ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត




- បណ្ណាល័យសម្ដេចម៉ែ មានព្រះកិត្តិយសបើកទទួលសាធារណជន
- លិខិតថ្វាយព្រះសព្ទសាធុការពរ សម្ដេចព្រះវររាជមាតាជាតិខ្មែរ ក្នុងពិធីបុណ្យចម្រើនព្រះជន្ម
- ឯកអគ្គរាជទូតអង់គ្លេស លោកដំនាវ ធីណា រ៉េដស ទស្សនាសំណង់ចេតិយ៍សំណង់និម្មិតរូប និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧០ ខែមិថុនា ឆ្នាំ២០២២

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧០ ខែមិថុនា ឆ្នាំ២០២២

## មាតិកា

### សំបុត្រ


- បណ្ណាល័យសម្ដេចម៉ែមានព្រះកិត្តិយសបើកទទួលសាធារណជន..........................១
- លិខិតថ្វាយព្រះសព្ទសាធុការពរសម្ដេចព្រះវររាជមាតាជាតិខ្មែរ .................... ៥


### ផ្នែកឯកសារ


- ភន ផល៖ ប្រធានរោងចក្រឥដ្ឋ (អ៣)..... ៦


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ឯកអគ្គរាជទូតអង់គ្លេស លោកជំទាវ ធីណា រ៉ែដស ទស្សនាសំណង់ចេតីយ៍ .................... ៩
- ដំណើរទស្សនកិច្ចសិក្សាសិស្សវិទ្យាល័យស្វាយចេកមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង... ១៣
- បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជាបើកសម្រាប់សាធារណជន .................... ១៤
- នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងប្រគល់ម៉ាស៊ីនវិទ្យុទាក់ទងដល់រដ្ឋបាលស្រុក .... ១៦
- ខ្ញុំដឹងរឿងរ៉ាវឪពុករបស់ខ្ញុំពីម្ដាយ និងពូ ....១៧
- សាំង អួន៖ កងកុមារក្នុងរបបខ្មែរក្រហម .. ២០
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំផ្អាវ ស្រុកត្រពាំង .......... ២២
- កម្រោងសូត្រចាមរបស់ .................. ៣៤
- រឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកោះសូទិន និងស្រុកកំពង់សៀម...៣៧




ចាន់ ម៉ុន អាយុ៨៣ឆ្នាំ រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កំពុងអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាសាធារណៈ


- មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាប្រវត្តិសាស្ត្រគ្រួសារ ..................... ៤៩
- វេទិកាថ្នាក់រៀនចុងសប្ដាហ៍ជាមួយសិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុនសែនអង្គរស ...៥១


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- «ទូលពិយាដ» (ត) ....................... ៥៧



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្មេរលេខនេះ ៖** ដា៉រដ្ឋ មេត្តា, ដេង ពង្សរ៉ាស៊ី, សួត វិចិត្រ, ឆាំង យុ, មេក វិន, ភួង សុខថា, ង៉ាន់ វីន, ហ៊ាន ពិសី, មីន សាណាស់, ទូច វណ្ណេត, អេង វណ្ណិកា, ថុន ស្រីពេជ្រ និង ឡុង វង្សសមិទ្ធ

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង


Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# បណ្ណាល័យសម្តេចម៉ែ មានព្រះកិត្តិយសបើកទទួលសាធារណជន

**លី សុខឃាង**





នៅក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល គម្រប់ព្រះជន្ម ៨៦ យាងចូល ៨៧ ព្រះវស្សា ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០២២ នេះ បណ្ណាល័យសម្តេចម៉ែមានព្រះកិត្តិយស និងសេចក្តីសោមនស្ស បើកទទួលសាធារណជនឲ្យចូលមកទស្សនាទៅតាមពេលវេលាកំណត់ដូចខាងក្រោម៖













*សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល យាង សម្ពោធបណ្ណាល័យ សម្តេចម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*សម្រាប់សាធារណជនដែលចូលមកអាន*

**បើកទទួលរៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ២:០០ រសៀល ដល់ ម៉ោង ៤:០០ រសៀល**

*សម្រាប់ដំណើរទស្សនកិច្ចជាក្រុម ដែលមានចំនួនកំណត់មិនលើសពី៥នាក់*

**បើកទទួលរៀងរាល់ថ្ងៃសុក្រ សប្តាហ៍ទី៤ នៃខែនីមួយៗ**

*សាធារណជនត្រូវអនុវត្តតាមវិធានការ ៣កុំ ៣ការពារ របស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩។*

*សាធារណជនដែលមានបំណងចង់មកធ្វើការសិក្សាស្រាវជ្រាវ សូមធ្វើការណាត់ជួបជាមុន។*

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងអ្នកស្រី*
*សុភ័ក្ត្រ ភាណា លេខទូរសព្ទ៖ ០៩២ ២៣៤ ៧០៧។*



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល យាងសម្ភោធបណ្ណាល័យ សម្តេចម៉ែៗ (បណ្ណាសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# លិខិតថ្វាយព្រះសព្ទសាធុការពរសម្ដេចព្រះវររាជមាតាជាតិខ្មែរ

## ក្នុងពិធីបុណ្យចម្រើនព្រះជន្ម




សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

***ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២***

*យើងខ្ញុំទាំងអស់គ្នា សូមក្រាបបង្គំទូលថ្វាយព្រះសព្ទសាធុការពរ សម្ដេចព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នាឱកាសដ៏មហាប្រសើរថ្លៃថ្លាក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គ។ ប្រជាជនកម្ពុជាមានភ័ព្វសំណាងក្រៃលែង ដែលអាចនិងបន្តជ្រកកោនក្រោមម្លប់ដ៏ត្រជាក់ត្រជុំ ដោយព្រះអង្គតែងលះបង់ព្រះកាយពលនិងព្រះរាជបញ្ញាញាណក្នុងការបំពេញព្រះបូជនីយកិច្ចដ៏ឧត្តុង្គឧត្តមគ្រងថែរក្សា និងយកព្រះទ័យ ទុកដាក់ខ្ពស់ចំពោះប្រជាជាតិកម្ពុជា។*

***ឆាំង យុ និងបុគ្គលិក ព្រមទាំង អ្នកស្ម័គ្រចិត្ត របស់លោកទាំងអស់***

# ភន ផល៖ ប្រធានរោងចក្រភ័ដ្ឋ (អ៣) តាខ្មៅ ក្រសួងឧស្សាហកម្ម

ដារ៉ារដ្ឋ មេត្តា



រោងចក្រតម្បាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ភន ផល អាយុ៤៤ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧) មានស្រុកកំណើតនៅភូមិទ័ពទាល់ ឃុំសង្កាក់ ស្រុកសង្កាក់ ខេត្តសូរិន្ទ (ប្រទេសថៃ)។ ប្រពន្ធខ្ញុំឈ្មោះ សាវ៉ែន គឺជាបុគ្គលិកពេទ្យ៧៥។ ពេលខ្ញុំ អាយុ១៥ឆ្នាំ ខ្ញុំមករស់នៅវត្តប៉ិន ក្នុងឃុំសង្កាក់។ ខ្ញុំបួសរយៈពេល១ឆ្នាំ ក៏ទាក់ទងជាមួយ យូ ខាំឿន គឺជាចៅហ្វាយខេត្តសុរិន្ទ, ផៃ វ៉ាន់ឌី គឺជាជំនួយការចៅហ្វាយខេត្តសុរិន្ទ និង ចំរើន ស៊ិក គឺជាពេទ្យសត្វនៅខេត្តសុរិន្ទ។ ក្រោយពីខ្ញុំស្គាល់ យូ ខាំឿន ក៏បញ្ចូលខ្ញុំទៅក្នុងអង្គការ សេអាតូ។ ការចូលនេះមិនមានគោរពទង់ជាតិអ្វីទេ គ្រាន់តែ យូ ខាំឿន គឺជាអ្នកខ្ទេសនាម។ ភារកិច្ចដែល យូ ខាំឿន ឲ្យខ្ញុំធ្វើមានពីរ គឺ១) ឲ្យខិតខំពង្រីកកម្លាំង និង២) ក្តាប់សភាពការណ៍ខាងក្នុងរបស់ប្រជាជនឲ្យជាប់។ ក្រោយមក យូ ខាំឿន, ចំរើន ស៊ិក និង ខ្ញុំ មានការចេញចូលនិងទាក់ទងអធិការវត្តប៉ិន ឈ្មោះ រ៉ុម។

ក្នុងឆ្នាំ១៩៥១ ខ្ញុំមកស្នាក់នៅវត្តពួក ស្ថិតនៅស្រុកពួក ខេត្តសៀមរាប តាមរយៈព្រះតេជគុណពីរអង្គ រៀននៅវត្តប៉ិនជាមួយគ្នា។ ខ្ញុំមកនៅវត្តពួកបានមួយឆ្នាំ ក៏សឹកមកភ្នំពេញដើរស៊ីឈ្នួលធាក់រ៉ឺម៉ក និងអូសទឹកលក់ ពេលខ្លះរកត្រីតាមដងទន្លេសាប។

ក្នុងឆ្នាំ១៩៥៦ ខ្ញុំស៊ីឈ្នួល ធាក់រ៉ឺម៉ក នៅខេត្តកំពត

បានរយៈពេល១ឆ្នាំ។ ខ្ញុំស្គាល់ឈ្មោះ វ៉ាង គឺជាអ្នកធាក់រ៉ឺម៉ក រហូតដល់ជិតស្និទ្ធជួលផ្ទះនៅជាមួយគ្នា និងដើរលេងស៊ីចុកជាមួយគ្នា។ រយៈពេលនោះ វ៉ាង ទាក់ទងខ្ញុំប៉ុន្តែមិនអប់រំខ្ញុំទេ។

ក្នុងឆ្នាំ១៩៥៩ វ៉ាង គឺជាគិញអប់រំខ្ញុំអំពីប្រាក់ខែ ព្រោះការធាក់ស៊ីក្លូ មានការយ៉ាប់យឺនណាស់។ក្រោយពីគាត់អប់រំខ្ញុំសម្រេចចិត្តខ្លួនឯងថាធ្វើអ្វីក៏ដោយឲ្យតែបានប្រាក់ខែស៊ីចាយសុខស្រួល។

ក្នុងឆ្នាំ១៩៦០វ៉ាង នាំខ្ញុំមកជួបជាមួយ វ៉ាន់ណាវ៉ា, ញៀន ធៀង គឺជាចៅហ្វាយខេត្តកំពត, ស៊ិន ទូច គឺជាគិញស័ក្តិ១ទៅជួបនៅផ្ទះរបស់ ញៀន ធៀង។ ពេលនោះ វ៉ាង ខទ្មេសនាមខ្ញុំឲ្យទាំង៣នាក់ ស្គាល់ជាខ្មែរគិញ។ ខទ្មេសនាមចប់ ញៀន ធៀង ប្រគល់ខ្ញុំ និង វ៉ាង ឲ្យទៅ ស៊ិន ទូច គឺជាអ្នកណែនាំអំពីភារកិច្ច និងដឹកនាំធ្វើសកម្មភាព។ ខ្ញុំមកនៅជាមួយ ស៊ិន ទូច ម្តុំសាលាខេត្តកំពត។ ស៊ិន ទូច ណែនាំនិងចាត់តាំង ភារកិច្ចស៊ើបរកអ្នកចម្លែក និងដើរចាប់ពួកលេងល្បែងស៊ីសង។

នៅក្នុងឆ្នាំ១៩៦២ ស៊ិន ទូច ខទ្មេសនាមកម្លាំងចំនួន៣នាក់ទៀតឲ្យធ្វើសកម្មភាពជាមួយ ខ្ញុំនិង វ៉ាង មានឈ្មោះ ញឹម គឺជាកម្មករធាក់រ៉ឺម៉ក់នៅកំពត, ឆែ គឺជាកម្មករធាក់រ៉ឺម៉ក់នៅកំពត និង សាញ់ គឺជាកម្មករធាក់រ៉ឺម៉ក់នៅកំពត។

ក្នុងឆ្នាំ១៩៧០ ក្រោយកើតមានរដ្ឋប្រហារ ប៊ុន ធឿន គឺជាចៅហ្វាយស្រុកភ្នំស្រួចនាំខ្ញុំមកនៅ ទឹរូមខេត្តកំពង់ស្ពឺ។ ពេលនោះ ប៊ុន ធឿន ចូលធ្វើទាហាននៅបន្ទាយច្បាមន។ ខ្ញុំនៅបានរយៈពេលពីរខែ ប៊ុន ធឿន ចាត់តាំងខ្ញុំចូលធ្វើជាទាហានជាមួយគាត់នៅបន្ទាយច្បារមន ស្ថិតក្រោមការដឹកនាំរបស់ ប៊ុន ធឿន។ ខ្ញុំធ្វើទាហានបានរយៈពេល៣ខែដោយសភាពការណ៍បដិវត្តន៍ខ្លាំងផ្ទោងគ្រាប់ចូលខ្លាំង ខ្ញុំរត់ចេញមកខាងស្រុកភ្នំស្រួច ហើយសូមប្រជាជនស្នាក់នៅ។ បន្ទាប់មកខ្ញុំសុំផ្ទះអ្នកភូមិស្នាក់នៅបណ្តោះអាសន្នខ្ញុំទំនាក់ទំនងធ្វើជាឈ្លបប្រចាំ ឃុំមហាសាំង។ ចូលធ្វើឈ្លបរយៈពេល២ខែ ខ្ញុំមកនៅក្នុងបដិវត្តន៍វរសេនាតូច១១៣ របស់ភូមិភាគនិរតី តាមការចាត់តាំងរបស់កងបដិវត្តន៍ តំបន់ និងស្រុក។ នៅក្នុងវរសេនាតូច ១១៣ ដែលមាន សោ គឺជាមេបញ្ជាការរបស់វរសេនាតូចភូមិភាគនិរតី,ណាម គឺជាសមាជិកវរសេនាតូច ១១៣, ខេង គឺជាអនុវរសេនាតូច១១៣។ ខ្ញុំបោះទីតាំងប្រចាំការនៅ ខាងជើងផ្លូវជាតិលេខ៤ ដែលកាលនោះខ្ញុំមានតួនាទីគឺជាប្រធានមន្ទីរវរសេនាតូច១១៣។

ក្នុងឆ្នាំ១៩៧២ ខ្ញុំទាក់ទងខ្មែរជាមួយ ខេង,សោ និង ណន ពួកគាត់អប់រំពីបុណ្យស័ក្តិនៅប្រទេសយួន ហើយមានការសប្បាយ។ ក្រោយអប់រំខ្ញុំ ទទួលការដាក់ភារកិច្ចឲ្យបំផ្លិចបំផ្លាញសម្ភារនៅក្នុងមន្ទីរ ហើយបង្កទំនាស់នៅក្នុងអង្គភាពឲ្យយុទ្ធជនទំនាស់ជាមួយអង្គការបដិវត្តន៍។ ភារកិច្ចដែលយើងអនុវត្តន៍កន្លងមកមាន៖ ១) ម្ហូបអាហារដែលអង្គការណែនាំផ្តល់ទៅសមរភូមិឲ្យគ្រប់គ្រាន់ប៉ុន្តែខ្ញុំបើកមិនឲ្យគ្រប់គ្រាន់ ហើយនិយាយថានៅ ខាងមុខត្រូវម្ចាស់ការ ខាងម្ហូបអាហារផង ២) ខោអាវ រាប់ពាន់ សម្រាប់ខ្ញុំទុកឲ្យខូចមិនព្រមបើកឲ្យអង្គភាពស្មៀកពាក់ ៣) ឯគ្រាប់រំសេវ ខ្ញុំរួមជាមួយ ខេង, សោរ កាយកប់គ្រាប់អស់ច្រើនគ្រាប់ ៤) អង្ករទុកឲ្យត្រូវភ្លៀងចោល ហើយមិនហាលថ្ងៃជាបន្តបន្ទាប់។ ក្រោយមកខ្ញុំដាច់ការ ទាក់ទងជាមួយ សោរ,ខេង, ណន ដោយអង្គការដកឲ្យធ្វើជាប្រធានពេទ្យ៣១១គ ប្រចាំនៅព្រៃល្វា ស្រុក៥៥ តំបន់៣៣។

ដើមឆ្នាំ១៩៧៣ ខ្ញុំអប់រំកម្លាំងបាន១នាក់ឈ្មោះ ស្រ៊ុន គឺជាបុគ្គលិកពេទ្យ ៣១១គ។ ក្រោយពីភ្ជាប់ខ្មែរ ហើយខ្ញុំនាំឲ្យ ស្រ៊ុន ស្គាល់គ្នា៣នាក់ទៀតមានឈ្មោះ ឡេង សម្បត្តិ គឺជាប្រធាននេសាទតំបន់៣៣, គ្រឹម វ៉ាន់ គឺជាគណស្រុក៥៥ តំបន់៣៣ និង អ៊ុន គឺជាគណតំបន់៣៣ ស្រុក៣៣។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការដកខ្ញុំមកធ្វើប្រធានរោងចក្រធ្វើឥដ្ឋអ៣ នៅតាខ្មៅរបស់ក្រសួងឧស្សាហកម្ម។ ខ្ញុំត្រូវរកវិធីធ្វើយ៉ាងណាអាចភ្ជាប់ខ្មែរចាស់បាន ពីនៅចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦។ ខ្ញុំចាប់ផ្តើម ទំនាក់ទំនងខ្មែរនៅក្នុងក្រសួងឧស្សាហកម្ម តាមរយៈការហៅគ្នាមកជប់លៀងហើយខ្ញុំខំភ្ជាប់នៅក្នុងរោងចក្រឥដ្ឋដើម្បីកសាងកម្លាំង។ នៅខែកុម្ភៈ ខ្ញុំអប់រំឈ្មោះ ឆួយ គឺជាប្រធានផ្នែកឥដ្ឋអ៣។



រោងចក្រអំពូលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែមករា ឆ្នាំ១៩៧៧ ខ្ញុំមកជួប ផល១៣៨(គណៈវរសេនាតូច១៣៨ កងពល៧០៣) និង ផា គឺជាគណៈកងវរសេនាតូច១៣៨ កងពល៧០៣ នៅពេលល្ងាចៗ ផល១៣៨(គណៈវរសេនាតូច១៣៨ កងពល៧០៣) ប្រាប់ពីគម្រោងការរត់ទៅស្រុកយួន ពីព្រោះសភាពការណ៍មិនអាចទប់ចលនាប់ដិវត្តន៍បានទេ គឺរត់កុំឲ្យអង្គការចាប់បានៗ នៅខែកុម្ភៈ ខ្ញុំហៅកម្លាំងក្បត់ក្នុងរោងចក្រឥដ្ឋអ៣ ទាំងអស់ចំនួន១៣នាក់មកប្រជុំៗ ខ្ញុំផ្សាយឲ្យកម្លាំងជាច្រើនទៀត ត្រូវបន្តធ្វើសកម្មភាពពង្រឹងកម្លាំងដែលកសាងបាន ហើយគិតថាថ្ងៃណាមួយរបបឯកជនពិតជាមកដល់មិនខានៗ ខែមេសា អង្គការណែនាំពីបញ្ហាការពារអគ្គីភ័យគ្រប់កន្លែង ដោយឡែករោងចក្រឥដ្ឋអ៣ ខ្ញុំ,ឆ្លួយ, ហ៊ិ គឺជាមេក្រុមដឹកជញ្ជូនដី នៅអ៣ បានឯកភាពគ្នាមិនធ្វើតាមព្រោះវិធានការការពារត្រូវរកពាង ធុង ដាក់ទឹកៗ ពួកខ្ញុំ មិនអាចរកពាងនិងធុងទឹកបានទេៗ ក្រៅពីសកម្មភាពនេះ កងវរសេនាតូច១៣៨ ចាប់ពីខែមេសា តែងតែមកកន្លែងខ្ញុំញឹកញាប់ ហើយប្រាប់ខ្ញុំពីរឿងរត់ទៅយួនតែទៅមិនបានៗ ខ្ញុំប្រាប់ថាខ្ញុំចង់ទៅដែរ ប៉ុន្តែ ផល១៣៨ (គណៈវរសេនាតូច១៣៨ កងពល៧០៣) មិនទាន់ឲ្យទៅទេឲ្យរង់ចាំសិន គឺរយៈពេល១ខែនឹងដឹងដំណឹងៗ ខែឧសភា យើងពិភាក្សាគ្នាហើយ ផល១៣៨ (គណៈវរសេនាតូច១៣៨ កងពល៧០៣) ប្រាប់ឲ្យចេញតាមច្រក ២៥ ទៅស្រុកយួន ទៅចូលធ្វើបដិវត្តន៍ជាមួយយួនៗ

ក្នុងឆ្នាំ១៩៧៧ ម៉ោងប្រហែលជា៧:០០យប់ ផល១៣៨ (គណៈវរសេនាតូច១៣៨ កងពល៧០៣) គេចខ្លួនដោយខ្ញុំចាត់តាំងឈ្មោះ ឆន គឺជាអ្នកបើកបរឡានជូនទៅ ប៉ុន្តែត្រូវអង្គការចាប់ ផល១៣៨ (គណៈវរសេនាតូច១៣៨ កងពល៧០៣) បានវិញៗ ឯសកម្មភាពក្នុងរោងចក្រខ្ញុំ ដឹកនាំធ្វើឲ្យខូចត្រាក់ទ័រជាបន្តបន្ទាប់រហូតចាត់តាំងកម្លាំងទម្លាយកង់ត្រាក់ទ័រទៀត ដើម្បីឲ្យស្ទះការងារៗ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំតែម្តងៗ

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ000៨៩៧ៗ រាល់ចម្លើយសារភាពរបស់អ្នកទោស ទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ភន ផល ពិតប្រាកដយ៉ាងណានោះទេៗ**

# ឯកអគ្គរាជទូតអង់គ្លេស លោកជំទាវ ធីណា រ៉េដស ទស្សនាសំណង់ចេតិយ៍សំណាង និម្មិតរូប និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម

*ផេង ពង្សរ៉ាស៊ី*



លោកស្រី ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ថតរូបជុំគ្នាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅចេតិយ៍សំណាងនិម្មិតរូប «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លោកជំទាវ ធីណា រ៉េដ ស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា និងសហការីលោកជំទាវគឺ វុទ្ធី សុកញ្ញា បានមកធ្វើទស្សនកិច្ចនៅ ទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជាកន្លែងដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសាងសង់ចេតិយ៍ជាសំណាងសមូហភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានសាច់ញាតិបងប្អូនស្លាប់ក្នុងរបបខ្មែរក្រហម និងសំណង់ផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

ដំណើរទស្សនកិច្ចរបស់លោកជំទាវ និងសហការីត្រូវបានទទួលស្វាគមន៍ដោយលោកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងបុគ្គលិក ព្រមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណ១០នាក់ នៅនឹងទីតាំងផ្ទាល់ នៅវេលាម៉ោង១០កន្លះ។ លោក ផេង ពង្សរ៉ាស៊ី បានជម្រាបជូនលោកជំទាវអគ្គរាជទូត ពីការសាងសង់សំណង់



រូបដើរមុខខាង លោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ទៅទស្សនាសំណង់ចេតិយ៍សំណង់និមិត្តរូប នៅទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបទីមួយរាប់ពីឆ្វេង លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និង លោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ទស្សនាសំណង់ចេតិយ៍ សំណង់និមិត្តរូប នៅទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ចេតិយ៍ និងផ្ទាំងពាក្យស្លោក និងបុព្វហេតុដែលនាំឲ្យមានការសាងសង់សំណង់រឹងមាំទាំងពីរ ថាជាការស្នើសុំរបស់អាជ្ញាធរមូលដ្ឋានបន្ទាប់ពីមានការឯកភាពគ្នាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅក្នុងភូមិនានានៃឃុំចាម ស្រុកកំពង់ត្របែក សម្រាប់សំណង់និមិត្តរូបក្រោយការបិទបញ្ចប់ដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ លោកស្រី សូ ហ្វារីណា បានប្រាប់ពីគម្រោងសំខាន់ៗមួយចំនួនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាន និងកំពុងអនុវត្តនៅក្នុងភូមិសាស្ត្រខេត្តព្រៃវែង ជាពិសេសនៅក្នុងស្រុកកំពង់ត្របែករួមទាំងគម្រោងស្តីពីការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផង។

លោកជំទាវអគ្គរាជទូតបានជួបសំណេះសំណាលជាមួយអ្នកភូមិដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកដែលបានយកអដ្ឋិធាតុសាច់ញាតិបងប្អូនដែលបានស្លាប់ក្នុងរបបខ្មែរក្រហម មកដាក់តម្កល់នៅក្នុងចេតិយ៍ នៅក្រោមដើមត្នោតបីបួនដើម ស្ថិតនៅលើទីតាំងទួលធាតុ ក្បែរសំណង់ចេតិយ៍ និងផ្ទាំងពាក្យស្លោក ដោយក្តីសោមនស្សរីករាយ និងភាពស្និទ្ធស្នាល។ ជាដំបូង លោកជំទាវបានថ្លែងអំណរគុណចំពោះវត្តមានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចំណាយពេលវេលាមកទទួលស្វាគមន៍លោកជំទាវ។ លោកជំទាវ ក៏បានរំឭកដល់អ្នករស់រានមានជីវិតទាំងអស់ពីសារសំខាន់នៃការសាងសង់ចេតិយ៍ និងផ្ទាំងពាក្យស្លោកនេះថា វាពិតជាបានបង្កើននូវការចងចាំ និងការផ្សះផ្សាជារួមមួយក្រោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រមទាំងជាកន្លែងបង្រៀនយុវជនជំនាន់ក្រោយពីប្រវត្តិសាស្ត្រនេះទៀតផង តាមរយៈការប្រើប្រាស់ទីតាំង និងសំណង់នេះជាថ្នាក់រៀន។ លោកជំទាវមានប្រសាសន៍





លោកស្រី ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅចេតិយ៍សំណង់និម្មិតរូប «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ថ៉ុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដូច្នេះថា «ខ្ញុំសប្បាយចិត្តណាស់ដែលឃើញបងប្អូនពូមីងបានមកចូលរួមនៅទីនេះ។ ខ្ញុំមកថ្ងៃនេះ គឺចង់មកមើលចេតិយ៍ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែសាងសង់រួចរាល់កាលពីខែមេសា កន្លងទៅនេះ។ ដោយយល់ឃើញថា បងប្អូនពូមីងដែលជាជនរងគ្រោះ មានសាច់ញាតិបងប្អូនស្លាប់នៅក្នុងរបបខ្មែរក្រហម ទើបមានការសាងសង់សំណង់ចេតិយ៍នេះឡើងនៅទីនេះ ដើម្បីគោរពវិញ្ញាណក្ខន្ធដល់ពួកគាត់ដែលបានស្លាប់ទៅ។ ទីតាំងនេះ ក៏ជាកន្លែងសម្រាប់បង្រៀនដល់ក្មេងជំនាន់ក្រោយឲ្យចងចាំពីរបបខ្មែរក្រហម និងទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យវិលត្រឡប់មកវិញសារជាថ្មីម្តងទៀត»។ ជាចុងក្រោយ លោកជំទាវបានសួរទៅកាន់អ្នករស់រានមានជីវិតទាំងអស់ពីអាយុ ការរស់នៅប្រចាំថ្ងៃ និងបញ្ហាសុខភាព។ មុនដំបូង លោកជំទាវបានបង្ហាញពីអារម្មណ៍របស់លោកជំទាវតាមរយៈការមើលឃើញផ្ទាល់ភ្នែកថាអ្នករស់រានមានជីវិតទាំងអស់ពិតជាមានសុខភាពល្អ និងរឹងមាំណាស់។ ប៉ុន្តែនៅពេលដែលលោកជំទាវសួរនាំដល់បញ្ហាសុខភាព អ្នករស់រានមានជីវិតភាគច្រើន ជាពិសេសអ្នកដែលមានអាយុលើស៦០ឆ្នាំ សុទ្ធតែមានជំងឺទឹកនោមផ្អែម ជំងឺសន្លាក់ និងជំងឺលើសឈាម។ លោកជំទាវមានប្រសាសន៍ដូច្នេះថា «...មួយវិញទៀតខ្ញុំបានដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានគម្រោងមួយពាក់ព័ន្ធនឹងការគាំពារសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំកោតសរសើរអ៊ុំពូមីង ដែលមើលទៅឃើញថាអ៊ុំពូមីងមានវ័យចាស់ និងមានសុខភាពរឹងមាំ ក៏ប៉ុន្តែតាមរយៈការសំណេះសំណាលរបស់ខ្ញុំជាមួយបងប្អូនពូមីងទើបខ្ញុំដឹងថា អ៊ុំពូមីងភាគច្រើន សុទ្ធតែមានជំងឺប្រចាំកាយ ដូចជាលើសឈាម ទឹកនោមផ្អែម ក្រពះ វិលមុខ ស្ពឹកស្រពន់ជាដើម»។ ចុងបញ្ចប់ លោកជំទាវបានផ្តាំផ្ញើឲ្យអ្នករស់រានទាំងអស់ថែរក្សាសុខភាព និងបន្តចែករំលែកបទពិសោធន៍របស់ខ្លួនដល់ក្មេងៗជំនាន់ក្រោយទៀត ដើម្បីថែរក្សាការចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចូលរួមទប់ស្កាត់ការកកើតឡើងវិញនៃរបបនេះនាពេលអនាគត។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានវត្តមាននៅឯសំណង់ចេតិយ៍សហគមន៍បានថ្លែងអំណរគុណដល់លោកជំទាវ ធីណា វ៉ែដស ដែលបានយកចិត្តទុកដាក់និងចុះមកសួរសុខទុក្ខអ្នករស់រានមានជីវិតដោយផ្ទាល់នាថ្ងៃនេះ។ នេះគឺជាកាយវិការមួយដែលបង្ហាញថា រឿងរ៉ាវរបស់គាត់មិនត្រូវបានបំភ្លេច។

អ្នករស់រានមានជីវិតទាំងអស់បានសំណូមលោកជំទាវឲ្យជួយកែលម្អបរិវេណចេតិយ៍ ជាពិសេសឈូសឆាយផ្លូវចូលមកកាន់ចេតិយ៍ឲ្យកាន់តែប្រសើរជាងនេះ ដើម្បីឲ្យគាត់ទាំងអស់គ្នាអាចមកប្រារព្ធកម្មវិធីផ្សេងៗ ដូចជា ទិវាចងចាំ និងវេទិកាពិភាក្សាអំពីរឿងរ៉ាវពីសម័យខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយនៅទីនេះបានកាន់តែប្រសើរ។

សូមបញ្ជាក់ថា កាលពីបីខែមុន គឺនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោកជំទាវ ធីណា វ៉ែដស បានមកធ្វើទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ នៃមជ្ឈ-មណ្ឌលឯកសារកម្ពុជា ម្តងរួចហើយ ដើម្បីស្វែងយល់ពីដំណើរការនៃបណ្ណាល័យនេះ និងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



លោក ដេង ពងរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និង លោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ទស្សនាសំណង់ចេតិយ៍សំណង់និម្មិតរូប នៅ ទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
( ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជួបលោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា នៅចេតិយ៍សំណង់និម្មិតរូប «ទួលធាតុ»។
( ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ដំណើរទស្សនកិច្ចសិក្សា

## សិស្សវិទ្យាល័យស្វាយចេក មកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

**ស្លួត ទិចិត្រ**



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងថតរូបជុំគ្នាជាមួយសិស្សវិទ្យាល័យស្វាយចេក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ សិស្សានុសិស្សចំនួន២៧ នាក់ មកពីវិទ្យាល័យស្វាយចេក នៃខេត្តបន្ទាយមានជ័យ បានបំពេញទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីស្វែងយល់ពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និង «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង»។

ទស្សនកិច្ចសិក្សានេះ ត្រូវបានធ្វើឡើងនៅក្នុងអតីតផ្ទះប្រជុំរបស់តាម៉ុកលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្ននេះត្រូវបានប្រែក្លាយទៅជាទីកន្លែងអប់រំពីសន្តិភាព និងសិទ្ធិមនុស្ស ដល់យុវជនជំនាន់ក្រោយ។


បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សវិទ្យាល័យស្វាយចេក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# បណ្ណាសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា បើកសម្រាប់សាធារណជន

ឆាំង យុ




មន្ត្រីអង្គការសហប្រជាជាតិចូលរួមពិធីសម្ពោធខ្សែភាពយន្តឯកសារឆ្មាំព្រៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា ប្ដេជ្ញាផ្ដល់សិទ្ធិអំណាចដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្រុមគ្រួសារ សហគមន៍ និងសាធារណជន ជាមួយនឹងការទទួលបានព័ត៌មានកាន់តែច្រើនអំពីប្រវត្តិសាស្ត្រ ខ្មែរក្រហម។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែបន្តធ្វើឲ្យបណ្ណសាររបស់ខ្លួនកាន់តែអាចចូលប្រើប្រាស់បានទូលំទូលាយតាមរយៈប្រព័ន្ធអនឡាញ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏កំពុងធ្វើឲ្យបណ្ណសារដ្ឋានរូបវ័ន្តរបស់ខ្លួនកាន់តែអាចចូលប្រើប្រាស់បានដោយផ្ទាល់ផងដែរ។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានមោទកភាពក្នុងការប្រកាសជាផ្លូវការនូវការបើកដំណើរការមជ្ឈ-មណ្ឌលប្រចាំតំបន់ទាំង៥របស់ខ្លួន ដែលតំណាងឲ្យបណ្ដាញមជ្ឈមណ្ឌលឯកសារកម្ពុជានៅទូទាំងប្រទេស។

ការបង្កើតមជ្ឈមណ្ឌលប្រចាំតំបន់ទូទាំងប្រទេស ស្របតាមបំណងប្រាថ្នារបស់ជនរងគ្រោះពីរបបខ្មែរក្រហម ដែលចង់ឃើញនូវធនធានលើបទពិសោធន៍និងរឿងរ៉ាវនៃសម័យកាលប្រវត្តិសាស្ត្ររបស់ពួកគេ នៅគ្រប់តំបន់នៃប្រទេសកម្ពុជា។

មជ្ឈមណ្ឌលនៅតាមសហគមន៍មិនត្រឹមតែផ្ដល់នូវការរៀបចំដ៏សម្បូរបែបនៃធនធានពហុប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការអប់រំ និងការស្រាវជ្រាវប៉ុណ្ណោះទេ

មជ្ឈមណ្ឌលនៅតាមសហគមន៍ក៏បម្រើជាទីតាំងប្រជុំដ៏សំខាន់សម្រាប់វេទិកាសហគមន៍ ការធ្វើបទបង្ហាញរបស់វាគ្មិន សន្និសីទ ការពិនិត្យសៀវភៅឡើងវិញ ការតាំងពិព័រណ៍សិល្បៈ និងតន្ត្រី ព្រមទាំងព្រឹត្តិការណ៍វប្បធម៌ផ្សេងៗទៀត។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបង្កើតអង្គភាពសេវាកម្មយុវជនស្ម័គ្រចិត្តមួយដែលមានឈ្មោះថា ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ដើម្បីបង្កើនភាពងាយស្រួល និងផ្សព្វផ្សាយកិច្ចការរបស់មជ្ឈមណ្ឌលដល់សហគមន៍មូលដ្ឋាន។ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ទាញយកការបំផុសគំនិតរបស់ខ្លួនពីក្រុមអ្នកស្ម័គ្រចិត្តអាមេរិក (AmeriCorps) ដែលជាអង្គភាពសេវាកម្មយុវជនស្ម័គ្រចិត្តនៅសហរដ្ឋអាមេរិក ដែលខិតខំដល់ការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងជំនាញវិជ្ជាជីវៈរបស់អ្នកស្ម័គ្រចិត្ត ដល់ការកសាង និងកែលម្អសហគមន៍ឡើងវិញ។ មជ្ឈមណ្ឌលនីមួយៗមានអ្នកស្ម័គ្រចិត្តចំនួនពី៥នាក់ ទៅ ១០ នាក់ដែលត្រូវបានជ្រើសរើស ហើយនៅទូទាំងប្រទេស មជ្ឈមណ្ឌលឯកសារកម្ពុជា មានក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាជាង ៥០០ នាក់ ដើម្បីជួយដល់អ្នករស់រានមានជីវិតចំពោះទម្លាប់នៃការរស់នៅប្រចាំថ្ងៃ ប្រមូលប្រវត្តិផ្ទាល់មាត់ និងធ្វើការស្រាវជ្រាវអំពីប្រវត្តិសហគមន៍មូលដ្ឋាន។

មជ្ឈមណ្ឌលឯកសារកម្ពុជា បន្តធ្វើការផ្ដោតលើការបង្កើនធនធានដែលមាននៅក្នុងមជ្ឈមណ្ឌលនីមួយៗ និងការបង្កើតមជ្ឈមណ្ឌលបន្ថែមនៅក្នុងតំបន់ផ្សេងទៀត។

មជ្ឈមណ្ឌលនៅតាមខេត្តទាំង៥ រួមមាន៖

១) មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

២) មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

៣) មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

៤) មជ្ឈមណ្ឌលឯកសារកោះថ្ម និង

៥) មជ្ឈមណ្ឌលឯកសារខេត្តតាកែវ។

សាធារណជនចូលប្រើប្រាស់បណ្ណសារឌីជីថលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សូមទាក់ទងទង៖ រស់ សំពៅ, អ៊ីម៉ែល៖ truthampeou.r@dccam.org

សាធារជនចូលអានឯកសារនៅបណ្ណាល័យសម្ដេចម៉ែ សូមទាក់ទង៖

សុភ័ក្ត្រ ភាណា, អ៊ីម៉ែល truthpheana.s@dccam.org ។

សូមអរគុណ!



សិស្សានុសិស្សទស្សនកិច្ចចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហមនៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡូហ្គោសហគមន៍អឺរ៉ុប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡូហ្គោទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡូហ្គោកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

## ប្រគល់ម៉ាស៊ីនវិទ្យុទាក់ទងដល់រដ្ឋបាលស្រុកអន្លង់វែង

**មេក ឌិន**



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងលោក ហោ ជិនវិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង នៅលើភ្នំដងរែក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



វិទ្យុទាក់ទងនៅលើខ្នងភ្នំដងរែក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ប្រគល់វិទ្យុទាក់ទងដល់លោក ហោ ជិនវិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ លោក ហោ ជិនវិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង បានទទួលម៉ាស៊ីនវិទ្យុទាក់ទងចល័តមួយគ្រឿង ដែលជាអំណោយរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកអភិបាលស្រុកក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកបណ្ឌិត លី សុខឃាង ដែលតំណាងឲ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកអភិបាលស្រុកមានប្រសាសន៍ថា ម៉ាស៊ីនវិទ្យុទាក់ទងចល័តប្រភេទ Motorola GM300 ដែលមានកម្លាំង៤៥វ៉ាត់នេះ នឹងរួមចំណែកនិងសម្រួលដល់ការទំនាក់ទំនងសម្រាប់ការកសាងស្តូបអនុស្សាវរីយ៍ឈ្មោះ ឈ្មោះអន្លង់វែង និងបម្រើឲ្យវិស័យទំនាក់ទំនងរបស់ស្រុកអន្លង់វែងទាំងមូល ដោយរាប់ទាំងការគ្រប់គ្រងសន្តិសុខជាដើម។

# ខ្ញុំដឹងរឿងរ៉ាវឪពុករបស់ខ្ញុំពីម្ដាយ និងពូ

**ភួង សុខថា**

ខ្ញុំឈ្មោះ ភួង សុខថា ភេទស្រី អាយុ២៦ឆ្នាំ។ ខ្ញុំរស់នៅភូមិព្រៃកណ្ដៀង ឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ សព្វថ្ងៃខ្ញុំគឺជាអ្នកស្ម័គ្រចិត្តរបស់មជ្ឈ-មណ្ឌលឯកសារ ខេត្តព្រៃវែង។ ចាប់តាំងពីខ្ញុំបានធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើរឿងរ៉ាវរបស់អ្នករស់រានពីរបបខ្មែរក្រហម រួមទាំងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរក្រហមដែលប្រជាជនកម្ពុជាបានឆ្លងកាត់។ បន្ថែមលើនេះ បានធ្វើឲ្យខ្ញុំចង់ដឹងរឿងរ៉ាវជីវិតរបស់ឪពុកខ្ញុំឈ្មោះ សុខ ផន ដែលបានស្លាប់បាត់បង់ជីវិតតាំងពីខ្ញុំនៅតូច ដូច្នេះខ្ញុំក៏បានសាកសួរប្អូនប្រុសរបស់ឪពុកខ្ញុំនិងម្ដាយរបស់ខ្ញុំទាក់ទងនឹងប្រវត្តិឪពុករបស់ខ្ញុំ។

តាមសម្ដីរបស់ពូ សុខ ភី អាយុ៥៦ឆ្នាំ ត្រូវជាប្អូនបង្កើតរបស់ឪពុកខ្ញុំ បាននិយាយរៀបរាប់ថា ឪពុករបស់ខ្ញុំឈ្មោះ សុខ ផន កើតនៅឆ្នាំ១៩៦៤។ ឪពុករបស់ខ្ញុំមានស្រុកកំណើតនៅភូមិជ្រួល ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ កាលពីក្មេង ឪពុករបស់ខ្ញុំមិនបានរៀនសូត្រទេ ព្រោះគ្រួសារខ្វះខាត ហើយប្រទេសមានសង្គ្រាម។ នៅពេលយោធាខ្មែរក្រហមចូលមកក្នុងភូមិនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងឲ្យឪពុករបស់ខ្ញុំចូលទៅនៅក្នុងកងកុមារភូមិហើយប្រធានកងកុមារខ្មែរក្រហមប្រើឪពុកខ្ញុំឲ្យ ឃ្វាលគោ-ក្របី និងដើរប្រមូលជីយកទៅ ទុកនៅក្នុងសហករណ៍។ ក្រោយមក ខ្មែរក្រហមផ្លាស់ប្ដូរការងារឪពុករបស់ខ្ញុំឲ្យទៅរែកដីបាតស្រះ និងត្រពាំងយក ទៅដាក់នៅវាលស្រែ។ ឪពុករបស់ខ្ញុំគឺជាក្មេងប្រុសម្នាក់ដែលខិតខំធ្វើការងារ ហើយប្រធានកងមិនដែលស្ដីបន្ទោសគាត់ឡើយ។ រហូតដល់ឪពុករបស់ខ្ញុំពេញវ័យ ទើបប្រធានកងចាត់តាំងគាត់ឲ្យរែកដី ភ្ជួរស្រែ និងស្ទូងនៅក្នុងភូមិ។ ប្រធានសហករណ៍ពេញចិត្តនឹងការងាររបស់ឪពុកខ្ញុំ ព្រោះឪពុកខ្ញុំគឺជាក្មេងខស្វា ហ៍ ដូច្នេះហើយទើបប្រធានកងមិនដែលឲ្យគាត់ចេញទៅធ្វើការនៅ ខាងក្រៅភូមិ។


ភួង សុខថា គឺជាអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (ភួង សុខថា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ឪពុករបស់ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាមេសាង។ ឪពុករបស់ខ្ញុំបានជិះកង់ដឹកប្អូនរបស់គាត់ពីរនាក់ទៅរៀនដែរ។ ឪពុករបស់ខ្ញុំរៀន






សុខ ដន ឪពុករបស់ ភួង សុខថា គឺជាអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (ភួង សុខថា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



រាប់ពីស្តាំទី២ ហង់ ធរ គឺជាយាយរបស់ ភួង សុខថា។ (ភួង សុខថា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រហូតដល់ថ្នាក់ទី៧ នៅក្នុងឆ្នាំ១៩៨៥។ ក្រោយពីឪពុករបស់ខ្ញុំបញ្ចប់ការសិក្សាភ្លាម បងធម៌ឈ្មោះ ភ័ណ បម្រើការជាមន្ត្រីនគរបាលនៅខេត្តព្រៃវែង មកហៅឪពុកខ្ញុំឲ្យទៅធ្វើការជាមួយគាត់។ ឈ្មោះ ភ័ណ ឲ្យឪពុកខ្ញុំសរសេរប្រវត្តិរូបចូលធ្វើការជាមន្ត្រីនគរបាលក្នុងខេត្តព្រៃវែង។ បន្ទាប់ពីឪពុករបស់ខ្ញុំចូលធ្វើជាមន្ត្រីនគរបាលខេត្តព្រៃវែង បានរយៈពេល១ខែ គាត់បានឡើងតួនាទីជាប្រធាន «គ» រហូតមកដល់ចុងឆ្នាំ១៩៨៩។ រយៈពេល៤ឆ្នាំ ក្រោយមកឪពុករបស់ខ្ញុំត្រូវបានមេបញ្ជាការឈ្មោះ ឃឹនណូ បញ្ជូនគាត់ឲ្យមកយាមនៅទួលប្រលៀសដែលមានទីតាំងនៅខាងកើតភូមិព្រៃកណ្តៀង ចម្ងាយប្រហែលកន្លះគីឡូម៉ែត្រ។ នៅពេលដែលឪពុករបស់ខ្ញុំប្រចាំការនៅទួលប្រលៀស ប្រធានភូមិព្រៃកណ្តៀងឈ្មោះ ហេង ឆឹង គឺជាប្រធានភូមិចាស់ បានស្នើកងកម្លាំងរបស់ឪពុកខ្ញុំឲ្យចុះជួយប្រជាជនស្រង់កំប្លោកនៅក្នុងភូមិព្រៃកណ្តៀង រយៈពេល២សប្តាហ៍ ។

ចំណែកម្តាយរបស់ខ្ញុំឈ្មោះ លន់ សុគន្ធា អាយុ៥២ឆ្នាំ កើតនៅភូមិព្រៃកណ្តៀង ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង បានរៀបរាប់ថា នៅថ្ងៃដែលឪពុករបស់ខ្ញុំទៅជួយប្រជាជនក្នុងភូមិព្រៃកណ្តៀងស្រង់កំប្លោក ឪពុករបស់ខ្ញុំបានជួបគាត់ និងចាប់ចិត្តស្រឡាញ់គាត់។ ឪពុករបស់ខ្ញុំបាននាំចាស់ទុំចូលទៅស្តីដណ្តឹងម្តាយរបស់ខ្ញុំ ប៉ុន្តែត្រូវបានម្តាយរបស់ខ្ញុំប្រកែក ព្រោះពេលនោះម្តាយខ្ញុំគិតថាគាត់នៅក្មេងអាយុត្រឹមតែ១៧ឆ្នាំមិនអាចមានគ្រួសារឡើយ។ ក្រោយមកដោយសារតែយាយរបស់ខ្ញុំឈ្មោះ ហង់ធរ ចង់បានកូនប្រសារធ្វើជានគរបាល ទើបបង្ខំម្តាយរបស់ខ្ញុំឲ្យរៀបការ។ យាយរបស់ខ្ញុំគិតថាប្រសិនបើគាត់មានកូនប្រសាជានគរបាល នោះកូនប្រុសរបស់គាត់ម្នាក់ទៀតនឹងមិនមានឈ្មោះចូលធ្វើជាទាហានវាយជាមួយខ្មែរក្រហមទេ។ ម្តាយរបស់ខ្ញុំបានព្រួសម្តីយាយរបស់ខ្ញុំបែបនេះ ក៏ព្រមរៀបការជាមួយឪពុករបស់ខ្ញុំនៅក្នុងឆ្នាំ១៩៩១។

បន្ទាប់ពីម្តាយខ្ញុំរៀបការជាមួយឪពុករបស់ខ្ញុំបានរយៈពេលកន្លះខែ មេបញ្ជាការរបស់ឪពុកខ្ញុំឈ្មោះ ឃឹនណូ ចាត់តាំងឪពុករបស់ខ្ញុំទៅបំពេញបេសកម្មនៅខេត្តបាត់ដំបងរយៈពេល៣ខែ។ នៅពេលនោះ ឪពុករបស់ខ្ញុំមានតួនាទីជាប៉ូលីសអាបឹ។ ពេលត្រឡប់

មកពីខេត្តបាត់ដំបងវិញ ឪពុករបស់ខ្ញុំធ្វើការនៅស្នងការនគរបាល ខេត្តព្រៃវែងដដែល និងមានតួនាទីដដែល។

រយៈពេល៣ខែ បន្ទាប់ពីឪពុករបស់ខ្ញុំត្រឡប់មកវិញ មេបញ្ជាការឈ្មោះ យឺនណូ ចាត់តាំងឪពុករបស់ខ្ញុំឲ្យទៅបំពេញបេសកម្មនៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺបន្តទៀត។ អំឡុងពេលឪពុករបស់ខ្ញុំទៅធ្វើការនៅខេត្តកំពង់ស្ពឺ ម្ដាយរបស់ខ្ញុំចាប់ផ្ដើមឈឺពោះឆ្លងទន្លេបានបងប្រុសរបស់ខ្ញុំ។ រយៈពេល៣ខែក្រោយមក ឪពុករបស់ខ្ញុំបានត្រឡប់មកធ្វើការនៅស្នងការនគរបាលខេត្តព្រៃវែងវិញ និងមានតួនាទីជាប្រធាន «គ»។

មិនយូរប៉ុន្មាន ឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅបំពេញបេសកម្មនៅខេត្តប៉ៃលិនរយៈពេល៣ខែទៀត។ នៅពេលឪពុករបស់ខ្ញុំបានត្រឡប់មកធ្វើការនៅខេត្តព្រៃវែងបានរយៈពេល៣ឆ្នាំ មេបញ្ជា និងអនុបញ្ជាការរបស់ឪពុកខ្ញុំឈ្មោះ យឺនណូ និង ចាន់ ប្រកប បានចាត់តាំងឪពុករបស់ខ្ញុំឲ្យដឹកនាំកម្លាំងនៅស្នងការនគរបាលខេត្តព្រៃវែង ទាំងអស់ចុះទៅបំពេញបេសកម្មនៅខេត្តប៉ៃលិនជាលើកទីពីរ។ ម្ដាយរបស់ខ្ញុំបានសួរទៅឪពុកខ្ញុំថា ហេតុអ្វីម្ដងនេះចុះទៅខេត្តប៉ៃលិនពីរដង។ កន្លងមកម្ដាយខ្ញុំមិនដែលសួរឪពុករបស់ខ្ញុំទេនៅពេលចុះទៅបំពេញបេសកម្ម។ ឪពុករបស់ខ្ញុំប្រាប់ម្ដាយខ្ញុំថា ការចុះទៅបំពេញបេសកម្មនៅខេត្តប៉ៃលិនជាលើកទីពីរនេះ ព្រោះយើងដេញខ្មែរក្រហមមិនទាន់ចេញអស់។ នៅពេលឪពុកខ្ញុំប្រាប់ម្ដាយខ្ញុំហើយ ឪពុករបស់ខ្ញុំក៏បានផ្ដាំបងប្រុសខ្ញុំថា «កូនត្រូវមើលថែប្អូន និងស្រឡាញ់ប្អូន»។ នៅពេលឪពុកខ្ញុំផ្ដែផ្ដាំរួច គាត់ក៏បានចាកចេញទៅ ចំណែកម្ដាយរបស់ខ្ញុំសង្កេតឃើញថាឪពុករបស់ខ្ញុំនិយាយប្លែកពីមុន។

នៅថ្ងៃដែលឪពុករបស់ខ្ញុំត្រូវបញ្ចប់បេសកម្មរយៈពេល៣ខែនៅខេត្តប៉ៃលិន ម្ដាយរបស់ខ្ញុំយល់សប្តិឃើញឪពុករបស់ខ្ញុំបានមកគោះទ្វារ ឲ្យម្ដាយខ្ញុំបើកទ្វារឲ្យគាត់ឡើងផ្ទះ។ បន្ទាប់មកឪពុករបស់ខ្ញុំបាននិយាយប្រាប់ម្ដាយខ្ញុំថា គាត់បានស្លាប់ហើយ។ នៅពេលឮឪពុកខ្ញុំនិយាយដូច្នេះ ម្ដាយរបស់ខ្ញុំបានភ្ញាក់ដឹងខ្លួន និងស្ទុះទៅបើកទ្វារ ប៉ុន្តែមិនឃើញឪពុកខ្ញុំទេ។ ម្ដាយរបស់ខ្ញុំបានខិតខំនិយាយបន្ទប់ខ្លួនឯងថា វាគ្រាន់តែជាការយល់សប្តិតែប៉ុណ្ណោះ។

នៅវេលាប្រហែលម៉ោង៨ពារសៀលថ្ងៃបន្ទាប់ ឈ្មោះ កង ភា គឺជាមន្ត្រីនគរបាល និងជាមិត្តភក្តិរបស់ឪពុកខ្ញុំបានមកប្រាប់ម្ដាយខ្ញុំថា សុខ ផន បានស្លាប់ហើយ។ ឈ្មោះ កង ភា ក៏បានប្រាប់ម្ដាយរបស់ខ្ញុំឲ្យរៀបចំផ្ទះសម្បែងរង់ចាំទទួលសាកសពឪពុករបស់ខ្ញុំ។ ពេលម្ដាយខ្ញុំឮឈ្មោះ កង ភា ប្រាប់បែបនេះ គាត់យំរហូតទាល់តែសាកសពឪពុករបស់ខ្ញុំត្រូវបានកម្លាំងនគរបាលដឹកមកដល់ផ្ទះ។ សាកសពឪពុករបស់ខ្ញុំត្រូវបានដឹកពីខេត្តប៉ៃលិនដោយចំណាយពេល២ថ្ងៃទើបមកដល់ស្រុក។ នៅពេលបុណ្យសពឪពុករបស់ខ្ញុំមានកងទ័ព និងនគរបាលជាច្រើនបានមកចូលរួម និងយាមនៅជុំវិញផ្ទះខ្ញុំរហូតដល់បុណ្យខួបគម្រប់៧ថ្ងៃ។ នៅពេលនោះ មេស្នងការនគរបាលខេត្តព្រៃវែង ឈ្មោះ ពេជ្រ ជីវន្ត ក៏បានមកចូលរួម និងជួយឧត្ថម្ភប្រាក់ដល់ម្ដាយខ្ញុំដែរ។

ម្ដាយខ្ញុំបានប្រាប់ខ្ញុំថា នៅពេលដែលឪពុកខ្ញុំស្លាប់ ខ្ញុំអាយុទើបតែ១ខួបតែប៉ុណ្ណោះ ដូច្នេះខ្ញុំមិនអាចចំណាំមុខមាត់របស់ឪពុករបស់ខ្ញុំច្បាស់លាស់ទេ។



ស្ត្រីអង្គុយឱបក្បាលជង្គង់ ឈ្មោះ លន់ សុគន្ធា គឺជាម្ដាយរបស់ ភួង សុខថា។
( ភួង សុខថា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# សាំង អួន ៖ កងកុមារក្នុងរបបខ្មែរក្រហម

ផាន់ ទីន



សាំង អួន អាយុ៦០ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រសាំង ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សាំង អួន ភេទស្រី មានអាយុ៦០ឆ្នាំកើតនៅភូមិក្រសាំង ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ។ ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ។ ខ្ញុំមានឪពុកឈ្មោះ គាន់ និងម្តាយឈ្មោះ គួយ និងមានបងប្អូនចំនួន ៩ នាក់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនក្នុងភូមិរបស់ខ្ញុំមួយចំនួនត្រូវបានខ្មែរក្រហមជម្លៀសទៅឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ប៉ុន្តែខ្ញុំនិងក្រុមគ្រួសារមិនត្រូវបានខ្មែរក្រហមជម្លៀសចេញទេដោយអង្គការឲ្យរស់នៅភូមិឃុំសន្ទុងដដែល។ ដំបូងខ្មែរក្រហមបែងចែកអង្ករឲ្យប្រជាជនទៅតាមក្រុម និងឲ្យហូបនៅតាមផ្ទះ។ ក្រោយមកខ្មែរក្រហម ចាប់ផ្តើមប្រមូលប្រជាជនឲ្យចូលក្នុងសហករណ៍ ហើយចែកពោតមួយកំប៉ុងសម្រាប់មនុស្ស៣នាក់។ ខ្ញុំយកគ្រាប់ពោតដែលខ្មែរក្រហមចែកឲ្យមកស្ងោលាយជាមួយបន្លែ និងអង្ករមួយក្តាប់ដែលបានលាក់ទុក។

មួយរយៈក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំឲ្យទៅភូមិអង្គប្រាង្គ ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវវិញ។ ខ្ញុំនៅ កងកុមារ និងត្រូវធ្វើការងារ ដូចជាដេញចាប រើសអាចម៍គោធ្វើជី និងកាប់ទន្ទ្រានខែត្រ។ ដោយសារមិនមានអាហារសម្រាប់ហូបចុកគ្រប់គ្រាន់បណ្តាលឲ្យខ្លួនខ្ញុំហើម។ ប្រធានរោងបាយចិត្តអាក្រក់ណាស់។ ខ្ញុំនិងក្មេងៗឯទៀតបានទៅសុំបាយពីប្រធានរោងបាយ ប៉ុន្តែប្រធានរោងបាយមិនឲ្យបាយខ្ញុំហូបទេ ថែមទាំងយកចានដែលខ្ញុំ និងក្មេងៗកាន់យកទៅបោកចោលទៀត។

ពេលខ្ញុំមានវ័យជំទង់ ខ្មែរក្រហមចល័តខ្ញុំឲ្យទៅជីកប្រឡាយនៅភ្នំស្រមោច ស្ថិតនៅភូមិអង្គខ្លាយ ឃុំដានគោម ស្រុកអង្គរជ័យ ខេត្តកំពត។ អំឡុងពេលធ្វើការងារខ្ញុំឃើញមនុស្សប្រហែលជាមួយគ្រួសារត្រូវបានឈ្លបខ្មែរក្រហមចង និងឲ្យដើរជាជួរ ដោយមានឈ្លបតូចៗដើរនៅពីមុខ និងពីក្រោយ និងពីចំហៀង។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមនៅស្តុក ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត។ ទ័ពវៀតណាមបានជម្លៀសប្រជាជនមកទីកន្លែងសុវត្ថិភាព និងឲ្យមករស់នៅភូមិរៀងៗខ្លួនវិញ ចំណែកខ្មែរក្រហមបានរត់គេចខ្លួនទៅលើភ្នំ។

ក្រោយរំដោះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បងប្រុសរបស់ខ្ញុំបានស្លាប់ម្នាក់ ដោយខ្មែរក្រហមយកទៅវាយចោល។ ចំណែកខ្ញុំ និងឪពុកម្តាយដែលនៅរស់ជីវិត បានមករស់នៅភូមិកំណើតរបស់ខ្លួនវិញ និងប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ យិនដិន ដែលជាអ្នកភូមិជាមួយគ្នា និងមានកូនចំនួន៣នាក់។

សាំង អូន ទទួលប្រអប់អនុស្សាវរីយ៍ពី ង៉ាន់ វីន អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## នៅឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

***មេក ទិន, សួត វិចិត្រ និង ហ៊ាន ពិសី***

ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចុះធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារនៅក្នុងភូមិចំនួន២គឺ ភូមិប្រោក និងភូមិអូរជី ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ កិច្ចការនេះទទួលបានការឯកភាព និងសម្របសម្រួលពីអាជ្ញាធរមូលដ្ឋានឃុំផ្អាវ ដើម្បីចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០នាក់ ក្នុងនោះមានស្រី៤នាក់។ ខាងក្រោមគឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតដែលបានឆ្លងកាត់របបខ្មែរក្រហម៖

### មិុល ឈួន ៖ និរសារ



មិុល ឈួន នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មិុល ឈួន ភេទប្រុស អាយុ៦១ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បច្ចុប្បន្ន មិុល ឈួន រស់នៅភូមិប្រោក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ មិុល ឈួន និយាយថា «សង្គ្រាមធ្វើឲ្យខ្ញុំមិនបានរៀនសូត្រ។ ដោយសារពេលនោះមានការធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុឲ្យចុះចេញពីតំណែង ជាហេតុធ្វើឲ្យប្រជាជនខ្មែរជាច្រើនដែលគាំទ្រនិងស្រឡាញ់ព្រះអង្គ បានចូលរួមតស៊ូក្នុងព្រៃម៉ាគី តាមរយៈការឃោសនារបស់សម្តេច។ នៅអាយុ១៨ឆ្នាំ ខ្ញុំ ចូលហាត់ធ្វើជាកងទ័ពនៅកំពង់ថ្មជិតប្រាសាទសម្បូរព្រៃគុក។ ប្រហែលពីរខែក្រោយមកខ្ញុំត្រូវបានបញ្ជូនទៅខ្សែត្រៀមដើម្បីត្រៀមប្រយុទ្ធ។ ឆ្នាំ១៩៧៥ ខ្មែរក្រហមវាយដាច់ភ្នំពេញ ខ្ញុំមកធ្វើជានីរសារឲ្យតាប្រាន។ តាប្រានមានតួនាទីជាគណៈស្រុកមកពីភូមិភាគនិរតី។ ការងាររបស់ខ្ញុំនៅពេលនោះគឺធ្វើជាអ្នករត់សំបុត្រ ដោយជិះសេះ និងមានកាំភ្លើងមួយដើមសម្រាប់ការពារខ្លួន។ ខ្ញុំមិនដែលដឹងអំពីខ្លឹមសារនៅខាងក្នុងសំបុត្រទេ ដោយសារមានការងារវេចខ្ចប់ស្រោមសំបុត្រយ៉ាងជិតល្អ។ ពេលទំនេរពីការរត់សំបុត្រខ្ញុំធ្វើជាអ្នកដឹកស្បៀងអង្ករពីឃ្លាំងនៅក្នុងស្រុកដាក់តាមសហករណ៍។ យើងមានក្រុមដឹកជញ្ជូនដោយរទេះសេះ មួយសហករណ៍ទទួលបាន អង្ករ ១០បាវ។ ការរស់នៅជាមួយ តាប្រាន យើងទទួលបានបាយ ហូបគ្រាប់គ្រាន់មិនដែល ហូបបបរទេ។

នៅឆ្នាំ១៩៧៦ ខ្ញុំចូលធ្វើទ័ពហើយខ្ញុំត្រូវបានខ្មែរ

ក្រហមបញ្ជូនឲ្យទៅឈរជើងនៅខាងភូមិភាគបូព៌ា ក្នុងស្រុកមេមត់ ដែលមាន សុខ សារឿន គឺជាប្រធាន។ ការរស់នៅទីនោះភាគច្រើនមិនសូវបានចូលវាយនៅសមរភូមិមុខទេ ខ្ញុំច្រើនតែធ្វើជាអ្នកយកបាយឲ្យកងទ័ពដែលកំពុងប្រយុទ្ធនៅសមរភូមិមុខ។ យើងអាចដឹកជញ្ជូនបាយទៅឲ្យកងទ័ពបានតែពេលយប់ប៉ុណ្ណោះ ទើបសត្រូវមើលយើងមិនឃើញ។ បាយនៅជំនាន់សង្គ្រាមខុសពីបាយធម្មតា។ ដោយសារបាយដែលត្រូវយកទៅឲ្យកងទ័ពនៅតាមលេណដ្ឋាន គឺត្រូវប្រួបាច់បាយនោះឲ្យប្រូលគ្នាស្អិតរមួត។ ក្នុងមួយកញ្ចប់មានទាំងបាយ និងម្ហូប រួមជាមួយទឹកដាក់ក្នុងបំពង់ដេកា ដែលអាចហូបបានបីនាក់និងពីរពេល សម្រាប់ពេលយប់និងព្រឹក។ នៅចុងឆ្នាំ១៩៧៦មានការបាត់ខ្លួនច្រើន ជាពិសេសកម្មាភិបាលថ្នាក់លើ។ ឲ្យតែមានការកោះហៅប្រជុំ គឺដឹងតែបាត់ខ្លួនដោយគ្មានមូលហេតុ។ បន្ទាប់មកជំនួសដោយកម្មាភិបាលភូមិភាគនិរតី៨០១ មកដឹកនាំបន្ត។ ខ្ញុំនៅតស៊ូរហូតដល់ឆ្នាំ១៩៧៩ ពេលវៀតណាមចូលមកយើងក៏បែកខ្ញែកគ្នា។ ខ្ញុំភៀសខ្លួនមកខាងភ្នំឪរ៉ាល់ ក្រោយមកបន្តចល័តរហូតមកស្រុកត្រពាំងប្រាសាទ។ មកដល់ត្រពាំងប្រាសាទខេត្តឧត្ដរមានជ័យបានមួយសប្ដាហ៍ យើងគ្មានអីហូបក្រៅពីគល់ចេក និងគល់ល្ហុង។ ក្រោយមក តាម៉ុក បញ្ជូនឲ្យខ្ញុំនិងកងកម្លាំងផ្សេងទៀតឡើងទៅភ្នំដងរែក។ យើងធ្វើដំណើរមកដល់ច្រកណាំយឺនប្រទេសថៃ ហើយក៏រស់នៅទីនោះ។ គ្រាន់តែមកដល់ច្រកណាំយឺន ថៃដកកាំភ្លើងយើងគ្រប់គ្នា។ ពីរថ្ងៃបន្ទាប់ខ្ញុំឃើញឡានដឹកស្បៀង ដែលមានអង្ករដំណើបនិងប៊ីចេងយកមកឲ្យយើងហូប។ លុះឆ្នាំ១៩៨២ តាម៉ុកឲ្យយើងទៅនៅជាមួយ តាពក នៅច្រក១០០១ ដែលមានកម្លាំងចំនួន១៥០០នាក់។ ប៉ុន្តែដោយសារកងទ័ពមួយចំនួនធំមានប្រពន្ធកូន ដូច្នេះនាំគ្នារត់ចូលទៅធ្វើកងទ័ពប៉ារ៉ាអស់ចំនួន៥០០នាក់។ ក្រោយមកខ្មែរក្រហមដកខ្ញុំឲ្យរៀនគួលេខនៅច្រក១០០៣។ ការរៀនគួលេខ គឺខ្មែរក្រហមយកលេខជំនួសដោយអក្សរ ប្រើលេខសម្រាប់សរសេរសារ។ ដូច្នេះការបញ្ជូនសារមួយគឺសម្ងាត់ណាស់ ប្រសិនបើអង្គការគិតថារឿងសម្ងាត់បែកធ្លាយគឺមានតែអ្នកបកសារគួលេខនឹងឯងគឺជាអ្នកក្បត់។ មិនយូរប៉ុន្មានខ្ញុំត្រូវដកឲ្យធ្វើនៅកង៩១៦ បានប៉ុន្មានថ្ងៃក៏វិលត្រឡប់មករៀនគួលេខម្ដងទៀត។ យូរៗទៅខ្ញុំហាក់នឿយនឹងការរៀនគួលេខ ខ្ញុំសុំប្ដូរមកកាន់កាំភ្លើងចូលសមរភូមិវិញ។ ដល់ឆ្នាំ១៩៨៨ ខ្ញុំរៀបការប្រពន្ធ និងមានកូន។

នៅឆ្នាំ១៩៧៩ ប៉ុល ពត រៀបចំបង្កើតគណៈកម្មាធិការ១៩ថ្មី។ ដោយមេដឹកនាំចាស់ៗដូចជា ប៉ុល ពត, តាម៉ុក, ខៀវ សំផន, ដែលចូលនិវត្តន៍ ជំនួសដោយអ្នកជំនាន់ថ្មីដូចជា តាសាន តាសារឿន តាឌុន តាញាន។ ការរៀបចំនេះត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត។ លទ្ធផលសន្លឹកឆ្នោត តាសាន ទទួលបានសំឡេងច្រើនជាងគេ។ ប៉ុន្តែតាសាន មិនព្រមធ្វើក៏ផ្ទេរឲ្យទៅតាសារឿន ឡើងធ្វើជាអគ្គមេបញ្ជាការនៅក្នុងតំបន់អន្លង់វែង ព្រោះតាសារឿន ធ្លាប់ជាមេរបស់តាសាន។ ប៉ុន្តែ តាម៉ុក ចង់ឲ្យ តាឌុន គឺជាមនុស្សជិតនិតឡើងគ្រប់គ្រងវិញ។ កាលនោះ ប៉ុលពត គិតថាបើអាច តាម៉ុក ទៅចាប់កម្លាំងខាងប៉ៃលិនដែលបម្រុងផ្ដាច់ខ្លួនបាន នោះ ប៉ុល ពត នឹងធ្វើតាមអ្វីដែល តាម៉ុក ចង់ឲ្យ តាឌុន ឡើងជាអ្នកដឹកនាំបន្ត។ ប៉ុន្តែតាម៉ុក ពុំអាចយកឈ្នះបានហើយថែមទាំងត្រូវកម្លាំងខាងប៉ៃលិនដេញ តាម៉ុក រត់ត្រឡប់មកវិញទៀត។ ក្នុងអំឡុងពេលនោះ ប៉ុល ពត ចង់ជ្រើសរើស សុន សេនឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រី ដែលជាមូលហេតុធ្វើឲ្យ តាសារឿន និង សុន សេន មានទំនាស់ជាមួយនឹងគ្នា។ ក្រោយមក ប៉ុល ពត ហាក់គិតមិនដល់ក៏បញ្ជូឲ្យ តាសារឿន ឡើងមកយក សុន សេន ឲ្យមកនៅជាមួយ។ ប៉ុន្តែតាសារឿន ពុំបាននាំ សុន សេន មក តែបែរជាទៅបាញ់សម្លាប់ សុន សេន និងគ្រួសារស្លាប់អស់។ ទាំងនេះខ្ញុំគិតថាជាការដណ្ដើមអំណាចគ្នាទើបធ្វើឲ្យខាងក្នុងមានការបែកបាក់គ្នា។ លុះឆ្នាំ១៩៩៨ ខ្ញុំហាក់នឿយណាយនឹងសង្គ្រាម ខ្ញុំសម្រេចចិត្តផ្ដាច់ខ្លួនតាំងពីពេលនោះមក»។

## គុន ឈិន ៖ យោធា



គុន ឈិន នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្ទាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គុន ឈិន ភេទប្រុស អាយុ៦២ឆ្នាំ មានស្រុកកំណើតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ គុន ឈិន សព្វថ្ងៃរស់នៅក្នុងភូមិប្រោក ឃុំផ្ទាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ គុន ឈិន និយាយរៀបរាប់អំពីការតស៊ូរបស់ខ្លួននៅជំនាន់ខ្មែរក្រហមថា ខ្ញុំរស់នៅក្នុងគ្រួសារដែលមានជីវភាពក្រីក្រ ឪពុកម្តាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការសម្រាប់ទ្រទ្រង់ជីវិត។ កាលពីក្មេងខ្ញុំមិនបានរៀនសូត្រទេដោយសារតែជីវភាពគ្រួសារខ្វះខាត។ ការរស់នៅក្នុងភូមិ ខ្ញុំនៅជំនាន់នោះមិនមានការរីកវរទេ ប្រជាជនមានការរស់នៅប្រកបដោយសុខសន្តិភាព។ នៅសម័យសង្គមរាស្ត្រនិយម ខ្ញុំនៅវ័យកុមារមិនទាន់ដឹងរឿងរ៉ាវអ្វីច្បាស់ទេ ប៉ុន្តែខ្ញុំបានដឹងថាជំនាន់នោះ សម្តេច ព្រះនរោត្តម សីហនុ តែងតែជិះយន្តហោះមកទម្លាក់ក្រណាត់នៅក្នុងស្រុកក្រឡាញ់។ រហូតដល់ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ នៅក្នុងភូមិខ្ញុំចាប់ផ្តើមមានការទម្លាក់គ្រាប់បែកធ្វើឲ្យប្រជាជនបាត់បង់ទ្រព្យសម្បត្តិ និងខូចខាតសម្ភារអស់ជាច្រើន។ នៅចុងឆ្នាំ១៩៧៣ ខ្ញុំចូលធ្វើជាកងទ័ព។ កាលខ្ញុំចូលជាកងទ័ពខ្ញុំមានអាយុ១៥ឆ្នាំ ដោយសារតែខ្ញុំនៅតូចពេក អង្គការមិនសូវបង្ហាត់បង្រៀនច្រើនដូចគេធំៗទេ អង្គការបង្ហាត់បន្តិចបន្តួចពីរបៀបធ្វើសង្គ្រាម។ បន្ទាប់ពីខ្ញុំបានហាត់រៀនមួយរយៈហើយ ខ្ញុំក៏ត្រូវបានបញ្ជូនឲ្យទៅវាយនៅសមរភូមិមុខៗ កងទ័ពខ្ញុំវាយឆ្ពោះចូលទៅទីក្រុងភ្នំពេញ ការវាយជាមួយកងទ័ព លន់ នល់ បានធ្វើឲ្យកងទ័ពជាច្រើនត្រូវស្លាប់ក្រោមភ្លើងសង្គ្រាម។ ខ្ញុំបន្តវាយទៅមុខរហូតដល់វាយបែកភ្នំពេញនៅឆ្នាំ១៩៧៥ កងទ័ពទាំងអស់មានចិត្តសប្បាយរីករាយជាខ្លាំងពេលទទួលជ័យជម្នះ។ បន្ទាប់ពីទទួលជ័យជម្នះ ខ្ញុំបន្តឈរជើងនៅភ្នំពេញរយៈពេលកន្លះខែទើបខាងថ្នាក់លើបញ្ជូនកងពលខ្ញុំ៩២០ និងកងពល៨០១ ទៅខេត្តក្រចេះ។ ការធ្វើដំណើរទៅកាន់ខេត្តក្រចេះកងទ័ពទាំងអស់ត្រូវធ្វើដំណើរដោយជិះកាណូត។ កងទ័ពទាំងអស់ធ្វើដំណើរអស់រយៈពេលមួយថ្ងៃមួយយប់ទើបទៅដល់ខេត្តក្រចេះ។ បន្ទាប់ពីទៅដល់ទីនោះហើយ កងទ័ពបន្តដំណើរទៅខេត្តមណ្ឌលគិរី។ កាលខ្ញុំឈរជើងនៅមណ្ឌលគិរី អង្គការចាត់តាំងខ្ញុំរួមទាំងកងទ័ពទាំងអស់ធ្វើស្រែចម្ការប្រមូលផលទុកសម្រាប់ទ្រទ្រង់ជីវភាពកងទ័ពដោយខ្លួនឯង និងនៅការពារព្រំដែន។ ខ្ញុំរស់នៅខេត្តមណ្ឌលគិរី រហូតដល់ឆ្នាំ១៩៧៩ វៀតណាមបានវាយចូលមកដល់ កងទ័ពទាំងអស់បានរត់ចូលព្រៃទាំងគ្មានស្បៀងអាហារ។ កងទ័ពខ្ញុំបានរស់នៅក្នុងព្រៃរង់ចាំអង្គការទាក់ទងមកអស់មួយរយៈពេល ទើបដឹងដំណឹងថាអង្គការទាំងអស់បានទៅរស់នៅលើភ្នំដងរែក។ បន្ទាប់ពីមានការទំនាក់ទំនងគ្នាបានហើយ ខ្ញុំ និងកងទ័ពដទៃទៀតធ្វើដំណើរឆ្ពោះទៅកាន់ភ្នំដងរែក។ ពេលធ្វើដំណើរមកដល់ភ្នំដងរែកកងទ័ពទាំងអស់ចាប់ផ្តើមមានអាហារហូបចុកគ្រប់គ្រាន់ លែងមានការខ្វះខាតអាហារដូចពេលរស់នៅក្នុងព្រៃទៀតហើយ។

## ប្រាក់ ថា៖ យោធា

ប្រាក់ ថា ភេទប្រុស អាយុ៧៦ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិស្វាយទាប ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ ប្រាក់ ថា សព្វថ្ងៃរស់នៅក្នុងភូមិប្រោក ឃុំផ្ទាវ ស្រុកត្រពាំងប្រាសាទ។ ប្រាក់ ថា ឪពុក



ប្រាក់ ថា នៅផ្ទះរបស់គាត់ពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពីជីវិតតស៊ូរបស់ខ្លួននៅក្នុងសម័យខ្មែរក្រហមថា ខ្ញុំគឺជាកូនកំព្រាឪពុកម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីនៅកុមារ។ ខ្ញុំមានបងប្អូនបង្កើតចំនួន២នាក់ ប៉ុន្តែបងរបស់ខ្ញុំស្លាប់បាត់បង់ជីវិតទៅហើយ។ សព្វថ្ងៃនេះ ខ្ញុំគ្មានបងប្អូនបុកូនចៅទេ។ កាលពីជំនាន់សម្តេចព្រះនរោត្តម សីហនុ ខ្ញុំដើរតាម ឡានដុតខសធ្វើដំណើរពីខាងស្វាយទៀបទៅខេត្តកំពង់ចាម។ ជំនាន់នោះប្រជាជនរស់នៅតាមដងផ្លូវមិនហ៊ានធ្វើផ្ទះនៅជិតផ្លូវជាតិទេ ព្រោះធំក្លិនដ្យែងចេញពីឡានដុតខស។ កាលពីក្មេងខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ពីសង្គម។ បន្ទាប់ពីខ្ញុំឈប់រៀនក្នុងឆ្នាំ១៩៦១ ខ្ញុំសម្រេចចិត្តទៅបួសរៀននៅវត្តតាំងគោក។ ខ្ញុំបួសជាព្រះសង្ឃអស់រយៈពេល៦ឆ្នាំ។ កាលនោះខ្ញុំសិក្សារៀនសូត្រភាសាបាលី ព្រះធម៌ និងរៀនអនុវត្តខាងបង្រៀនសិស្សក្មេងៗ។ រហូតដល់ឆ្នាំ១៩៦៨ នៅក្នុងស្រុកភូមិខ្ញុំចាប់ផ្តើមមានការកេណ្ឌប្រជាជនទៅធ្វើជាកងទ័ព។ ខ្ញុំចូលធ្វើកងទ័ពរំដោះចាប់តាំងពីពេលនោះមក។ បន្ទាប់ពីខ្ញុំចូលធ្វើជាកងទ័ពហើយដល់ឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ពីតំណែង។ ខ្ញុំរួមទាំងកងកម្លាំងជាច្រើននាក់ទៀតត្រូវបានបញ្ជូនទៅវាយជាមួយកងទ័ព លន់ នល់។

នៅចន្លោះឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧៥ កងកម្លាំងខ្ញុំមានគោលដៅវាយរំដោះយកទីក្រុងភ្នំពេញ។ កាលនោះខ្ញុំវាយដំបូងនៅម្តុំកប់ស្រូវ ហើយបន្តវាយចូលទួលគោក។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលជ័យជម្នះ។ នៅពេលខ្ញុំចូលដល់ភ្នំពេញ ខ្ញុំឃើញប្រជាជនត្រូវបានកងកម្លាំងមួយក្រុមជម្លៀសចេញពីក្រុងភ្នំពេញទៅទីជនបទ។ ទិដ្ឋភាពការជម្លៀសប្រជាជនកាលនោះ អ្នកខ្លះជិះឡាន អ្នកខ្លះជិះរទេះ ឯខ្លះទៀតដើរទូលរែកកូនចៅ សម្ភារដែលខ្លួនយកទៅតាមដូចជាអង្ករ អំបិល ឆ្នាំងចាន។ បន្ទាប់មក ខ្ញុំនៅឈរជើងមួយរយៈនៅក្នុងទីក្រុងភ្នំពេញ។ ការងារដែលខ្ញុំធ្វើគឺដើរបោសសម្អាតផ្ទះសម្បែងប្រជាជនដែលជម្លៀសចេញពីភ្នំពេញ។ កងទ័ពទាំងអស់ទទួលសម្លៀកបំពាក់តែពីរសម្រាប់ និងស្បែកជើងមួយគូតែប៉ុណ្ណោះ ដោយមានពាក្យស្លោកមួយឃ្លានិយាយថា «កម្មសិទ្ធិសមរម្យ»។ ខ្ញុំនៅបោសសម្អាតផ្ទះសម្បែងនៅភ្នំពេញរហូតដល់ថ្នាក់លើបញ្ជូនឲ្យទៅនៅខេត្តមណ្ឌលគិរី។ ការធ្វើដំណើរទៅមណ្ឌលគិរី មុនដំបូងកងទ័ពទាំងអស់ត្រូវជិះទូកចេញពីភ្នំពេញទៅ ឈប់សម្រាកនៅខេត្តក្រចេះមួយយប់ ទើបធ្វើដំណើរដោយថ្មើរជើងឆ្ពោះទៅខេត្តមណ្ឌលគិរីបន្ត។ ខ្ញុំរួមទាំងកងទ័ពជាច្រើននាក់ចំណាយពេលដើរអស់រយៈពេលមួយសប្តាហ៍ទើបទៅដល់ស្រុកកោះញែក។ នៅទីនោះ អង្គការឲ្យខ្ញុំធ្វើស្រែ ចម្ការ ដាំដំណាំ ជាក្រុមកងទ័ព។ ការធ្វើស្រែនៅជំនាន់នោះ គឺយើងធ្វើនឹងចបកាប់ ទម្រាំតែធ្វើស្រូវរួចមួយវស្សាៗកងទ័ពហត់នឿយណាស់។ ផលស្រូវដែលទទួលបានគឺមានចំនួនច្រើន ដោយសារតែដីល្អធ្វើស្រូវបានផលច្រើន។ បន្ទាប់មកទៀត ខ្ញុំត្រូវបញ្ជូនឲ្យឈរជើងការពារព្រំដែននៅអូរដាក់ដាំ។ អូរដាក់ដាំ ទឹកធ្លាក់ទៅដល់ទន្លេស្រែពក។ ជំនាន់នោះ វៀតណាមនៅម្ខាងអូរ ហើយអូរចែកទឹកពាក់កណ្តាលវៀតណាម ពាក់កណ្តាលទៀតខ្មែរ។ ក្រៅពីការពារព្រំដែនកងទ័ព ខ្ញុំធ្វើស្រែធ្វើស្រូវប្រមូលផលទុកសម្រាប់ស្បៀងកងទ័ព។ នៅឆ្នាំ១៩៧៧ ខ្ញុំរៀបការ ដោយពេលនោះ

អង្គការរៀបការឲ្យចំនួន៦៣គូ នៅសាលាកងពល ក្នុងស្រុកកោះញែក។ បន្ទាប់ពីរៀបការហើយ ខ្ញុំបន្តនៅឈរជើងនៅកោះញែករហូតដល់ឆ្នាំ ១៩៧៩ វៀតណាមវាយចូលទើបជម្លៀសមកនៅ ជំរំអូរគ្រាវលើភ្នំដងរែក។ ខ្ញុំមកដល់ភ្នំដងរែកចាប់ផ្តើមរស់នៅជាប្រជាជនធម្មតា រហូតដល់ធ្វើសមាហរណកម្មនៅអន្លង់វែងទើបខ្ញុំចុះមករស់នៅក្នុងភូមិប្រោកនេះរហូតដល់សព្វថ្ងៃ។

នៅឆ្នាំ១៩៩៨ ខ្ញុំចូលបម្រើនៅឃុំផ្អាវ ក្នុងស្រុកត្រពាំងប្រាសាទ។ ខ្ញុំបានដើររៃអង្គាសប្រាក់ប្រជាជនបន្តិចបន្តួចរហូតដល់បានឈូសឆាយធ្វើផ្លូវដើរនៅក្នុងភូមិប្រោកនេះ បានមកដល់សព្វថ្ងៃ រួមទាំងវត្តនិងសាលារៀន។

## ឆេង ភាង៖ យោធា



ឆេង ភាង នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆេង ភាង ភេទប្រុស អាយុ៦៩ឆ្នាំ មានទីកន្លែងកំណើតនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ឆេង ភាង រស់នៅភូមិប្រោក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ឆេង ភាង បានចែករំលែករឿងរ៉ាវថា «ឆ្នាំ១៩៧២ ខ្ញុំចូលរួមតស៊ូជាមួយខ្មែរក្រហម។ កាលណោះខ្ញុំបានចូលឈ្លបនៅក្នុងសន្តាត់។ ប៉ុន្តែក្រោយមកខ្ញុំត្រូវការហ្វឹកហាត់អំពីយុទ្ធសាស្ត្រធ្វើសង្គ្រាម និងរៀនពីនយោបាយរបស់ខ្មែរក្រហម។ ខ្មែរក្រហមបណ្តុះស្មារតីយើងយ៉ាងណាឲ្យយើងរឹងមាំ កុំតក់ស្លុត ហើយស្គាល់សត្រូវឲ្យបានច្បាស់។ ក្រៅពីនោះខ្មែរក្រហមបំផុសចលនាក្នុងគោលបំណងអ្វីខ្ញុំពុំបានដឹងទេ នោះជាក្បួននយោបាយរបស់ខ្មែរក្រហម ខ្ញុំដឹងតែម៉្យាងចូលរួមតស៊ូដើម្បីទាមទារយកសិទ្ធិអំណាចជូនព្រះមហាក្សត្រឲ្យបានវិញ។ បីខែបន្ទាប់ពីខ្ញុំហ្វឹកហាត់ចេះហើយ ខ្ញុំត្រូវបញ្ជូនឲ្យមកធ្វើជាទ័ពតំបន់៣១ ក្រោមការគ្រប់គ្រងរបស់ តាពក ដែលមានកម្លាំងក្នុងមួយវរៈ៣០០ ទៅ៤០០នាក់។ បន្ទាប់មកខ្ញុំឡើងធ្វើជាប្រធានកងអនុសេនាតូចលេខ៧៣៦ ដឹកនាំកម្លាំង៣០នាក់។ លុះចុងឆ្នាំ១៩៧៤ ខ្ញុំមកឈរជើងនៅតាមបណ្តោយផ្លូវទៅភ្នំបាសិទ្ធ។ កងទ័ពខ្មែរក្រហមចាប់ផ្តើមវាយកម្លាំងពេញទាំងអស់នៅតាមទីជនបទ។ ក្រោយមកទើបខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ ខ្ញុំដឹកនាំកម្លាំងមកដល់ទួលគោកនៅម៉ោង៣ភ្លឺ។ ចំណែកកងទ័ពពិសេសបញ្ជូនទៅខាងផ្សារថ្មី។ បន្ទាប់ពីវាយដាច់ភ្នំពេញ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងអស់គ្មានសល់។ ខ្ញុំបានឃើញទិដ្ឋភាពប្រជាជនជាច្រើនដែលត្រូវជម្លៀសចេញទាំងបង្ខំ អ្នកខ្លះរែក អ្នកខ្លះទូលអីវ៉ាន់ នាំកូនចៅចាកចេញទាំងលំបាក។ កាលណោះយើងជឿតាមអ្វីដែលខ្មែរក្រហមប្រកាសដែរ ព្រោះយើងខ្លាចមានការទម្លាក់គ្រាប់បែកធ្វើឲ្យប្រជាជនស្លាប់ និងខាតបង់ទ្រព្យសម្បត្តិកាន់តែច្រើនថែមទៀត។ ក្រោយមកកម្លាំងទ័ពខាងខ្ញុំទទួលខុសត្រូវបោសសម្អាតនៅតំបន់ទួលគោក ដោយធ្វើការប្រមូល ឡានម៉ូតូនិងសម្ភារផ្សេងៗដាក់មួយកន្លែង។ ខ្ញុំនៅភ្នំពេញបានកន្លះខែ ខ្ញុំត្រូវផ្លាស់ចេញមកខាងខេត្តមណ្ឌលគិរី និងឈរជើងការពារព្រំដែននៅទីនោះ។ យើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល៩២០ ដែលមាន ឈិន គឺជាប្រធាន។ អំឡុងពេលឈរជើងនៅមណ្ឌលគិរីយើងក៏មានជម្លោះជាមួយវៀតណាមជាញឹកញាប់ ដោយសារតែវៀតណាមចូលមកទឹកដីខ្មែរ។ ក្រោយមកទៀតពេល

សភាពការណ៍ស្ងប់ស្ងាត់ហើយ កងទ័ពចាប់ផ្តើមផ្លាស់គ្នាមួយខែមួយក្រុមយាមល្បាត មួយក្រុមមកធ្វើស្រែ សម្រាប់ផ្គត់ផ្គង់នៅក្នុងកងអង្គភាព។ នៅឆ្នាំ១៩៧៧ ពេលនោះសភាពការណ៍ចាប់ផ្តើមប្រែប្រួលម្តងទៀតដោយសារតែ តាឈិន ត្រូវខ្មែរក្រហមចោទថាក្បត់ ហើយជំនួសដោយតាសាន ហៅតា០៦វិញ។ ពេលនោះ ខ្មែរក្រហមចាប់ផ្តើមសង្ស័យ និងធ្វើវិសុទ្ធកម្មរកអ្នកក្បត់ ចោទគ្នាជាពិសេសអង្គការថ្នាក់លើដោយមិនដឹងថាយកទៅខាងណាខ្លះទេ។ ដល់ឆ្នាំ១៩៧៩ ខ្ញុំមកខាងភ្នំដងរែក ដោយខ្ញុំប្តូរមកធ្វើជាអ្នកដឹកជញ្ជូន។ កាលណោះខ្ញុំដឹកចម្រុះដូចជាដឹកកងទ័ព ដឹកគ្រាប់ ប៉ុន្តែជាទូទៅខ្ញុំដឹកស្បៀងដាក់តាមអង្គភាព។ ខ្ញុំនៅបន្តដឹកជញ្ជូនរហូតដល់ពេលដែលអ៊ុនតាក់ចូលទើបខ្ញុំឈប់ដឹកជញ្ជូន។ លុះឆ្នាំ១៩៩៨ ពេលដែលខ្មែរក្រហម ធ្វើសមាហរណកម្មជាមួយនឹងរដ្ឋាភិបាលខ្ញុំមករស់នៅក្នុងភូមិនេះរហូតដល់ពេលបច្ចុប្បន្ន។

## សៅ ហៀង ៖ នារីដឹកជញ្ជូន



សៅ ហៀង នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សៅ ហៀង ភេទស្រី អាយុ៧៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុង ឃុំគោកធ្លក ស្រុកជីក្រែង ខេត្តសៀមរាប។ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ សៅ ហៀង រៀបរាប់ពីបទពិសោធន៍ថា «កាលជំនាន់សង្គមរាស្ត្រនិយម ខ្ញុំបានរៀនសូត្រតិចតួចដោយសារជីវភាពក្រលំបាក។ ឪពុករបស់ខ្ញុំធ្លាប់បម្រើការជាទាហានខ្មែរឥស្សរៈ។ លុះដល់ឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ នៅពេលនោះក្នុងភូមិរបស់ខ្ញុំមិនទាន់ជួបប្រទះនឹងការវាយប្រទាញប្រទង់គ្នានៅឡើយទេ។ ប្រជាជននៅក្នុងភូមិនាំគ្នាត្រៀមលក្ខណៈ ខ្លះជីកត្រង់សេ ខ្លះត្រៀមចូលព្រៃដើម្បីគេចក្រែងលោមានការទម្លាក់គ្រាប់បែក។ ប៉ុន្តែទោះជាយ៉ាងណា ភូមិរបស់ខ្ញុំមិនធ្លាប់ទទួលរងការទម្លាប់គ្រាប់បែកទេ ដោយសារប្រជាជនមានភាពស្អាតស្អំ និងមិនមានលាក់ ឬជ្រំគំនិតជាមួយចារកម្ម។ ជាទូទៅ ប្រសិនបើភូមិណាមួយមានគិញចារម្មភូមិនោះនឹងទទួលរងការទម្លាក់គ្រាប់បែកពី លន់ នល់។ ក្រោយមក សម្តេច ព្រះនរោត្តម សីហនុ បានប្រកាសឲ្យប្រជាជនចូលទៅក្នុងព្រៃម៉ាគី ដើម្បីតស៊ូដណ្តើមអំណាចឲ្យព្រះអង្គវិញ។ យុវជនជាពិសេស បុរសៗបាននាំគ្នាចូលតស៊ូជាមួយនឹងកម្លាំងខ្មែរក្រហមយ៉ាងច្រើនក្នុងការវាយប្រយុទ្ធជាមួយទាហាន លន់ នល់។ ខ្ញុំបានចូលរួមទៅក្នុងចលនាខ្មែរក្រហមនៅអាយុប្រហែល១៣ឆ្នាំ ដោយធ្វើការក្នុងកងសែងអ្នករបួសនៅក្នុងអង្គភាព យាយថាន តាមរយៈមេភូមិរបស់ខ្ញុំ។ ដំណាក់កាលដំបូងខ្មែរក្រហមបានបង្ហាត់បង្រៀន និងបំពាក់បំប៉នយើងពីរបៀបកងទ័ព ហើយជំរុញឲ្យយើងខិតខំតស៊ូដើម្បីបម្រើប្រទេសជាតិ។ ការងារសែងអ្នករបួសមានភាពមមាញឹកណាស់ ដោយយើងត្រូវធ្វើការទាំងថ្ងៃទាំងយប់ រាល់ពេលដែលមានអ្នករបួស ឬមេអង្គភាពត្រូវការយើង។ យើងសែងអ្នករបួសជាអាទិភាពទីមួយ ចំណែកឯអ្នកស្លាប់ជាអាទិភាពទីពីរ។ នៅក្នុងអ្នកស្លាប់ ឬអ្នករបួសម្នាក់ យើងសែងគ្នាពីរនាក់ ហើយកំណត់គោលដៅត្រង់ចំណុចណាមួយ ដើម្បីបែងចែកកម្លាំងសែងបន្តទៅកាន់សមរភូមិក្រោយ។ ការងារសែងអ្នករបួសបានជួបនូវការលំបាក ដោយ

សារយើងត្រូវធ្វើដំណើរទាំងយប់អាធ្រាត្រ ភ្លៀងផ្គរ និងប្រឈមនឹងគ្រាប់ផ្លោង និងការបាញ់ប្រហារគ្នា។ កងកម្លាំងមួយចំនួនបានស្លាប់នៅតាមសមរភូមិអំឡុងពេលសែងអ្នករបួស ឬសាកសពចេញពីសមរភូមិមុខ។ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលជ័យជម្នះ អង្គភាពសែងអ្នករបួសរបស់ខ្ញុំត្រូវបានផ្ទាក់លើបញ្ជូនទៅកាន់ខណ្ឌទួលគោក រដ្ឋធានីភ្នំពេញ និងប្រមែរប្រមូលរបស់របរនៅតាមផ្ទះប្រជាជន និងរៀបចំរោងចក្រកាត់ដេរ និងតម្បាញឡើងវិញ។ ក្រោយមក អង្គភាពរបស់ខ្ញុំក៏ត្រូវបានមេខ្មែរក្រហមបញ្ជូនទៅកាន់ខេត្តមណ្ឌលគិរី។

## មៀន ជាតី ៖ កងទ័ពខ្មែរក្រហម



មៀន ជាតី នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មៀន ជាតី ភេទប្រុស អាយុ៧១ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បច្ចុប្បន្ន មៀន ជាតី រស់នៅភូមិប្រោក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ មៀន ជាតី ចែករំលែករឿងរ៉ាវថា «បងប្អូនខ្ញុំចំនួន១២នាក់ ស្រីតែម្នាក់គត់។ ខ្ញុំបួសរៀននៅក្នុងវត្តផ្តៀក ក្នុងខេត្តកំពង់ធំ បានចំនួន៧វស្សា។ បន្ទាប់ពីរៀនសូត្របានជ្រៅជ្រះ ខ្ញុំត្រូវបានជ្រើសរើសធ្វើជាគ្រូបង្រៀនសូត្រឆ្មេងនៅក្នុងវត្ត។ នៅពេលខ្ញុំមានអាយុ២០ឆ្នាំ មានតែខ្ញុំម្នាក់ប៉ុណ្ណោះដែលចាកចេញពីផ្ទះ ចំណែកបងខ្ញុំនិងប្អូនៗរស់នៅជាមួយឪពុកម្តាយ។ ពេលបែកទីក្រុងភ្នំពេញ ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនចេញពីក្រចេះមកខេត្តមណ្ឌលគិរី។ ដោយខ្មែរក្រហមឲ្យខ្ញុំធ្វើជាប្រធានកងវរៈសេនាតូចលេខ១២ ក្រោមការគ្រប់គ្រងរបស់តាសាន ហៅថា០៦។ កិច្ចការងាររបស់ខ្ញុំនៅទីនោះក្រៅពីតួនាទីមើលការខុសត្រូវលើវរសេនាតូចលេខ១២ ដែលមានកម្លាំង៣០០នាក់ យើងត្រូវដើរល្បាតនៅតាមព្រំដែនមួយជួរដាក់ដាំ។ មុនពេលខ្ញុំបានធ្វើជាប្រធានកងវរៈ យើងក៏ត្រូវមានស្នាដៃ មានសេចក្តីក្លាហាន មោះមុត ទើបខ្មែរក្រហមជ្រើសរើសឲ្យធ្វើមេ។ ក្នុងនាមជាអ្នកដឹកនាំម្នាក់ ធ្វើអ្វីមួយត្រូវតែជាអ្នកនាំមុខគេជានិច្ច។ ការរស់នៅទីនោះយើងពុំសូវជួបប្រទះនូវការលំបាកទេ ដោយសារតែយើងចេះជួយគ្នាបរបាញ់សត្វ និងដាំដំណាំចែកគ្នាហូប។

## ព្រុំ ឈៀង៖ កងទ័ពជើងទឹក



ព្រុំ ឈៀង នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រុំ ឈៀង ភេទប្រុស អាយុ៦៧ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងស្រុកកំពង់ត្រាច ខេត្តកំពត។ បច្ចុប្បន្ន រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ព្រុំ ឈៀង បានរៀបរាប់ពីជីវិតកងទ័ពដែលខ្លួនធ្លាប់ឆ្លងកាត់ថា នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំចូលបម្រើដល់

កងទ័ពខ្មែរក្រហមនៅក្នុងកងវរសេនាធំ៦៣ តាមការអំពាវនាវរបស់សម្តេច ព្រះនរោត្តម សីហនុឲ្យចូលព្រៃម៉ាគី ក្រោយរដ្ឋប្រហារទម្លាក់ព្រះអង្គ។ ដំបូងឡើយ យើងត្រូវបញ្ជូនទៅហ្វឹកហ្វឺនពីរបៀបប្រយុទ្ធរបស់កងទ័ពនៅភ្នំវល្លិ៍បន្ទាប់មក យើងត្រូវបានថ្នាក់លើបញ្ជូនទៅការពារមុខសញ្ញាជុំវិញទីរួមខេត្តកំពតក្រោមការគ្រប់គ្រងរបស់ ចម្រើន ។ រហូតដល់ឆ្នាំ១៩៧៤ ការវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ចាប់ផ្តើមកើតមានទ្រង់ទ្រាយធំនៅខាងកើតខេត្តកំពតត្រង់ម្តុំរោងចក្រីទីញ និងសមរភូមិភ្នំស៊ិយ។ ការតស៊ូទ្រង់ទ្រាយធំនេះ គឺមានការគាំទ្រពីកងទ័ពវៀតណាមខាងជើង ដែលផ្តល់លទ្ធភាពឲ្យកងទ័ពខ្មែរក្រហមបង្កើនកម្លាំងកាន់តែច្រើនដើម្បីយកជ័យជម្នះលើទាហាន លន់ នល់ ក្នុងឆ្នាំ១៩៧៥។ ខណៈពេលដែលកងទ័ពខ្មែរក្រហមគ្រប់គ្រងទីក្រុងភ្នំពេញទាំងស្រុង ប៉ុន្តែសមរភូមិខេត្តកំពតទទួលបានជ័យជម្នះរយៈពេលបីថ្ងៃក្រោយមកទៀត ដោយមានការបាញ់ទម្លាក់យន្តហោះ លន់ នល់ ប្រមាណជាបីគ្រឿងនៅសមរភូមិទៀត។ ភ្លាមៗនោះ កងកម្លាំងរបស់យើងចាប់ផ្តើមប្រមូលសម្បត្តិជ័យភណ្ឌ ដូចជា រថក្រោះ និងសព្វាវុធជាច្រើនទៀត ដើម្បីបម្រើដល់អង្គភាពខ្មែរក្រហមបន្ទាប់ពីទាហាន លន់ នល់ រត់បែកខ្ចាត់ខ្ចាយតាមព្រំដែនទឹក។ ចំណែកប្រជាជនក៏បានសាទរចំពោះជ័យជម្នះនេះដែរ។ ក្រោយមក អង្គភាពខ្មែរក្រហមបញ្ជូនខ្ញុំទៅឈរជើងនៅកោះទន្សាយ ក្រោមវរសេនាធំឯករាជ្យ ដើម្បីការពារព្រំដែនទឹក។ យើងផ្តោតទៅលើកោះទាំងឡាយនៅតាមបណ្តោយព្រំដែនទឹក ដូចជា កោះដូង កោះបុស្សី កោះទន្សាយ កោះដោះក្រមុំ និងកោះពូលូវ៉ៃ ជុំវិញតំបន់៣៥។ យើងបានប្រើប្រាស់កាណូតឈើ ដើម្បីចុះផ្ទាល់ទៅកាន់កោះទាំងអស់នោះស្ទង់មើលសភាពការណ៍។ យើងបានជួបប្រទះសភាពការណ៍មិនល្អជាមួយនឹងកងទ័ពវៀតណាមយូរៗម្តង ដោយសារការនេសាទនៅតាមបណ្តោយព្រំដែនទឹក។ កងទ័ពវៀតណាមប្រើប្រាស់ម៉ូតូទឹកទំនើបៗក្នុងការនេសាទ ជាពិសេសតែងចូលមកក្នុងដែនទឹករបស់យើងជាញឹកញាប់។ កងកម្លាំងរបស់យើងតែងដេញក្រុមនេសាទទាំងអស់នោះឲ្យត្រឡប់ទៅវិញដោយប្រើកាណូតឈើ។ យើងបានប្រើក្បូនទូកដែលមានគ្នាចំនួន៦០នាក់ក្នុងមួយទូក និងមានទូកតូចៗអមដំណើរល្បាតតាមព្រំដែនទឹកដែលនៅពេលនោះ ខ្ញុំមានតួនាទីគឺជាប្រធានអនុសេនាធំ។ ជារៀងរាល់ម៉ោង៤ព្រឹក យើងតែងនាំកងល្បាតទៅកាន់កោះមួយចំនួនតាមព្រំដែន រហូតដល់ល្ងាចទើបត្រឡប់ទៅកាន់កោះទន្សាយវិញ និងមានក្រុមផ្សេងទៀតល្បាតបន្ត។ ជាទូទៅយើងតែងផ្លាស់ប្តូរវេនគ្នាសម្រាកប្រមាណជា៦ខែម្តងនៅក្នុងមួយកងវរសេនាធំ ដើម្បីមានពេលកម្សាន្តនៅក្រុងកែប។ មួយរយៈក្រោយមក នៅពេលមានជម្លោះជាមួយវៀតណាម អង្គការថ្នាក់លើបានដកខ្ញុំទៅកាន់ព្រំដែនទាន់ហាន់ប៉ុហៅថា ដងទង់ធំ ហើយអំឡុងពេលនោះ កងទ័ពវៀតណាមបានបញ្ជូនទ័ពចូលកោះត្រល់។ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៥ កងកម្លាំងចាប់ផ្តើមមានការប្រុងប្រៀបប៉ុន្តែយើងបានហាមកម្លាំងតាមព្រំដែនដាច់ខាតមិនឲ្យប្រើប្រាស់អាវុធជាអាទិភាពទេ។ ក្រោយមកទៀត ខ្ញុំត្រូវថ្នាក់លើដកទៅទីក្រុងភ្នំពេញដើម្បីរៀនបច្ចេកទេសបើកយន្តហោះ ប៉ុន្តែដោយសារសុខភាពរបស់ខ្ញុំមិនល្អ ថ្នាក់លើក៏ដកទៅរៀនបច្ចេកទេសកាំភ្លើងធំវិញ។

## ចាន់ ម៉ុន៖ កងទ័ពខ្មែរក្រហម

ចាន់ ម៉ុន ភេទប្រុស អាយុ៨៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិដូនរាជ្យ ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។ បច្ចុប្បន្នគាត់រស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ចាន់ ម៉ុន បានរៀបរាប់ពីបទពិសោធន៍របស់ខ្លួនកាលនៅជាកងទ័ពខ្មែរក្រហមថា «នៅឆ្នាំ១៩៧៤ ខ្ញុំបានចូលរួមជាមួយចលនាខ្មែរក្រហមដោយការចាប់បង្ខំ។ ខ្មែរក្រហមកៀងគរប្រជាជនជាច្រើននៅក្នុងភូមិឲ្យចូលរួមក្នុងការវាយជាមួយទាហាន លន់ នល់ ជាពិសេសកងរបស់ខ្ញុំត្រូវវាយតាមមុខសញ្ញាផ្តោះ



ចាន់ ម៉ុន និង មេក វិន អ្នកស្រាវជ្រាវមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅកាន់ទីក្រុងភ្នំពេញ។ នៅពេលនោះកម្លាំងរបស់យើងបានស្លាប់ច្រើនណាស់ពីមួយថ្ងៃទៅមួយថ្ងៃ។ លុះដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលជ័យជម្នះ ហើយប្រជាជននៅក្នុងក្រុងត្រូវបានជម្លៀសចេញមកក្រៅ ហើយនៅពេលនោះ ខ្ញុំឈរជើងនៅទួលគោក។ ខ្ញុំទទួលដំណឹងថា ការជម្លៀសនេះ គឺដើម្បីការពារប្រជាជនពីការទម្លាក់គ្រាប់បែក និងបោសសម្អាតកិញសម្ងាត់ដែលលាក់ខ្លួននៅក្នុងក្រុង។ ក្រោយពីការជម្លៀសប្រជាជនចេញទៅអស់ ស្នូរកាំភ្លើងរប៉េសរប៉ុសបានកើតមាននៅក្នុងក្រុង ប៉ុន្តែក្រោយមកក៏បានស្ងប់ស្ងាត់ទៅវិញ។ ខ្មែរក្រហមចាត់កម្លាំងបោសសម្អាត និងរៀបចំផ្ទះសម្បែងឡើងវិញ។ ក្រុមខ្ញុំមានគ្នាចំនួន៣នាក់ បាននាំគ្នាប្រមូលសម្លៀកបំពាក់ សម្ភារប្រើប្រាស់ និងស្បៀងអាហារ ដើម្បីបញ្ជូនទៅកាន់ទីជនបទ។ ក្រោយមក ខ្មែរក្រហមបញ្ជូនខ្ញុំទៅកាន់ខេត្តមណ្ឌលគិរី ដើម្បីធ្វើស្រែតាមព្រំដែនជាមួយនឹងអង្គភាព និងកម្លាំងទ័ពជាច្រើននាក់។ ដោយសារពុំមានផ្លូវធ្វើដំណើរងាយស្រួល យើងតែងចំណាយពេលវេលាក្នុងការកល់ឡានពេលដែលជាប់ផុង និងធ្វើដំណើរជាច្រើនថ្ងៃទើបទៅដល់គោលដៅ។ ខ្ញុំរស់នៅ និងបង្កបង្កើនផលនៅមណ្ឌលគិរី រហូតដល់កងទ័ពវៀតណាមវាយបានទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៩ ទើបកម្លាំងរបស់ខ្ញុំរត់ចូលព្រៃដើម្បីលាក់ខ្លួន។ នៅពេលនោះ យើងបានជួបនឹងការលំបាកម្តងទៀត ដោយសារដាច់ស្បៀងអាហារ ហើយពីមួយថ្ងៃទៅមួយថ្ងៃ យើងបានដឹកមើមក្តួច និងដំឡូងព្រៃមកហូបដើម្បីចម្អែតក្រពះ ទម្រាំកងកម្លាំងរបស់យើងអាចចូលទៅក្នុងភូមិដើម្បីកៀងគរកម្លាំងប្រជាជន និងស្បៀងអាហារបាន។ ខណៈដែលប្រជាជននៅតាមស្រុកភូមិចាប់ផ្តើមមានភាពធូរស្បើយឡើងវិញ កងកម្លាំងខ្មែរក្រហមនៅក្នុងព្រៃចាប់ផ្តើមជួបការលំបាកកាន់តែខ្លាំងឡើង ដោយការវាយប្រហារពីកងទ័ពវៀតណាម ខ្វះខាតគ្រាប់ និងស្បៀងអាហារ។ ក្រោយមកទៀត ទើបកម្លាំងរបស់យើងចាប់ផ្តើមមានខ្សែរយៈឡើងវិញហើយចាប់ផ្តើមប្រមូលកម្លាំងដែលនៅសេសសល់ធ្វើដំណើរទៅកាន់ភ្នំដងរែក»។

## ចាន់ ស៊ុយៈ កងទ័ព



ចាន់ ស៊ុយ នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាន់ ស៊ុយ ភេទប្រុស អាយុ៧៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល។ បច្ចុប្បន្នរស់នៅក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ចាន់ ស៊ុយ បានរៀបរាប់អំពីការងាររបស់ខ្លួនក្នុងចលនាខ្មែរក្រហមថា «ខ្ញុំមានបងប្អូនចំនួន ៦នាក់ នៅក្នុងក្រុមគ្រួសារ មានជីវភាពក្រលំបាកនៅជំនាន់សង្គមរាស្ត្រនិយម។ ក្រោយមកខ្ញុំស៊ីឈ្នួលដឹកសាកសព ដែលស្លាប់ដោយសារជំងឺនៅតាមមន្ទីរ

ពេទ្យនានាក្នុងទីក្រុងភ្នំពេញទៅជាយក្រុង ដើម្បីឲ្យក្រុមគ្រួសារធ្វើបុណ្យតាមប្រពៃណី។ ដើម្បីចិញ្ចឹមឪពុកម្ដាយ និងបងប្អូនដែលកំពុងរៀនសូត្រ ខ្ញុំមិនខ្លាចទេក្នុងការប្រកបរបរមួយនេះ។ ពេលខ្លះដឹកសពទៅតំបន់ឆ្ងាយពីក្រុងភ្នំពេញ ពេលខ្លះក៏នៅក្នុងក្រុង។ ខ្ញុំធ្លាប់ត្រូវបាន ឡានកៀរធ្លាក់ផ្លូវក៏មានដែរជាមួយនឹងសាកសពដែលសន្ដោងដោយរ៉ឺម៉ករទេះ។ បើទោះបីជាមុខរបរដឹកសាកសព គឺជាមុខរបរដែលមនុស្សគ្រប់គ្នាខ្លាចរអា ប៉ុន្តែក្រុមគ្រួសាររបស់ខ្ញុំហាក់មានភាពប្រសើរឡើង និងសល់លុយកាក់បន្តិចបន្តួចពីមុខរបរនេះនៅត្រឹមឆ្នាំ១៩៧១។ ជីវភាពរស់នៅរបស់ប្រជាជនចាប់ផ្ដើមមានការប្រែប្រួលនៅពេលព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្ដេច ព្រះនរោត្តម សីហនុ និងមានការធ្វើបាតុកម្មទាមទារអំណាចឲ្យព្រះអង្គវិញ។ ខ្ញុំឃើញទិដ្ឋភាពរបស់ប្រជាជនរស់នៅក្នុងក្រុងមានភាពចលាចល ប៉ុន្តែខ្ញុំក៏មិនខ្វាយខ្វល់ពីព្រឹត្តិការណ៍នេះដែរទេ។ ខ្ញុំមិននឹកស្មានថាព្រឹត្តិការណ៍នេះ ជាដើមចមសង្គ្រាមដ៏រ៉ាំរ៉ៃ រហូតបង្ខំឲ្យយើងរត់ចូលព្រៃដើម្បីតស៊ូក្នុងចលនាខ្មែរក្រហមទេ។

នៅក្នុងឆ្នាំ១៩៧២ ខ្ញុំចូលបម្រើដល់កងទ័ពខ្មែរក្រហម ហើយក្រោយមកខ្ញុំមានតួនាទីកាន់អង្គភាព «គ៣» ដែលមានកម្លាំងប្រមាណជា ៤០០ នាក់។ អង្គភាពរបស់ខ្ញុំទទួលខុសត្រូវលើមុខសញ្ញាចាប់ពីផ្សារតាខ្មៅ ទៅដល់ព្រំប្រទល់ស្រុកកោះធំ។ យើងបានវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ប៉ុន្តែជាទូទៅ ទាហានទាំងនោះមានចំណុចខ្សោយទៅលើបណ្ដាញទំនាក់ទំនងពីបន្ទាយមួយទៅបន្ទាយមួយ ឬពីសមរភូមិមួយទៅសមរភូមិមួយ និងមិនមានការប្ដេជ្ញាចិត្តដូចកងទ័ពខ្មែរក្រហមទេនេះក៏ព្រោះតែទាហានទាំងនោះជាទាហានស៊ីឈ្នួល ឬធ្វើការដើម្បីប្រាក់ខែតែប៉ុណ្ណោះ។

នៅអំឡុងរដ្ឋប្រហារឆ្នាំ១៩៧០ កងកម្លាំងរបស់យើងជួបប្រទះនូវការទម្លាក់គ្រាប់បែក និងប្រយុទ្ធដោយផ្ទាល់ជាមួយនឹងទាហានអាមេរិក ពេលនោះខ្ញុំមានតួនាទីគឺជាមេវរសេនាតូចលេខ១២។ សភាពការណ៍នៅពេលនោះ មិនអំណោយផល និងអនុញ្ញាតឲ្យយើងត្រៀមខ្លួនបានពេញលេញទេ។ ទាហានអាមេរិកមានមាឌធំៗ បានចូលប្រយុទ្ធទាំងកម្រោល និងមិនមានការលូនក្រាប ឬជីកត្រង់សេ ដើម្បីការពារដូចយើងទេ។ ភាគច្រើនទាហានទាំងនោះបានស្លាប់ និងបានវាយរំដោះយកសាកសពត្រឡប់ទៅវិញ។ ទោះជាយ៉ាងនេះក្ដី ទាហានទាំងនោះមិនបានដកថយភ្លាមៗទេ គឺបន្តការវាយប្រយុទ្ធអស់រយៈពេលជាច្រើនខែបន្តទៀតបណ្ដាលឲ្យកងកម្លាំងរបស់យើងបាត់បង់ជីវិតជាច្រើននាក់។ កងកម្លាំងក្នុងអង្គភាពរបស់ខ្ញុំ ត្រូវស្លាប់បាត់បង់ជីវិតខ្ទង់ពាន់នាក់អំឡុងពេលវាយប្រហារពីលើអាកាស និងថ្មើរជើង។

រហូតដល់ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមទទួលជ័យជម្នះ នៅពេលនោះកងកម្លាំងរបស់ខ្ញុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាសាន ហៅតា០៦ មេកងពល៩២០ ដែលកំណត់មុខសញ្ញាឲ្យខ្ញុំឈរជើងនៅត្រង់គល់ស្ពានជ្រោយចង្វារ។ នៅពេលនោះស្ពានឆ្លងទន្លេដ៏ធំនេះត្រូវបានកាត់ផ្ដាច់រួចទៅហើយ។ បន្ទាប់មកខ្ញុំឃើញទិដ្ឋភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយសារខ្លាចមានខ្មាំងបង្កប់ និងការពារប្រជាជនពីការទម្លាក់គ្រាប់បែកបន្តទៀត។ ខ្ញុំបានជួបប្រជាជនចំនួន១០គ្រួសារ ដែលខ្ញុំធ្លាប់ស្គាល់ និងជួយសម្រួលនៅក្នុងការជម្លៀសនេះកុំឲ្យមានការវាយធ្វើបាបនៅតាមផ្លូវ។ ក្រោយមកទៀត ទិដ្ឋភាពនៅក្នុងក្រុងភ្នំពេញចាប់ផ្ដើមមានភាពស្ងាត់ជ្រងំ ហើយកងកម្លាំងរបស់ខ្ញុំត្រូវខ្មែរក្រហមចាត់ឲ្យប្រមូលរបស់របរ បោសសម្អាតផ្លូវ និងផ្ទះប្រជាជននៅក្នុងក្រុង។ យើងបានបែងចែកមុខសញ្ញាគ្នាដើម្បីធ្វើការ។ ក្រោយមកទៀត ខ្មែរក្រហមបានដកខ្ញុំទៅរៀនបើករថក្រោះ នៅព្រលានយន្តហោះពោធិ៍ចិនតុងជាមួយនឹងកងកម្លាំងរាប់ពាន់នាក់។ ក្នុងទ្រឹស្ដីខ្មែរក្រហមនិយាយថា «ការបម្រើក្នុងកងរថក្រោះ គឺជាអ្នកដែលក្លាហានបំផុត»។ ក្នុងកងរថក្រោះ គឺផ្ដោតទៅលើអ្នកបើកបរ និងអ្នកបាញ់ ហើយជាអ្នកដែលមានសមត្ថភាពដូចគ្នា បើពុំដូច្នោះទេ យើងនឹងស្លាប់ទាំងអស់គ្នា ដោយសារបរាជ័យក្នុងសមរភូមិ។ ខ្ញុំឃើញរថក្រោះដែលយើងវាយបានពីទាហាន លន់

នល់ និងជំនួយដែលផ្ដល់ដោយចិន គឺមានចំនួនច្រើនណាស់ ប៉ុន្តែរថក្រោះទាំងនោះហាក់មិនត្រូវបានប្រើប្រាស់នៅតាមព្រំដែនទៅវិញ ដែលប្រហែលមកពីចំនួនមានកំណត់ និងខ្វះអ្នកបច្ចេកទេសបើកបរ។ បន្ទាប់ពីរៀនសូត្រពីជំនាញបើករថក្រោះរយៈពេលប្រមាណជា ៣ខែ ខ្មែរក្រហមក៏បានបញ្ជូនខ្ញុំទៅគ្រប់គ្រងកងទ័ពជើងទឹកនៅវាលរិញ ប្រមាណជិតមួយខែ។ ខ្ញុំមិនមានជំនាញនេះពីមុនមកទេ ប៉ុន្តែជាទូទៅខ្មែរក្រហមបានផ្ដល់ឱកាសដល់ខ្ញុំក្នុងការរៀនសូត្រដោយរៀនពីបច្ចេកទេសនៅក្នុងការមើលផែនទី ការសិក្សាអំពីកោះតាមព្រំដែនទឹក និងអំពីការយល់ដឹងពីផ្លូវទឹក។ បន្ទាប់មក ខ្ញុំក៏ត្រូវបានដកឲ្យទៅឈរជើងនៅខេត្តមណ្ឌលគិរី។

រឿងមួយដែលខ្ញុំចងចាំមិនភ្លេចកាលពីឆ្នាំ១៩៧៧ កងពល៩២០បានបញ្ជូនខ្ញុំឲ្យទៅយកឡានជាង ១០០០គ្រឿង ពីភ្នំពេញ ដើម្បីដឹកជញ្ជូនស្បៀង និងគ្រាប់ទៅកាន់ព្រំដែនខេត្តមណ្ឌលគិរី។ កម្លាំងរបស់ខ្ញុំចំនួន ៦នាក់បានទទួលបទបញ្ជានេះ តាមរយៈសារអង្គលីលេខ។ យើងធ្វើដំណើរមកភ្នំពេញតាមកាណូត។ គ្រាន់តែដល់ចំណតភ្លាម កម្លាំងទ័ពខាងភ្នំពេញ បានចាប់ខ្លួនក្រុមរបស់ខ្ញុំទៅសួរចម្លើយនៅគុកព្រៃ-ស ដោយចោទថា ក្រុមរបស់ខ្ញុំជាជនក្បត់តាមរយៈកំហុសបច្ចេកទេសក្នុងការវាយខ្ទឹមសារតាមអង្គលីលេខ។ ឆ្មាំគុកទាំងនោះបានចោទសួរក្រុមខ្ញុំទាំង៦នាក់ថា «ម៉េចបានពួកហែងក្បត់?» ខ្ញុំបានឆ្លើយថា ខ្ញុំមិនបានក្បត់ និងមិនបានដឹងរឿងអ្វីនោះទេ។ បន្ទាប់មក ឆ្មាំគុកទាំងនោះ បានវាយខ្ញុំ និងធ្វើទារុណកម្មដោយឆក់នឹងខ្សែភ្លើងរយៈពេល៣ថ្ងៃម្ដង។ ខ្ញុំបានឃើញប្រជាជនច្រើនណាស់ដែលជាប់ទោសនៅទីនោះ ហើយជួបនឹងស្ថានភាពដូចខ្ញុំដែរ។ យើងមិនទទួលរបបអាហារគ្រប់គ្រាន់នោះទេអំឡុងពេលជាប់ឃុំឃាំង។ យើងទទួលបានបបរតែមួយកូនចង្កឹះប៉ុណ្ណោះក្នុងមួយពេល។ យើងតែងងូតទឹករួមគ្នាក្នុងចំណោមមនុស្សប្រុសស្រីជាច្រើននាក់នៅក្នុងគុក និងជួបការអៀនខ្មាសគ្រប់បែបយ៉ាង។ ដោយសារបាត់ដំណឹងពីក្រុមរបស់ខ្ញុំ ប្រហែលរយៈពេល១០ថ្ងៃក្រោយមក មេអង្គភាព ៩២០ ក៏បានទំនាក់ទំនងមកកម្លាំងក្នុងទីក្រុងភ្នំពេញ ហើយក៏ដឹងសាច់រឿងនេះ បន្ទាប់មក ក្រុមរបស់ខ្ញុំក៏ត្រូវបានដោះលែងវិញ។ ភ្លាមៗនោះ ខ្ញុំបានសងសឹក ដោយសារវាយទៅលើឆ្មាំគុកដែលធ្លាប់បានធ្វើទារុណកម្មមកលើខ្ញុំ មុននឹងត្រឡប់ទៅយកឡានទៅខេត្តមណ្ឌលគិរីវិញ។ ខ្ញុំយល់ថា ទោះបីខ្ញុំជួបការលំបាក ជាពិសេសការធ្វើទារុណកម្មបែបនេះក៏ដោយ ប៉ុន្តែខ្ញុំក៏មិនអាចដកខ្លួនចេញពីខ្មែរក្រហមបានដែរ»។

## ទូច ខេង ៖ នីរសារ



ទូច ខេង នៅផ្ទះរបស់គាត់នៅពេលធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ កាលពីខែមិថុនា ឆ្នាំ២០២២ ក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទូច ខេង ភេទស្រី អាយុ៦៥ឆ្នាំ មានស្រុកកំណើតរស់នៅក្នុងភូមិគោកដូល ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ។ ទូច ខេង សព្វថ្ងៃរស់នៅក្នុងភូមិអូរជីក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ។ ទូច ខេង បាននិយាយរៀបរាប់រឿងរ៉ាវដែលខ្លួនបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមថា កាលពីកុមារភាពខ្ញុំរៀនបានថ្នាក់ទី១២ ពីសង្គមស្មើនឹងថ្នាក់ទី១ យើងបច្ចុប្បន្ននេះ។ ជំនាន់នោះដោយសារតែគ្រួសារមានជីវភាពខ្វះខាត ហើយខ្ញុំជាកូនកំព្រាផងទើបមិនអាចរៀនបានខ្ពស់ដូចក្មេងៗដទៃ។ ឪពុកម្ដាយរបស់ខ្ញុំបានស្លាប់តាំងពីខ្ញុំនៅក្មេង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ ប៉ុន្តែ

បងៗខ្ញុំបានស្លាប់អស់៣នាក់ហើយ ខ្ញុំនៅតែពីរនាក់ប្អូនស្រីពៅ។ ការរស់នៅរបស់ខ្ញុំ និងប្អូនស្រីមានការលំបាក។ ក្នុងឆ្នាំ១៩៧២ ខ្ញុំបានចេញពីភូមិទៅធ្វើជានីរសាររត់សំបុត្រនៅឃុំត្រពាំងក្រសាំង។ កាលខ្ញុំនៅជានីរសារឃុំ ការងាររបស់ខ្ញុំគឺយកសំបុត្រទៅជូនប្រធានភូមិទាំងអស់នៅក្នុងឃុំត្រពាំងក្រសាំង។ កាលណោះ មេឃុំខ្ញុំឈ្មោះ ដេង មើលការខុសត្រូវក្នុងឃុំទាំងមូល។ នីរសាររត់សំបុត្ររបស់ក្រុមខ្ញុំមានគ្នា៣នាក់ គឺស្រីទាំងអស់។ ជំនាន់នោះ ឲ្យតែមានសំបុត្រមកដល់មិនថាយប់ឬក៏ថ្ងៃទេ ក្រុមខ្ញុំទាំង៣នាក់ ត្រូវតែយកទៅជូនប្រធានភូមិទាំងអស់មិនឲ្យខកខានទេ ព្រោះខ្លាចមេភូមិមិនបានទទួលដំណឹងមកប្រជុំមិនទាន់ពេលវេលា។ ខ្ញុំបានធ្វើជានីរសារនៅឃុំអស់រយៈពេល២ឆ្នាំ ខ្ញុំក៏ឡើងទៅធ្វើនីរសារស្រុក។ គណៈស្រុកបាទីនៅជំនាន់នោះឈ្មោះតាភឿង។ ពេលខ្ញុំឡើងមកដល់ស្រុក អង្គការមានកង់សម្រាប់ឲ្យជិះ និងកាំភ្លើងមួយដើមទុកការពារខ្លួនប៉ុន្តែមិនដែលហ៊ានបាញ់ទេ បានត្រឹមតែដាក់តាមខ្លួន។ ខ្ញុំរត់សំបុត្រឲ្យទៅតាមឃុំ។ នៅពេលយប់ ក្រុមខ្ញុំស្រីៗចាប់ផ្តើមចែកផ្លូវគ្នាទៅរត់សំបុត្រហើយ អ្នកខ្លះ ២នាក់ យក ៣ឃុំ ឯខ្លះទៀតគ្នា២នាក់ យក២ឃុំ។ នីរសារទាំងអស់ត្រូវយកសំបុត្រទៅជូនមេឃុំឲ្យដល់ដៃទាំងយប់ ប្រសិនបើមានមេឃុំណាមួយមិនទទួលបានសំបុត្រ ខាងសាលាស្រុកនឹងបើកការប្រជុំណែនាំ ឬសួររកហេតុផលថាហេតុអ្វីមិនអាចយកសំបុត្រទៅដល់មេឃុំបាន។

ខ្ញុំរស់នៅធ្វើជានីរសារស្រុក រហូតដល់ឆ្នាំ១៩៧៥ មានការជ្រើសរើសនារីៗ និងយុវជនទៅខាងមណ្ឌលគិរី។ បន្ទាប់ពីមានការជ្រើសរើសហើយ ខ្ញុំក៏បានចូលក្នុងកង៩២០។ ការធ្វើដំណើរទៅខេត្តមណ្ឌលគិរី មានការលំបាកខ្លាំងណាស់ ដោយសារតែមិនទាន់មានផ្លូវធ្វើដំណើរស្រួលបួលទេ។ កងទ័ពរួមទាំងប្រជាជនបានធ្វើដំណើរអស់រយៈពេល៦ខែ ទម្រាំតែទៅដល់មណ្ឌលគិរី។ ពេលធ្វើដំណើរទៅដល់មណ្ឌលគិរី ខ្ញុំយុវជន យុវនារីទាំងអស់ត្រូវបានចាត់តាំងឲ្យធ្វើស្រែ។ កាលណោះ ប្រជាជនទាំងអស់បានចងខ្សែកាបឆ្លងទន្លេស្រែពកដើម្បីដឹកជញ្ជូនសំណាបទៅស្ទូង ព្រោះមិនទាន់មានស្ពានឆ្លង។ ថ្ងៃមួយកម្លាំងដែលជញ្ជូនសំណាបតាមខ្សែកាបបានធ្លាក់ចូលទឹកកំពុងហូរ ស្លាប់អស់៣នាក់។ នៅក្នុងកង៩២០ ខ្ញុំមិនដែលទទួលបានអាហារគ្រប់គ្រាន់ទេ។ រហូតដល់ខ្ញុំ ត្រូវបានបញ្ជូនឲ្យទៅជួយធ្វើការនៅកង១០៥ ទើបខ្ញុំទទួលបានការហូបចុកគ្រប់គ្រាន់។ កាលណោះ បានជាអង្គការបញ្ជូនកម្លាំងមកខាងមណ្ឌលគិរីដែលជាទីកន្លែងជនជាតិភាគតិច មូលហេតុគឺដោយសារតែអង្គការមិនចង់ឲ្យរើសអើងជនជាតិ។ អង្គការបង្កើតឲ្យមានការរៀបការជនជាតិព្នងជាមួយខ្មែរ ជនជាតិឡាវជាមួយព្នង។ កាលខ្ញុំនៅក្នុងកង១០៥ អង្គការឲ្យខ្ញុំនៅនេសាទរកត្រីផ្តល់ឲ្យកងទ័ពសមរភូមិមុខ និងប្រជាជននៅសហករណ៍។

នៅឆ្នាំ១៩៧៩ វៀតណាមវាយចូលដល់ទន្លេស្រែពក ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់ទៀតបានរត់គេចខ្លួនចូលទៅរស់នៅក្នុងព្រៃជាមួយជនជាតិភាគតិច។ ខ្ញុំជួបការលំបាកជាច្រើន។ ខ្ញុំមិនដែលបានបាយហូបទេពេលនោះ។ ខ្ញុំហូបតែក្តួចចំណែកឯខោអាវមានតែមួយសម្រាប់ប៉ុណ្ណោះ។ វៀតណាមដើរល្បាតតាមអូរ រកពួកខ្ញុំប្រសិនបើវៀតណាមឃើញបាញ់តែម្តង។ ប្រជាជនទាំងអស់មិនហ៊ានដេកទេ ត្រៀមតែចាំរត់។ នៅពេលឈប់សម្រាកនៅទីកន្លែងណាបានយូរ ខ្ញុំរួមទាំងអ្នករួមដំណើរទាំងអស់នាំគ្នាជីកក្តួចដំឡូងហាលឲ្យស្ងួតទុកដាក់នៅក្នុងជង្រុកដូចជាស្រូវអង្ករ។ ប្រជាជនទាំងអស់ចាត់ទុកក្តួច ដំឡូងជាបាយ។ រហូតដល់ឆ្នាំ១៩៨១ ខ្ញុំធ្វើដំណើរមកកាន់ភ្នំដងរែក។ ពេលមកដល់ភ្នំដងរែកហើយប្រជាជនមួយចំនួនមិនចេះហូបបាយទេ ពីព្រោះធ្លាប់ហូបក្តួច។ នៅក្នុងឆ្នាំ១៩៨២ ខ្ញុំរៀបការ ប្តីខ្ញុំធ្វើជាកងទ័ព។ ក្រោយពីខ្ញុំមានគ្រួសារហើយ ខ្ញុំបន្តរស់នៅលើភ្នំដងរែករហូតដល់មានការដង្រះដង្រាររួមគ្នានៅអន្លង់វែងក្នុងឆ្នាំ១៩៩៨ ទើបខ្ញុំចុះមករស់នៅក្នុងឃុំផ្អាវនេះរហូតដល់បច្ចុប្បន្ន។

# គម្រោងសូត្រចាមរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា

*មីន សាណាស់*



*ស្ត្រីជនជាតិចាម នៅស្រុកកោះសូទិន ខេត្តកំពង់ចាម កំពុងត្បាញសូត្រ។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*សំពត់សូត្រចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

គម្រោងសូត្រចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតឡើងក្នុងគោលបំណងដើម្បីរក្សាការចងចាំរបស់ជនជាតិចាមអំពីសូត្រ និងតម្បាញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ, លើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយ និងរៀបចំផែនការអភិវឌ្ឍន៍នៅពេលអនាគត។ គម្រោងនេះនឹងគាំទ្រស្ត្រី និងអ្នករស់នៅក្នុងសហគមន៍បង្កើតជាសិប្បកម្មតម្បាញធុនតូចដោយចាប់ផ្តើមពីគំនិត កីមួយ និងសូត្រមួយសំពត់។

នៅដំណាក់ដំបូងនៃគម្រោងសូត្រចាមនឹងផ្តោតសំខាន់ៗទៅលើសកម្មភាព ដូចតទៅ គឺ ១) ចុះស្រាវជ្រាវ និងចងក្រងឯកសារ ២) សិក្សាពីសិល្បៈនិងសហគមន៍តម្បាញសូត្រចាម ៣) ធ្វើពិសោធន៍ និងរៀបចំការបណ្តុះបណ្តាលសម្រាប់សហគមន៍ ៤) ត្បាញ ៥) ធ្វើការផ្សព្វផ្សាយនិងដាក់តាំងបង្ហាញពីផលិតផលតម្បាញរបស់សហគមន៍ចាម។ គម្រោងស្រាវជ្រាវ សូត្រចាមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភដោយប្រទេសតួគី តាមរយៈទីភ្នាក់ងារ សហប្រតិបត្តិការនិងអភិវឌ្ឍន៍របស់ប្រទេសតួគីដោយសហការជាមួយ ស្ថានទូតតួគីប្រចាំនៅប្រទេសកម្ពុជា។

នៅចន្លោះថ្ងៃទី១៣ដល់១៥ ខែមិថុនា ឆ្នាំ២០២២ ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារ កម្ពុជា រួមមាន

ស៊ាង ចិន្តា, ឡុង អូន និង មីន សាណាស់ បានចុះទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាជនជាតិចាម អំពីរឿងរ៉ាវជីវិតដែលបានឆ្លងកាត់របបខ្មែរក្រហម និងការប្រកបរបរចិញ្ចឹមគ្រួសារជាមួយការត្បាញសូត្រ ការប្រើសិល្បៈត្បាញគោម ការរចនាម៉ូត និងការប្រើប្រាស់ពណ៌ក្នុងការត្បាញ។

**ម៉ាត់ ម៉ៃស្នះ** ភេទស្រី អាយុ៧២ឆ្នាំ រស់នៅស្រុកកោះសូទិន ខេត្តកំពង់ចាម បានរៀបរាប់ថា «តម្បាញសូត្រចាម អាចឲ្យខ្ញុំចិញ្ចឹមម្ដាយ កូន និងក្មួយក្រោយពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩»។

ក្រោយរបបខ្មែរក្រហម គ្រួសារខ្ញុំរស់រានមានជីវិតតែស្ត្រី និងក្មេងៗតែប៉ុណ្ណោះ ហេតុនេះ ខ្ញុំនិងម្ដាយរបស់ខ្ញុំខិតខំស្វះស្វែងទៅរកត្រីដើម្បីលក់សន្សំលុយទិញកីទុកត្បាញក្រណាត់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។ ខ្ញុំនៅចាំថា ម្ដាយខ្ញុំ និងស្ត្រីចាមក្នុងភូមិ សុទ្ធតែមានចំណេះដឹងខាងតម្បាញសូត្រ ហើយនៅតាមផ្ទះនីមួយៗមានកីតម្បាញគ្រប់ៗគ្នា។ ចំណែកខ្ញុំមានជំនាញចងគោម និងត្បាញតពីម្ដាយរបស់ខ្ញុំ ហើយម្ដាយរបស់ខ្ញុំក៏ទទួលចំណេះដឹងតពីយាយរបស់ខ្ញុំដែរ។

ម្ដាយរបស់ខ្ញុំឈ្មោះ ម៉ៃយំ ពេលនៅរស់គាត់ប្រកបរបរតម្បាញ ចំណែកឪពុករបស់ខ្ញុំឈ្មោះ ម៉ាត់ មានមុខរបរជាអ្នកនេសាទ។ កាលពីសម័យមុន ជនជាតិចាមមករស់នៅក្នុងប្រទេសកម្ពុជាមានមុខរបរតែពីរប៉ុណ្ណោះ



ម៉ាត់ ម៉ៃស្នះ ភេទស្រី អាយុ៧២ឆ្នាំ រស់នៅស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

គឺនេសាទ និងតម្បាញ ហើយកូនៗដែលកើតមកត្រូវតែមានចំណេះដឹងក្នុងការប្រកបរបរនេះ។ ឪពុករបស់ខ្ញុំបានបង្រៀនបងប្រុស និងប្អូនប្រុសខ្ញុំអំពីជំនាញនេសាទត្រី ចំណែកម្ដាយរបស់ខ្ញុំបានបង្រៀនខ្ញុំនិងបងប្អូនស្រីៗអំពីសិល្បៈចរបាច់, តម្បាញ, ចាក់ផ្កាលើពូកខ្នើយ ជាដើម។ នៅពេលប្រទេសកម្ពុជាកើតមានសង្គ្រាមជាហូរហែ ប្រពៃណី វប្បធម៌របស់ជនជាតិចាមក៏បាត់បង់បន្តិចម្ដងៗ។

ខ្ញុំចេះត្បាញសំពត់សូត្រតាំងពីអាយុ១៣ឆ្នាំ និងកាន់កីតម្បាញរាល់ថ្ងៃ។ នាសម័យមុន មុខរបរតម្បាញសូត្រ គឺថ្លៃថ្នូរ ហើយប្រជាជនផ្ដល់តម្លៃខ្លាំងណាស់។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានរៀបការជាមួយប្ដីរបស់ខ្ញុំឈ្មោះ កសឹម ប្រកបមុខរបរនេសាទត្រី។ ក្រោយពីរៀបការរួច ខ្ញុំមានកូនចំនួន៣នាក់។ ខ្ញុំបានមករស់នៅលើទូកនេសាទជាមួយប្ដីរបស់ខ្ញុំ ចំណែកមុខរបរត្បាញសំពត់សូត្ររបស់ខ្ញុំក៏ផ្អាកជាបណ្ដោះអាសន្ន។

នៅពេលយោធាខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានបំផុសឲ្យជនជាតិចាមនៅក្នុងភូមិកោះសូទិន រៀបចំអីវ៉ាន់ និងត្រៀមធ្វើដំណើរទៅរស់នៅប្រទេសអារ៉ាប់។ ប្រជាជនចាមនៅក្នុងភូមិ រួមទាំងគ្រួសារខ្ញុំ ឪពុកម្ដាយខ្ញុំបានចាកចេញពីភូមិកោះសូទិន តាមការចាត់ចែងរបស់កម្មាភិបាលខ្មែរក្រហម។ នៅតាមផ្លូវ យោធាខ្មែរក្រហមបញ្ឆោតឲ្យគ្រួសារខ្ញុំទុករបស់មានតម្លៃ និងលុយកាក់ ព្រោះទៅដល់ទីនោះមិនខ្វះខាតឡើយ។ តាមពិត យោធាខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំតាមរថភ្លើងទៅកាន់ភូមិរហាលសួង ខេត្តបាត់ដំបង។ រយៈពេលកន្លះឆ្នាំបន្ទាប់ពីការជម្លៀស ឪពុកខ្ញុំបានធ្លាក់ខ្លួនឈឺដោយសារការបរិភោគមិនបានគ្រប់គ្រាន់ ហើយស្លាប់នៅទីនោះ។ តមកប្ដីរបស់ខ្ញុំ និងកូនប្រុសច្បងរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារការអត់ឃ្លានទៀត។ នៅអំឡុងពេលកូននិងប្ដីរបស់ខ្ញុំស្លាប់ គឺខ្ញុំទើបសម្រាលកូនទី៣ បានរយៈពេល

មួយខែប៉ុណ្ណោះ។ ទោះបីខ្ញុំនៅសរសៃខ្វីក៏អង្គការមិនឲ្យខ្ញុំឈប់សម្រាកដែរ គឺអង្គការបានចាត់តាំងខ្ញុំទៅកាស់គល់ឈើ និងដកស្ទូង។ ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅសល់តែខ្ញុំ ម្តាយរបស់ខ្ញុំ និងកូនតូចៗរបស់ខ្ញុំប៉ុណ្ណោះ។ យើងធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ នៅតាមផ្លូវកូនស្រីរបស់ខ្ញុំទាំងពីរកើតជំងឺអុតស្វាយ រីឯម្តាយរបស់ខ្ញុំមានវ័យចំណាស់ពិបាកក្នុងការធ្វើដំណើរ។ ខ្ញុំបានសុំរថយន្តរបស់កងទ័ពវៀតណាមជិះមកខេត្តកំពង់ចាម។ ពេលមកដល់ភូមិកំណើត ផ្ទះរបស់ខ្ញុំត្រូវបានខ្មែរក្រហមរុះរើគ្មានសល់ឡើយ។ ខ្ញុំបានក្រាលកន្ទេលលើដីដើម្បីដេកបណ្តោះអាសន្ន។ ម្តាយរបស់ខ្ញុំ និងខ្ញុំចេញទៅនេសាទ ដើម្បីយកត្រីទៅដូរយកសម្ភារប្រើប្រាស់ប្រចាំថ្ងៃ និងរៀបចំសាងសង់ខ្ទមសម្រាប់ស្នាក់នៅ។

នៅឆ្នាំ១៩៨០ ជនជាតិចាមនៅក្នុងភូមិដែលជីវភាពធូរធារ បាននាំគ្នាទៅទិញសម្ភារសម្រាប់ត្បាញ។ ប៉ុន្តែការត្បាញនោះ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងចែកដល់កូនចៅប៉ុណ្ណោះ គឺមិនទាន់មានការលក់ដូរឡើយ។ ខ្ញុំបានសន្សំប្រាក់រៀបចំធ្វើកីត្បាញ ព្រមទាំងស៊ីឈ្នួលត្បាញឲ្យប្រជាជនក្នុងភូមិរហូតដល់ឆ្នាំ២០១៥ ទើបឈប់ ព្រោះគ្មានទីផ្សារ។ ចំពោះគោមសំពត់សូត្រចាម គឺមានច្រើនម៉ូតណាស់ ដូច្នេះយើងបានបែងចែកវាជាបី គឺ ទី១) គោមវល្លិ៍, ទី២) គោមផ្កា និងផ្លែឈើ និងទី៣) គោមរូបសត្វ។ ចំណែកការជ្រលក់ពណ៌ យើងមិនអាចសម្គាល់បានច្បាស់លាស់ឡើយ ព្រោះពណ៌សំពត់សូត្រចាមមានភាពខុសគ្នាពីមួយជំនាន់ទៅមួយជំនាន់ ដូចជាជំនាន់សង្គមចាស់យើងប្រើផ្ទៃពណ៌ក្រហមសុទ្ធ ហើយចំណងគោម គឺមានពណ៌ក្រហមលឿង និងបៃតង។ ក្រោយមកទៀត អ្នកត្បាញចាប់ផ្តើមប្រើផ្ទៃស្រអាប់ៗ ហើយពណ៌ចំណងក៏មានតែពីរពណ៌ដែរ។

ខ្ញុំយល់ថា សំពត់សូត្រចាម ក្បាច់គោមសំពត់ចាមអាចនឹងបាត់បង់នៅពេលខាងមុខនេះ ព្រោះសព្វថ្ងៃនេះ ក្មេងស្រីជនជាតិចាមនៅក្នុងភូមិ ហាក់មិនចាប់អារម្មណ៍នឹងការផារតម្បាញដែលជាប្រពៃណីរបស់យើងឡើយ។



ស្ត្រីជនជាតិចាម នៅស្រុកកោះសូទិន ខេត្តកំពង់ចាម កំពុងចងមងសម្រាប់នេសាទត្រី។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)




សហគមន៍នេសាទរបស់ជនជាតិចាម នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវអ្នករស់រានមានជីវិត

## ពីរបបខ្មែរក្រហមនៅស្រុកកោះសូទិន និង ស្រុកកំពង់សៀម ខេត្តកំពង់ចាម

***ធូច វណ្ណាត និង អេង វណ្ណីកា***

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានចុះទៅភូមិសាស្ត្រស្រុកកោះសូទិន និងស្រុកកំពង់សៀម ដើម្បីជួបជាមួយអាជ្ញាធរមូលដ្ឋាន និងធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ ក្នុងអំឡុងពេលចុះធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ ក្រុមការងារបានជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៩ គ្រួសារ ដែលបានរៀបរាប់អំពីរឿងរ៉ាវបែកបាក់គ្រួសារ ទុក្ខលំបាក បទពិសោធន៍ និងការធ្វើការងារហួសកម្លាំងក្នុងរបបខ្មែរក្រហម។ ខាងក្រោមនេះគឺជាការចែករំលែកសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានជួបសម្ភាសន៍៖

### ១) ម៉ៅ វណ្ណា



ម៉ៅ វណ្ណា អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ (ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំនៅចាំពាក្យសម្តីរបស់មិត្ត ផាច និយាយមុនពេលខ្មែរក្រហមនាំគាត់ទៅសម្លាប់ថា «ខ្មែរក្រហមមិនដែលសាហាវដាងហុតែរ គឺខ្មែរសម្លាប់ខ្មែរនោះទេ»។ ខ្ញុំឈ្មោះ ម៉ៅ វណ្ណា ភេទស្រី អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ សុខ ផុយ និងមានកូនប្រុសស្រីចំនួន៣នាក់។ ខ្ញុំគឺជាអតីតនាយកសាលាបឋមសិក្សាទីប្រជុំ ដែលស្ថិតនៅភូមិទី ៨ នេះ។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ លាងគ្រី ដែលជាគ្រូបង្រៀននៅវិទ្យាល័យជម្ពូវិន និងម្តាយឈ្មោះ ម៉ៅ សុផល ជាមេផ្ទះ។ ឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ គឺមានតែរូបខ្ញុំម្នាក់ទេដែលរួចផុតពីការកាប់សម្លាប់។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាចុងកោះរហូតដល់ថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំស្នាក់នៅជាមួយ ជីដូននៅភូមិ ចំណែកឯឪពុកម្តាយ និងបងប្អូនផ្សេងទៀតរបស់ខ្ញុំរស់នៅទីក្រុងភ្នំពេញ។ ប៉ុន្មានខែបន្ទាប់ពីមានរដ្ឋប្រហារនៅឆ្នាំ១៩៧០ មានអ្នកភូមិចូលរួមដង្ហែបាតុកម្មទៅទីរួមខេត្តកំពង់ចាម។ ខ្ញុំមិនបានទៅចូលរួមទេ ប៉ុន្តែខ្ញុំបន្តស្នាក់នៅផ្ទះជាមួយជីដូន។ ក្រោយមកទៀត កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ និងស្នាក់នៅក្រោមផ្ទះរបស់អ្នកភូមិ។ នៅចុងឆ្នាំ១៩៧០ និងដើមឆ្នាំ១៩៧១ សង្គ្រាមរវាង ទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅភូមិសាស្ត្រកោះសូទិន។ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ទាហាន លន់ នល់ បើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមដែលឈរជើងនៅ

ភូមិសាស្ត្រកោះសូទិនកាន់តែខ្លាំងឡើង។ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំ ឪពុកម្តាយបានយកខ្ញុំទៅរស់នៅជាមួយនៅ ទីក្រុងភ្នំពេញវិញ។ នៅពេលនោះ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ចាស់។ ខ្ញុំបន្តរៀននៅសាលាបឋមសិក្សាជម្ពូវ័ន រហូតដល់ថ្នាក់ទី៤នៅវិទ្យាល័យជម្ពូវ័ន។

នៅដើមឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំទទួលបានដំណឹងថា កងទ័ពខ្មែរក្រហមបានចូលមកដល់ជិតទីក្រុងភ្នំពេញ។ នៅពេលនោះ ឪពុកខ្ញុំប្រាប់ម្តាយឲ្យនាំកូនៗចូលទៅភ្នំពេញ និងទៅស្នាក់នៅជាបណ្តោះអាសន្ននៅម្តុំទួលស្វាយព្រៃ។ ចំណែកឯឪពុករបស់ខ្ញុំគឺជិះកង់មកតាមក្រោយ។ បន្ទាប់ពីស្នាក់នៅមិនបានប៉ុន្មានផង ទីក្រុងភ្នំពេញត្រូវបានវាយបែក និងគ្រប់គ្រងដោយកងទ័ពខ្មែរក្រហម។ គ្រួសាររបស់ខ្ញុំគឺស្ថិតនៅក្នុងចំណោមគ្រួសាររាប់ពាន់ផ្សេងទៀត ដែលត្រូវបានជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ឪពុកម្តាយខ្ញុំសម្រេចចិត្តនាំកូនៗមកភូមិកំណើតនៅកោះសូទិនដើម្បីរស់នៅជាមួយជីដូនវិញ។ គ្រួសាររបស់ខ្ញុំធ្វើដំណើរជាច្រើនថ្ងៃទើបមកដល់ភូមិ។

បន្ទាប់ពីមកដល់ភូមិវិញ គ្រួសាររបស់ខ្ញុំត្រូវបានប្រជាជនមូលដ្ឋានដឹងថាជាប្រជាជន១៧មេសា ដែលមានប្រវត្តិធ្លាប់ធ្វើជាគ្រូបង្រៀននៅរបបចាស់។ បន្ទាប់មកឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានភូមិតាណុង ដែលជាកន្លែងប្រមូលផ្តុំប្រជាជន ដែលជាប់និន្នាការជាមួយរបបលន់ នល់ ដើម្បីទទួលរងការលត់ដំខ្លួន។ នៅពេលនោះ ខ្ញុំមិនបានទៅជាមួយឪពុកម្តាយ និងបងប្អូនទេ ពីព្រោះជីដូនរបស់ខ្ញុំបានប្រាប់មេភូមិថា ខ្ញុំគឺជាអ្នកមូលដ្ឋានចាស់។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការក្នុងកងចល័តនារី ដើម្បីធ្វើស្រែ ជីកដី និងលើកទំនប់។ នៅឆ្នាំ១៩៧៧ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ទីធ្វើការនៅការដ្ឋានឆ្ព័ត្រ ដែលជាកន្លែងខ្ញុំស្ទើរតែត្រូវបានចាប់យកទៅសម្លាប់ និងជាកន្លែងដែលខ្ញុំឃើញផ្ទាល់ភ្នែកពីទុក្ខវេទនារបស់គ្រួសារខ្ញុំនៅពេលនោះ។ ខ្ញុំតែងតែលួចទៅជួបឪពុកម្តាយក្នុងស្ថានភាពស្គមស្គាំង និងភិតភ័យ។ ខ្ញុំបានត្រឹមតែសួរសុខទុក្ខ និងមិនអាចធ្វើអ្វីបានលើសពីនេះ។ ចំណែកឯ កងចល័តនារីរបស់ខ្ញុំវិញត្រូវទៅជីកដីលើកដី និងធ្វើស្រែគ្មានពេលសម្រាក និងគ្មានអាហារហូបគ្រប់គ្រាន់។ កងចល័តនារីកន្លែងខ្ញុំធ្វើការមានសមាជិកមិត្តនារីទាំងអស់ ៩៧ នាក់។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកដល់ និងចាប់ផ្តើមចាប់កម្មាភិបាលមូលដ្ឋាន និងប្រធានកងយកទៅសម្លាប់ចោល។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីក៏ចាប់ផ្តើមស្រាវជ្រាវប្រវត្តិប្រជាជន១៧មេសា។ នៅពេលនោះ កងចល័តនារីនៅសេសសល់ប្រហែល៦០នាក់។

នៅយប់មួយ ប្រធានកងចល័តនារីឈ្មោះ ស្រ៊ាង បានដើរស្រង់ឈ្មោះអ្នកដែលមានប្រវត្តិជា ប្រជាជន១៧មេសា។ ខ្ញុំដឹងថាប្រជាជន១៧មេសានៅពេលនោះគឺត្រូវស្រង់ឈ្មោះបានចំនួន១៣នាក់ រួមទាំងឈ្មោះរបស់ខ្ញុំផងដែរ។ ប៉ុន្តែមិត្តនារី ស្រ៊ាង ដែលជាអតីតមិត្តរៀនថ្នាក់ទី១១នៅសាលាបឋមសិក្សាចុងកោះ ស្គាល់ខ្ញុំនិងមិនបានហៅខ្ញុំដើម្បីរៀបចំបាយពោតដើម្បីយកទៅសម្លាប់ចោលនោះទេ។ ចំណែកឯ អ្នក១២នាក់ផ្សេងទៀតត្រូវបានមិត្តនារី ស្រ៊ាង ប្រាប់ឲ្យរៀបចំបាយពោត និងយកទៅតាមខ្លួន។ នៅយប់ដដែល ប្រជាជន១៧មេសា បានផើបអង្គុយ និងពិភាក្សាគ្នាអំពីការរៀបចំបាយ និងការទៅកន្លែងមួយទៀត។ នៅពេលនោះមិត្តថាចដែលរៀនបានខ្ពង់ខ្ពស់ និងចប់ថ្នាក់មហាវិទ្យាល័យ និយាយទៅកាន់អ្នករាល់គ្នាថា «កុំទៅបារម្ភពេក ខ្មែរក្រហមមិនដែលសាហាវជាងហ៊ីត្លែរនោះទេ»។ ការលើកឡើងរបស់មិត្តថាចនៅពេលនោះគឺគាត់មិនជឿថា ខ្មែរក្រហម សម្លាប់ខ្មែរនោះឡើយ។ ប៉ុន្តែអ្វីដែលមិត្ត ថាច និយាយនោះគ្រាន់តែជាការយល់ខុស។ ខ្មែរក្រហមបានបណ្តើរអ្នកទាំង១២នាក់ ដែលត្រូវបានស្រង់ឈ្មោះ និងប្រាប់ឲ្យរៀបចំបាយយកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃក្បែរការដ្ឋាន ដែលខ្ញុំ និងអ្នកផ្សេងទៀតកំពុងធ្វើការ។

នៅឆ្នាំ១៩៧៨ ខ្ញុំទទួលបានដំណឹងថា ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ និងទម្លាក់ចោលក្នុងទន្លេ ពីព្រោះតែជាប់ប្រវត្តិជាប្រជាជន១៧មេសា។ បន្ទាប់ពី កងទ័ពវៀតណាមចូលមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំមិនបានរត់ទៅជាមួយ

ខ្មែរក្រហមមកពីភូមិភាគនិរតីនោះទេ។ ខ្ញុំបានវិលត្រឡប់មកភូមិទី៨វិញ ដើម្បីរស់នៅបន្តជាមួយជីដូននិងប្អូនម្នាក់ដែលរួចផុតពីការសម្លាប់នៅពេលនោះ។ នៅឆ្នាំ១៩៨០ ខ្ញុំបានចូលបង្រៀនកូនអ្នកភូមិនៅសាលាបឋមសិក្សាទីប្រជុំ និងក្រោយមកទៀតទទួលតួនាទីជានាយកសាលា។ បន្ទាប់ពីខ្ញុំចូលចូលនិវត្តន៍ ខ្ញុំលក់នំនិងអាហារនៅក្នុងសាលា និងបន្តបង្រៀនកូនអ្នកភូមិក្នុងនាមជាគ្រូកិច្ចសន្យាម្តង។

## ២) ជា ខេងថៃ ៖ ប្រធានមន្ទីរពាណិជ្ជកម្មតំបន់ ៤១ ក្នុងរបបខ្មែរក្រហម



ជា ខេងថៃ អាយុ៧០ឆ្នាំ ជាកសិករ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា ខេងថៃ អាយុ៧០ឆ្នាំ ជាកសិករ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំគឺជាគ្រូបង្រៀនចូលនិវត្តន៍កាលពីឆ្នាំ២០១១។ ខ្ញុំរៀបការប្រពន្ធឈ្មោះ យា ឆេងស៊ិន ដោយមានកូនចំនួន៤នាក់(ស្រី៣ និងប្រុស១)។ ខ្ញុំកើតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ ខ្ញុំមានឪពុកឈ្មោះ ជា ម៉េត និងម្តាយឈ្មោះ គា ណៃគីម។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៣នាក់។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាកំពង់ក្របីរហូតដល់ចប់ថ្នាក់ទី៧ និងបានប្រឡងជាប់ដើម្បីបន្តការរៀនសូត្រនៅវិទ្យាល័យព្រះសីហនុ។ ប្រហែលជា៣ខែបន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញមានបាតុកម្មដង្ហែចូលមកទីរួមខេត្តកំពង់ចាមរយៈពេល៣ថ្ងៃ។ នៅពេលនោះ ខ្ញុំរៀនថ្នាក់ទី៦។ បើទោះបីជាមានការធ្វើបាតុកម្មយ៉ាងណាក្តី ខ្ញុំនៅតែបន្តការសិក្សា និងស្នាក់អាស្រ័យជាមួយឪពុកមានៅទីរួមខេត្តកំពង់ចាម។ បន្ទាប់ពីបាតុកម្មបានបញ្ចប់ ការផ្ទុះអាវុធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានកើតឡើង។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ភូមិកំណើតរបស់ខ្ញុំដើម្បីត្រៀមវាយបន្ទាយ លន់ នល់ នៅម្តុំកោះរកា។ ខ្ញុំតែងតែមកលេងផ្ទះដោយដើរតាមផ្លូវវាង។ មូលហេតុដែលខ្ញុំមិនអាចមកតាមផ្លូវពីព្រែកដើមចាន់មកភូមិចំការសាមសិប គឺមានទាហាន លន់ នល់ ត្រូវបានដាក់ឈរជើងដើម្បីទប់ទល់ និងវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមនៅភូមិជិតនោះ។ ខ្ញុំបានបន្តរៀននៅវិទ្យាល័យព្រះសីហនុរហូតដល់ឆ្នាំ១៩៧៣ ត្រឹមថ្នាក់ទី៣។ ខ្ញុំបានឈប់រៀនបន្ទាប់ពីមកលេងផ្ទះនាពេលចុងសប្តាហ៍។ នៅពេលនោះ លោកតារបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា កុំវិលទៅរៀននៅទីរួមខេត្តកំពង់ចាម ព្រោះតែស្ថានការណ៍ច្របូកច្របល់។

ចាប់តាំងពីឆ្នាំ១៩៧៣ មក ខ្ញុំបានចូលបម្រើបដិវត្តន៍ និងត្រូវបានមិត្ត ជឿន ដែលជាមេភូមិក្នុងតំបន់រំដោះនាពេលនោះ ដាក់ចូលធ្វើការងារនៅកងពាណិជ្ជកម្មស្រុកកំពង់សៀម។ នៅក្នុងកងពាណិជ្ជកម្មស្រុកមានសមមិត្តប្រហែលជា១០នាក់ដែលមានតួនាទីដឹកជញ្ជូនសម្ភារប្រើប្រាស់ផ្សេងៗ។ នៅឆ្នាំ១៩៧៣ ដដែល ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៤១ ដែលមានមិត្ត ងួន គឺជាប្រធាន។ នៅពេលនោះ ខ្ញុំទទួលបានមុខងារជាអ្នកកត់ត្រា និងធ្វើបញ្ជីទំនិញសម្ភារប្រើប្រាស់។ នៅមន្ទីរពាណិជ្ជកម្មតំបន់៤១នេះ មានសមមិត្តទាំងអស់ចំនួន១០នាក់ ដែលត្រូវបានចាត់តាំងធ្វើការងារផ្សេងៗគ្នា។ សមរភូមិរវាងទាហានលន់នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើង។ កងពាណិជ្ជកម្មតំបន់៤១បានជិះកង់ទៅដឹកអ៊ីវ៉ាន់សម្ភារប្រើប្រាស់ពីព្រំប្រទល់វៀតណាម ដើម្បីយកមកចែកចាយនៅតាមស្រុកនានាក្នុងតំបន់។

បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានរំដោះនៅឆ្នាំ១៩៧៥ ខ្ញុំនៅបន្តធ្វើជាអ្នកកត់បញ្ជីឃ្លាំងនៅមន្ទីរពាណិជកម្មតំបន់៤១ដដែល ដែលស្ថិតនៅទីប្រជុំជន

ផ្ទាល់ទទឹង ស្រុកព្រៃឈរ។ ខ្ញុំមិនដែលបានមកលេងផ្ទះនោះឡើយ។ តាមអ្វីដែលខ្ញុំដឹងនោះគឺតំបន់៤១ ស្ថិតនៅភូមិភាគកណ្តាលដែលមាន កែ ពក គឺជាលេខាភូមិភាគ មានស្រុកចំណុះចំនួន ៥ រួមមាន៖ ស្រុកកំពង់សៀម (ហៅថាស្រុក៨៨), ស្រុកព្រៃឈរ (ហៅថាស្រុក៧៧), ស្រុកកងមាស (ហៅថាស្រុក១០១), ស្រុកជើងព្រៃ (ហៅថាស្រុក៨៤) និង ស្រុកបាធាយ (ហៅស្រុក៧៣)។ នៅឆ្នាំ១៩៧៦តំបន់៤១មានប្រធានឈ្មោះមិត្តតាំង។ ប្រធានមន្ទីរពាណិជ្ជកម្មតំបន់គឺមិត្ត សាន ដែលបានចាត់តាំងឲ្យខ្ញុំកត់ត្រាបញ្ជីសម្ភារប្រើប្រាស់ក្នុងឃ្លាំង។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកដល់ និងចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន។ នៅពេលនោះមិត្ត តាំង ប្រធានតំបន់ និងមិត្ត សាន ត្រូវបានចាប់ខ្លួន និងសម្លាប់។ មិត្ត ស៊ុប ប្រធានមន្ទីរសន្តិសុខតំបន់ គឺជាអ្នកដើរចាប់។ ប៉ុន្តែក្រោយមកមិត្ត ស៊ុប ត្រូវបានសម្លាប់ដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីវិញម្តង។ នៅក្នុងឆ្នាំដដែល សមមិត្ត អោ អាន ត្រូវបានផ្លាស់មកគ្រប់គ្រងតំបន់ ៤១ ។ បន្ទាប់ពីការមកដល់របស់ សមមិត្ត អោ អាន មានការចាប់ប្រធានកង និងកម្មាភិបាលមូលដ្ឋាននៅតាមស្រុកកាន់តែច្រើនឡើង។ ខ្ញុំត្រូវបានចាត់តាំងធ្វើជាប្រធានមន្ទីរពាណិជ្ជកម្ម។ ថ្នាក់លើប្រាប់ថា ខ្ញុំមិនទាន់ត្រូវបានចាប់យកទៅសម្លាប់នៅពេលនេះ ពីព្រោះតែមិនទាន់មានអ្នកជំនួសចេះធ្វើបញ្ជីនៅឃ្លាំង។ ចាប់តាំងពីពេលនោះមក ខ្ញុំបានកិនគ្រាប់ស្វែងនិងដាក់តាមខ្លួនរហូត។ នៅពេលដែលខ្ញុំត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម ខ្ញុំនឹងសម្លាប់ខ្លួនដោយការលេបគ្រាប់ស្វែងដែលកិនរួចជាស្រេចនោះ។ ខ្ញុំខ្លាចការធ្វើទារុណកម្ម។ រាល់ពេលខ្ញុំទៅមន្ទីរតំបន់៤១ ខ្ញុំតែងតែឮសូរការសួរចម្លើយ និងសម្រែកឈឺចុកចាប់ចេញពីការធ្វើទារុណកម្ម។ ខ្ញុំមិនចង់ជួបភាពឈឺចុកចាប់បែបនេះទេ។ មិនយូរមិនឆាប់ ខ្ញុំនឹងត្រូវបានចាប់ខ្លួន ដូច្នេះខ្ញុំបានត្រៀមគ្រាប់ស្វែងកិនដាក់តាមខ្លួន។ ក្នុងអំឡុងពេលធ្វើជាប្រធានមន្ទីរពាណិជ្ជកម្ម ខ្ញុំតែងតែដឹកនាំកងដឹកជញ្ជូនពាណិជ្ជកម្មទៅយកអំបិល សម្ភារប្រើប្រាស់ និងក្រណាត់ខ្មៅនៅមន្ទីរភូមិភាគកណ្តាលនៅម្តុំចំការលើ។ បន្ទាប់ពីដឹកអំបិល សម្ភារប្រើប្រាស់ និងក្រណាត់ចូលឃ្លាំងវិញមក មិត្ត អោ អាន លេខាតំបន់៤១ មិនអនុញ្ញាតឲ្យដឹកយកទៅចែកនៅតាមបណ្តាស្រុកក្នុងតំបន់នោះឡើយ រហូតដល់របស់ទាំងអស់នេះនៅសល់ពេញឃ្លាំង។ ខ្ញុំដឹងថា មិត្ត កែ ពក លេខាភូមិភាគ បានបញ្ជាឲ្យលេខាតំបន់៤១ គឺមិត្ត អោ អាន ធ្វើការចែកចាយសម្ភារប្រើប្រាស់ ជាពិសេសក្រណាត់ខ្មៅទៅកាន់ស្រុកផ្សេងៗ ប៉ុន្តែមិត្ត អាន មិនស្តាប់និងអនុវត្តតាមនោះឡើយ។

នៅថ្ងៃមួយចុងឆ្នាំ១៩៧៧ ខ្ញុំបានឡើងទៅដឹកសម្ភារប្រើប្រាស់បន្ថែមនៅមន្ទីរភូមិភាគ និងសរសេរសំបុត្រអនាមិកមួយរាយការណ៍ដល់លេខាភូមិភាគអំពីការមិនចែកចាយសម្ភារប្រើប្រាស់ ជាពិសេសក្រណាត់ខ្មៅនៅតំបន់៤១។ ពីរទៅបីថ្ងៃបន្ទាប់មក នីរសារភូមិភាគចំនួន២នាក់ ត្រូវបានបញ្ជូនមកដើម្បីពិនិត្យមើលឃ្លាំងនៅមន្ទីរពាណិជ្ជកម្មតំបន់ ៤១ ។ ប៉ុន្មានថ្ងៃក្រោយមក មិត្ត អាន បានឡើងទៅប្រជុំនៅមន្ទីរភូមិភាគ។ បន្ទាប់ពីការប្រជុំនៅមន្ទីរភូមិភាគ មិត្ត អាន បានបញ្ជាឲ្យកងពាណិជ្ជកម្មតំបន់ចាប់ផ្តើមចែកចាយសម្ភារ និងក្រណាត់ខ្មៅនៅតាមស្រុក និងសហករណ៍នៅក្នុងតំបន់៤១។ ខ្ញុំមានការព្រួយបារម្ភជាខ្លាំងពីការដែលអង្គការដឹងថា ខ្ញុំគឺជាអ្នកសរសេរសំបុត្រអនាមិកជូនលេខាភូមិភាគ។ នៅឆ្នាំ១៩៧៨ ខ្ញុំបន្តធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៤១។ នៅពេលដែលកងទ័ពវៀតណាមខិតចូលមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំត្រូវបានជម្លៀសជាមួយអ្នកផ្សេងទៀតទៅទិសខាងលិចប្រទេស។ ដោយសារតែភ័យខ្លាចការនាំទៅសម្លាប់ ខ្ញុំ និងមិត្ត៣នាក់ទៀតបានលួចឡានជិះរត់ទៅខាងចំការលើ និងបានទុកឡានចោលក្នុងចម្ការចេក។ ខ្ញុំបានបន្តដើរមកកាន់ភូមិកំណើតវិញ និងរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម។ នៅឆ្នាំ១៩៨១ ខ្ញុំចូលបង្រៀនសិស្សនៅសាលាបឋមសិក្សាកំពង់ក្របី និងចូលនិវត្តន៍អស់រយៈពេលជិត១០ឆ្នាំហើយ។

## ៣) ស្រេង ស៊ីថា៖ ខ្មែរក្រហមសម្លាប់ក្រុមគ្រួសារនិងម្តាយរបស់ខ្ញុំទាំងមានផ្ទៃពោះជិតគ្រប់ខែ

ខ្ញុំឈ្មោះ ស្រេង ស៊ីថា អាយុ៦២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្ត

កំពង់ចាម។ ខ្ញុំគឺជាអតីតគ្រូបង្រៀនថ្នាក់ទី១ នៅសាលាបឋមសិក្សាទីប្រជុំ។ ខ្ញុំរៀបការប្តីឈ្មោះ អ៊ុត ម៉ៅ និងមានកូនប្រុសស្រីទាំងអស់ចំនួន៤នាក់។ ខ្ញុំមានឪពុកឈ្មោះ ស ស្រេង គឺជានាយទាហានលន់ នល់ និងម្តាយឈ្មោះ មែន ជា។ ខ្ញុំគឺជាកូនទី៣ ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៧នាក់។ ខ្ញុំមានស្រុកកំណើតនៅភូមិចុងកោះដើង ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាទួលថ្មរ ហូតដល់បញ្ចប់ថ្នាក់ទី៧ចាស់។ ខ្ញុំបានប្រឡងចូលរៀនថ្នាក់ទី៦នៅ វិទ្យាល័យព្រះសីហនុ។



ស្រេង ស៊ីថា អាយុ៦២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម (ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពី មានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញមានការធ្វើបាតុកម្មនៅ ទីរួមខេត្តកំពង់ចាម។ បាតុកម្មបានអូសបន្លាយរយៈពេលប្រហែល២ទៅ៣ថ្ងៃ។ មិនយូរប៉ុន្មានបន្ទាប់ពីបាតុកម្មបានបញ្ចប់ សង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង។ នៅពេលនោះឪពុករបស់ខ្ញុំគឺជានាយទាហានលន់នល់ថ្នាក់អនុសេនីយ៍ឯក។ ចាប់ពីចុងឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧២ សង្គ្រាមរវាងទាហាន លន់ នល់ ដែលឈរជើងនៅព្រំប្រទល់ចូលទីរួមខេត្តកំពង់ចាម និងកងទ័ពរំដោះខ្មែរក្រហមដែលឈរជើងនៅតាមភូមិផ្ទុះកាន់តែខ្លាំងឡើង។ នៅឆ្នាំ១៩៧៣ ដោយបានឃើញស្ថានភាពមិនស្រួល ឪពុករបស់ខ្ញុំបាននាំគ្រួសារជិះយន្តហោះនៅព្រលានយន្តហោះស្ថិតនៅម្តុំវាលវង់ ខេត្តកំពង់ចាមមកទីក្រុងភ្នំពេញ។ បន្ទាប់មក ឪពុករបស់ខ្ញុំបានផ្លាស់ទៅធ្វើការនៅកំពង់សោម។ ខ្ញុំនិងក្រុមគ្រួសារបានទៅរស់នៅជាមួយឪពុកនៅទីនោះ។ នៅឆ្នាំ១៩៧៤ ឪពុករបស់ខ្ញុំត្រូវបានផ្លាស់មកភ្នំពេញវិញ។ នៅពេលនោះ ឪពុកនិងម្តាយខ្ញុំបានទិញផ្ទះមួយនៅម្តុំវត្តទឹកល្អក់។ ខ្ញុំបានចូលរៀននៅសាលាឯកជនមួយឈ្មោះ តារាសាស្ត្រ ដោយបានរៀនត្រឹមថ្នាក់ទី៤។ ប៉ុន្មានខែបន្ទាប់ ឪពុករបស់ខ្ញុំទទួលបានតួនាទីជាបាឡាត់ខេត្តកំពត។ នៅពេលនោះ ឪពុករបស់ខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តកំពតតាមរយៈយន្តហោះខ្នាតតូច ពីព្រោះតែការធ្វើដំណើរតាមផ្លូវជាតិ គឺមិនមានសុវត្ថិភាព និងអាចទទួលរងការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហម។ ម្តាយ និងបងប្អូនខ្ញុំផ្សេងទៀត គឺបន្តរស់នៅទីក្រុងភ្នំពេញ។ នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមខិតជិតចូលមកដល់ទីក្រុងភ្នំពេញ ឪពុករបស់ខ្ញុំសម្រេចចិត្តជិះយន្តហោះខ្នាតតូចវិលត្រឡប់មកភ្នំពេញដើម្បីជួបជុំជាមួយគ្រួសារ។ ឪពុកខ្ញុំបានមកដល់ផ្ទះវិញ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គឺមួយថ្ងៃមុនពេលកងទ័ពរំដោះខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ នៅវេលាប្រហែលម៉ោង៨រសៀល ខ្ញុំឮសូរការទម្លាក់គ្រាប់បែកនៅម្តុំខ្ញុំរស់នៅ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ។ កងទ័ពខ្មែរក្រហមបានមកគោះទ្វារផ្ទះ ប៉ុន្តែឪពុកខ្ញុំបានប្រាប់ថាសុំស្នាក់នៅផ្ទះមួយយប់សិន។ នៅព្រឹកថ្ងៃបន្ទាប់គឺថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានមកប្រាប់គ្រួសារខ្ញុំឲ្យចាកចេញពីទីក្រុងភ្នំពេញត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ។ ភ្លាមនោះ ម្តាយខ្ញុំបានរៀបចំយកមុង ភួយ និងខោអាវខ្លះៗ មុនពេលចាកចេញពីផ្ទះ។ គ្រួសាររបស់ខ្ញុំដើរតាមផ្លូវទឹកល្អក់ រហូតដល់អង់តែនទួលគោក ឆ្ពោះទៅគីឡូម៉ែត្រលេខ៦ និងបន្តទៅព្រែកក្តាមដើម្បីឆ្លងទន្លេទៅខាងកំពង់ចាម។ ខ្ញុំឃើញមានប្រជាជនជាច្រើននាក់ដើរពាសពេញផ្លូវទៅព្រែកក្តាម។ គ្រួសារខ្ញុំបានដើរ៤ថ្ងៃទើបទៅដល់កំពង់ចម្លងព្រែកក្តាម។ ខ្ញុំនៅចាំបានថា កងទ័ពខ្មែរក្រហមបានស្កាត់សួរអំពីប្រវត្តិរបស់ប្រជាជនជម្លៀសពីភ្នំពេញ។

ការសួរសាកស្តាត់សួរអំពីប្រវត្តិលើកទី១ គឺនៅក្នុងវត្តមួយ ដែលខ្ញុំមិនបានចាំឈ្មោះវត្តនោះទេ។ នៅពេលនោះ ឪពុករបស់ខ្ញុំប្រាប់កងទ័ពខ្មែរក្រហមថា គាត់គឺជាអ្នកបើកឡាននៅភ្នំពេញ។ ការស្ពាត់សួរអំពីប្រវត្តិលើកទី២ គឺនៅម្តុំការកោង។ ប្រជាជនជាច្រើននាក់ដែលត្រូវបានស៊ើបដឹងថា ធ្លាប់បម្រើការជាគ្រូបង្រៀនទាហាន ឬមន្ត្រីក្នុងរបប លន់ នល់ ត្រូវបានកងទ័ពខ្មែរក្រហមមិនអនុញ្ញាតឲ្យបន្តដំណើរទៅមុខទៀតនោះទេ និងក្រោយមកត្រូវបានយកទៅសម្លាប់ចោល។ គ្រួសារខ្ញុំបន្តដំណើរទៅដល់ភូមិត្រពាំងស្នោរ និងបានស្នាក់នៅប្រហែល១ខែ។

នៅខែមិថុនា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំបានលួចរត់ទាំងយប់ចេញពីភូមិត្រពាំងស្នោរ ដើម្បីមកភូមិកំណើតរបស់ជីដូន ដែលកំពុងរស់នៅភូមិប្រមាត់ដី ឃុំស្វាយទាប ស្រុកចំការលើ។ ចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៧ ខ្ញុំចូលធ្វើការក្នុងកងចល័តនារីឃុំស្វាយទាប ដោយបានដើរលើកទំនប់ ជីកដី និងភ្ជួររាស់។ ចំណែកឯឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅតាមកងចល័តរៀងៗខ្លួន។ នៅថ្ងៃមួយ ខ្ញុំនិងកងចល័តនារីផ្សេងទៀតត្រូវបានប្រាប់ទៅប្រជុំនៅផ្ទះលេខាភូមិភាគ គឺសមមិត្ត កែ ពក។ នៅពេលនោះ ខ្ញុំឃើញមានកងចល័តជាច្រើនបានអង្គុយប្រជុំ។ មិត្ត កែ ពក បាននិយាយឲ្យខិតខំធ្វើការងារ។

នៅឆ្នាំ១៩៧៨ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ប្តូរទៅលើកទំនប់នៅខេត្តកំពង់ធំគឺទំនប់១មករា អស់រយៈពេល៣ខែ។ ការដ្ឋានទំនប់១មករាមិនទាន់បញ្ចប់នៅឡើយទេ ប៉ុន្តែកងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់មកកាន់ភូមិប្រមាត់ដីវិញ។ បន្ទាប់ពីមកដល់ភូមិបានប្រហែល២ទៅ៣ខែ ខ្ញុំត្រូវបានមិត្ត រឿន ដែលជាប្រធានកងចល័តឃុំ ជ្រើសរើសចូលក្នុងកងកម្លាំងស្រួច ដែលមានសមមិត្តប្រហែល២៥នាក់ ដើម្បីទៅធ្វើការនៅកន្លែងនេសាទត្រីនៅខេត្តកំពង់ធំ និងទៅបោចវល្លិនៅខេត្តព្រះវិហារ។ ខ្ញុំបាននិយាយលាឪពុកម្តាយ និងបងប្អូនមុនពេលចាកចេញដំណើរទៅ។ បន្ទាប់ពីបានទៅធ្វើការឆ្ងាយពីភូមិរយៈពេល៣ខែ ខ្ញុំបានសុំច្បាប់មកលេងផ្ទះបាន៣ថ្ងៃ។ នៅពេលដែលខ្ញុំចេញពីផ្ទះវិលត្រឡប់ទៅធ្វើការងារវិញ ប្អូនប្រុសរបស់ខ្ញុំបានសុំខ្ញុំទៅជាមួយ។ ប៉ុន្តែខ្ញុំមិនបានយកប្អូនទៅជាមួយទេ ពីព្រោះខ្ញុំធ្វើការបោចវល្លិនៅក្នុងព្រៃក្បែរភ្នំត្បែង ដែលពិបាករស់នៅណាស់។ ៤ថ្ងៃបន្ទាប់ពីខ្ញុំចាកចេញពីផ្ទះលើកនេះ ខ្ញុំទទួលបានដំណឹងថា គ្រួសាររបស់ខ្ញុំរួមមានឪពុកម្តាយដែលកំពុងពពោះជិតគ្រប់ខែ និងបងប្អូនទាំងអស់ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់។ នៅពេលទទួលដំណឹងការស្លាប់របស់គ្រួសារ ខ្ញុំគ្មានព្រលឹងក្នុងខ្លួននោះឡើយ។ ប៉ុន្តែមិត្ត រឿន បាននិយាយលើកទឹកចិត្តខ្ញុំឲ្យពង្រឹងស្មារតីក្នុងការធ្វើការងារ ពីព្រោះខ្ញុំត្រូវបានដាក់ស្ថិតនៅក្នុងប្រជាជនមានប្រវត្តិមិនល្អ ដែលប្រឈមការចាប់យកទៅសម្លាប់គ្រប់ពេលវេលា។

នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ទីរួមខេត្តកំពង់ចាម កងចល័តទាំងអស់ត្រូវបានរំសាយ។ នៅពេលនោះ ខ្ញុំនិងមិត្តនារី៣នាក់ទៀតបានថែវទូកតាមទន្លេមកភូមិវិញ និងត្រូវបានស្ពាត់ដោយកងទ័ពខ្មែរក្រហមដែលសេសសល់។ ប៉ុន្តែខ្ញុំនិងមិត្តនារីទាំងនេះត្រូវបានដោះលែង និងបន្តថែវទូករហូតមកដល់ភូមិវិញ។ ខ្ញុំដឹងថា មានប្រជាជនជាច្រើនគ្រួសារក៏បានថែវទូកនៅពីក្រោយខ្ញុំ ប៉ុន្តែត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងអស់។ ខ្ញុំរួចផុតពីសេចក្តីស្លាប់នាពេលនោះ ប៉ុន្តែបានបាត់បង់សមាជិកគ្រួសារទាំងអស់។

នៅឆ្នាំ១៩៨០ ខ្ញុំបានផ្លាស់មករស់នៅភូមិទី៨ ស្រុកកោះសូទិន។ នៅឆ្នាំ២០១០ ខ្ញុំចាប់ផ្តើមបង្រៀនសិស្សនៅសាលាបឋមសិក្សាទីប្រជុំរហូតដល់ចូលនិវត្តន៍នៅឆ្នាំ២០២០។ បច្ចុប្បន្នខ្ញុំលក់ដូរបន្តិចបន្តួចនៅផ្ទះដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

## ៤) លឹម អេង ៖ អតីតកងនេសាទក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ លឹម អេង អាយុ៧៥ឆ្នាំ រស់នៅក្នុងភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំគឺជាកសិករ ប៉ុន្តែដោយសារតែជរាភាព ខ្ញុំមិនបានធ្វើអ្វីទៀតទេ។ ខ្ញុំរៀបការប្រពន្ធឈ្មោះ សេត ឡាង និងមានកូនចំនួន៦នាក់។ ខ្ញុំកើតនៅភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន នេះតែម្តង។ ខ្ញុំមានឪពុកឈ្មោះ គុយ លឹម និងម្តាយឈ្មោះ អោ សេន។ ខ្ញុំគឺជា

កូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាវត្តចុងកោះសូទិន និងបន្តការសិក្សានៅទីរួមខេត្តកំពង់ចាម។ ខ្ញុំរៀននៅសាលាឯកជនមួយ ដើម្បីត្រៀមប្រឡងចូលថ្នាក់ទី៣សង្គមចាស់។ ក្រោយមកទៀត ខ្ញុំសម្រេចចិត្តទៅរៀននៅសាលាព្រែកដំណឹង ស៊ីធរកណ្ដាល ខេត្តព្រៃវែងវិញ ពីព្រោះខ្ញុំមានឪពុកមារស់នៅទីនោះ។ ក្នុងពេលដែលខ្ញុំកំពុងស្នាក់នៅ និងរៀននៅស៊ីធរកណ្ដាល ខ្ញុំឮដំណឹងថាមានរដ្ឋប្រហារទម្លាក់សម្ដេចឪ។ បន្ទាប់មក បងប្អូនខ្ញុំបានបបួលខ្ញុំទៅចូលធ្វើជាទាហានលន់ នល់ នៅទីក្រុងភ្នំពេញ។ ខ្ញុំមិនទៅនោះទេ។ បាតុកម្មបានផ្ទុះឡើង និងដង្ហែទៅទីរួមខេត្ត



លឹម អេង អាយុ៧៥ឆ្នាំ រស់នៅក្នុងភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។
( ស៊ាង ចិន្ដា / មជ្ឈមណ្ឌលឯកសារកម្ពុជា )

កំពង់ចាម។ ដោយឃើញស្ថានភាពមិនស្រួល ខ្ញុំបានវិលត្រឡប់មករស់នៅភូមិជួបជុំជាមួយគ្រួសារវិញ។

នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ក្នុងភូមិ និងស្នាក់អាស្រ័យនៅក្រោម ឬក្រោយផ្ទះរបស់អ្នកភូមិ។ ពេលនោះគឺជាវេលានៃការផ្ទុះអាវុធរវាងទាហានលន់ នល់ ដែលឈរជើងនៅត្រើយម្ខាង និងទីរួមខេត្តកំពង់ចាម និងកងទ័ពរំដោះខ្មែរក្រហម ដែលឈរជើងនៅភូមិនានាក្នុងស្រុកកោះសូទិន។ ភូមិទី៩ ទទួលរងការផ្លោងគ្រាប់កាំភ្លើងធំដែលបានបាញ់ចេញពីភ្នំស្រីភ្នំប្រុសយ៉ាងខ្លាំង។ នៅក្នុងឆ្នាំ១៩៧១ដដែល គ្រួសារខ្ញុំបានរត់ភៀសខ្លួនចេញពីភូមិទៅរស់នៅជាមួយបងប្អូននៅភូមិព្រែកឃ្មុំ ឃុំព្រែកឃ្មុំ ស្រុកស៊ីធរកណ្ដាល ដែលជាតំបន់រំដោះខ្មែរក្រហម។ បន្ទាប់ពីបានទៅដល់ ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាគ្រូបង្រៀនមូលដ្ឋាន។ ខ្ញុំត្រូវបានបញ្ជូនទៅរៀនវគ្គបណ្ដុះបណ្ដាលអស់រយៈពេល៣ខែ។ បន្ទាប់ពីវគ្គបណ្ដុះបណ្ដាលបានបញ្ចប់ ខ្ញុំបានបង្រៀនថ្នាក់ទី៣នៅសាលាបឋមសិក្សាស្វាយទាប ដែលមានមិត្ត ឈាន គឺជានាយកសាលា។

នៅឆ្នាំ១៩៧៣ ខ្ញុំរៀបការប្រពន្ធឈ្មោះ សេត ឡាង និងទៅរស់នៅជាមួយគ្រួសារខាងប្រពន្ធ។ ដោយសារតែផ្ទះគ្រួសារខាងប្រពន្ធស្ថិតនៅឆ្ងាយ ខ្ញុំបានឈប់បង្រៀន។ ក្រោយមកទៀត ខ្ញុំស្ម័គ្រចិត្តចូលធ្វើជាពេទ្យ និងត្រូវបានបញ្ជូនទៅរៀនវគ្គបណ្ដុះបណ្ដាលរយៈពេល៣ខែ ដើម្បីរៀនអំពីការចាក់ថ្នាំ ផ្សំថ្នាំ និងពិនិត្យមើលអាការជំងឺ។ បន្ទាប់ពីរៀនចប់ ខ្ញុំត្រូវបានចាត់តាំងធ្វើជាពេទ្យប្រចាំភូមិដើម្បីពិនិត្យ និងព្យាបាលប្រជាជនមូលដ្ឋាន។ នៅចុងឆ្នាំ១៩៧៣ មេភូមិ ដែលខ្ញុំមិនបានចាំឈ្មោះ បានជ្រើសរើសពេទ្យជំនាញវះកាត់។ នៅពេលនោះ បងថ្លៃខ្ញុំដែលជាពេទ្យមូលដ្ឋានបានស្ម័គ្រចិត្តចូលរៀនជំនាញពេទ្យវះកាត់ និងត្រូវបានបញ្ជូនទៅរៀន ប៉ុន្តែបងថ្លៃខ្ញុំមិនដែលវិលត្រឡប់មកភូមិវិញទេ។ នៅឆ្នាំ១៩៧៤ ខ្ញុំនាំប្រពន្ធ និងកូនមករស់នៅភូមិទី៩ ដែលជាភូមិកំណើតវិញ។ នៅពេលដែលត្រៀមឆ្លងទន្លេមកភូមិ ម៉ារីន ទាហានលន់ នល់ បានបើកចុះឡើងដើម្បីបាញ់បើកផ្លូវឡើងទៅកំពង់ចាម។ ខ្ញុំនិងប្រពន្ធកូន ស្នាក់នៅម្ដុំកោះចិនមួយយប់សិន។ នៅពេលដែលសភាពការណ៍ស្ងប់ស្ងាត់ទើបវិលត្រឡប់មកវិញ ខ្ញុំនិងប្រពន្ធកូនជួលទូកជិះឆ្លងទន្លេមករស់នៅភូមិវិញ។

នៅឆ្នាំ១៩៧៥ ខ្ញុំនិងគ្រួសាររស់នៅក្នុងភូមិ។ នៅឆ្នាំ១៩៧៦ ខ្ញុំចាំបានថា គឺជាពេលដែលខ្ញុំនិងអ្នកភូមិផ្សេងទៀតចាប់ផ្ដើមហូបបាយរួម។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកងនេសាទភូមិ ដែលមានគ្នាចំនួន១០នាក់ សម្រាប់រកត្រីមកឲ្យរោងបាយ។ កងនេសាទមានខ្មែរ-អ៊ីស្លាម មិត្តលាស់ មិត្តកូប និងមិត្តម៉ាន ដែលជាអ្នកជំនាញជួសមង ឬដោះមងដែលជាប់នៅបាតទន្លេ។ ប្រធានកងនេសាទឈ្មោះ វែង ថៃ និង

មានលាយចាមខ្លះដែរឈ្មោះ លាស់ កូប ម៉ាន។ កងនេសាទរបស់ខ្ញុំគឺធ្វើការចាប់ពីពាក់កណ្ដាលយប់ ដោយបានរាយមងនៅកណ្ដាលទន្លេ និងចូលមកសម្រាកវិញ។ រហូតដល់ម៉ោង៦ព្រឹក កងនេសាទបានថែវទូកទៅលើកមងជាប់ត្រីដូចជា ត្រីគល់រាំង ត្រីក្អែក និងត្រីព្រួលជាដើម។ បន្ទាប់មក កងដឹកជញ្ជូនបានដឹកត្រីដែលរកបានទៅរោងបាយរួមដើម្បីធ្វើម្ហូបឲ្យអ្នកភូមិ។ នៅឆ្នាំ១៩៧៧ ខ្ញុំឃើញមានកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីក្មេងចាស់ចូលមកដល់ក្នុងភូមិ។ ខ្ញុំមិនហ៊ានសូម្បីតែមើលមុខ។ ខ្ញុំបន្តធ្វើការនៅកងនេសាទ និងពេលខ្លះមកលេងប្រពន្ធ និងកូននៅផ្ទះ។ ក្រោយមក មិត្ត លាស់ មិត្តកូប និងមិត្តម៉ាន នៅកងនេសាទភូមិ ត្រូវបានចាប់ខ្លួនយកទៅសម្លាប់។ ខ្ញុំមិនដឹងថាអង្គការសម្លាប់នៅកន្លែងណាទេ។ ខ្ញុំធ្វើការនៅកងនេសាទ រហូតដល់កងទ័ពវៀតណាមចូលមកដល់នៅដើមឆ្នាំ១៩៧៩។ ខ្ញុំនិងគ្រួសាររួចផុតជីវិតពីរបបខ្មែរក្រហម និងប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតរហូតដល់ពេលបច្ចុប្បន្ននេះ។



សេត ឡាង អាយុ៧០ឆ្នាំ រស់នៅភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។
( ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា )

## ៥) សេត ឡាង ៖ អតីតកងចល័តនារីក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ សេត ឡាង អាយុ៧០ឆ្នាំ រស់នៅភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំកើតនៅភូមិសាមគ្គី ឃុំព្រែកញ្ញៅ ស្រុកពារាំង ខេត្តព្រៃវែង។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៣នាក់។ នៅពីក្មេង ខ្ញុំទៅរៀនសូត្រនៅសាលាបឋមសិក្សាវត្តសាមគ្គី។ ខ្ញុំឈប់រៀន និងជួយការងារផ្ទះ និងមើលប្អូនៗតូច ពីព្រោះម្ដាយរបស់ខ្ញុំបានស្លាប់ចោល។

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចឪនៅឆ្នាំ១៩៧០ ខ្ញុំឃើញមានអ្នកភូមិជាច្រើនបានចូលរួមបាតុកម្មដើម្បីទាមទារអំណាចថ្វាយសម្ដេចឪវិញ។ នៅឆ្នាំ១៩៧៣ ខ្ញុំរៀបការប្ដី និងផ្លាស់ទៅរស់នៅស្វាយទាប។ នៅឆ្នាំ១៩៧៤ ខ្ញុំបានមករស់នៅជាមួយប្ដី នៅភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧៥ ខ្ញុំបង្កើតបានកូនម្នាក់។ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការងារនៅកងចល័តនារីភូមិ និងបានទៅធ្វើការងាររួមមានរែកដី ជីកប្រឡាយ កាប់ពោត និងដាំដំណាំនៅជុំវិញកោះសូទិន។ នៅពេលយប់ ខ្ញុំមកសម្រាកនៅផ្ទះជាមួយកូន និងម្ដាយ។ ខ្ញុំធ្វើការចាប់ពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់ ឈប់សម្រាកហូបបបរលាយពោត។ ខ្ញុំបន្តការងារចាប់ពីម៉ោង១រសៀលដល់ម៉ោង៥ល្ងាច។ ខ្ញុំធ្វើការនៅកងចល័តនារី រហូតដល់កងទ័ពវៀតណាមចូលមកដល់នៅដើមឆ្នាំ១៩៧៩។ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម ខ្ញុំបានជួបជុំជាមួយប្ដី និងប្រកបរបរធ្វើចម្ការដើម្បីចិញ្ចឹមជីវិត។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

## ៦) ឡុង គីមស្រ៊ាង ៖ អតីតប្រធានកងរយក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ ឡុង គីមស្រ៊ាង អាយុ៦៤ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្ដីឈ្មោះ ថៃ ម៉ុកហេង និងមានកូនប្រុសស្រីចំនួន៦នាក់។ បច្ចុប្បន្ននេះ ខ្ញុំមិនមានមុខរបរអ្វីទេ គឺគ្រាន់តែធ្វើការងារស៊ីឈ្នួលដើម្បីបានលុយខ្លះទិញអង្ករ និងម្ហូប។ ខ្ញុំកើតនៅភូមិទី៧នេះតែម្ដង។ ខ្ញុំមានឪពុកឈ្មោះ មាន និងម្ដាយឈ្មោះ ស៊ិន។ នៅវ័យកុមារ ខ្ញុំរៀននៅសាលាបឋមសិក្សាវត្តគ្រួអ្នក ត្រឹមថ្នាក់ទី១០ចាស់។ នៅឆ្នាំ១៩៧០ បាតុកម្មបានកើតឡើង។ ខ្ញុំឃើញអ្នកភូមិជាច្រើនចូលរួមបាតុកម្មដង្ហែទៅទីរួមខេត្តកំពង់ចាម បន្ទាប់ពីរដ្ឋប្រហារទម្លាក់



ឡុង គីមស្រ៊ាង អាយុ៦៤ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្តេចឪ។ នៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ កងទ័ពរំដោះខ្មែរក្រហមចាប់ផ្តើមចូលមកក្នុងភូមិជាបណ្តើរៗ និងសុំផ្ទះអ្នកភូមិដើម្បីស្នាក់អាស្រ័យ។ នៅឆ្នាំ១៩៧៣ ខ្ញុំឃើញមានយន្តហោះទ្រូងជ្រូកហោះមកទម្លាក់គ្រាប់បែកយ៉ាងខ្លាំងនៅភូមិ។ ពេលនោះ ខ្ញុំរត់ភៀសខ្លួនទៅរស់នៅភូមិមហាលាភ ដែលមានបងប្អូនខាងឪពុកខ្ញុំនៅទីនោះ។

នៅឆ្នាំ១៩៧៥ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារតែជំងឺ។ ខ្ញុំវិលត្រឡប់មកភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៦ ខ្ញុំចូលធ្វើការនៅក្នុងកងចល័តនារី និងកងចុងភៅរោងបាយរួម ស្ថិតនៅកណ្តាលកោះសូទិន។ មិត្ត ជុន គឺជាប្រធានក្តាប់រួមកងចល័តភូមិនាពេលនោះ។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានដាក់ឲ្យធ្វើជាប្រធានកងរយ ដែលមនុស្សចំនួន៩៧នាក់។ កងចល័តរយគឺមានទិសដៅធ្វើការងារនៅការដ្ឋានស្រែ និងការដ្ឋានគំរិល ស្ថិតនៅខាងអូររាំងឪ។ នៅឆ្នាំ១៩៧៧ដដែល ខ្ញុំទទួលបានបទបញ្ជាឲ្យស្រង់ឈ្មោះមិត្តចំនួន៣៤នាក់ ដែលកំពុងធ្វើការនៅក្នុងកងចល័តរយនេះ។ ដោយគ្មានជម្រើសអ្វីឡើយ ខ្ញុំបានដើរស្រង់ឈ្មោះមិត្ត ៣៤នាក់នោះ និងប្រគល់ដល់ប្រធានក្តាប់ធំគឺមិត្តជុន។ នៅថ្ងៃបន្ទាប់ ខ្ញុំដឹងថាឈ្មោះមិត្តទាំង៣៤នាក់នោះត្រូវបានសម្លាប់នៅទីវាលក្រោយភូមិដែលជិតទីតាំងសម្លាប់នោះគឺជាគុកចាន់អណ្តែត។

នៅឆ្នាំ១៩៧៨ ខ្ញុំបន្តនាំកងចល័តរយដែលមានមិត្តនៅសេសសល់ចំនួន៦០នាក់ជាង ទៅធ្វើការនៅការដ្ឋានគំរិល។ រហូតដល់ចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនមកភូមិវិញ និងធ្វើការនៅកងដាំបាយនៅរោងបាយរួម។ នៅចុងឆ្នាំ១៩៧៨ដដែល ខ្ញុំឮដំណឹងអំពីសារាចរឈប់សម្លាប់មនុស្ស។ នៅឆ្នាំ១៩៧៩ ខ្ញុំរួចផុតជីវិតពីរបបខ្មែរក្រហម និងរៀបការប្តី។ ខ្ញុំនិងគ្រួសារប្រកបរបរជាកសិករ។

## ៧) ទីន ញ៉ ៖ អតីតកងចល័តវ័យកណ្តាលក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ ទីន ញ៉ អាយុ៧០ឆ្នាំ រស់នៅភូមិដំណាក់ព្រីង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំគឺជាដូនជីនៅវត្តដំណាក់ព្រីង។ ខ្ញុំមានប្តីឈ្មោះ ឈៀង ឈាន និងកូនចំនួន៤នាក់(ប្រុស៣ស្រី១)។ ខ្ញុំកើតនៅភូមិទី៥ ឃុំអំពិលពក ស្រុកអូររាំងឪ។ ខ្ញុំមានឪពុកឈ្មោះ សាំង ទីន និងម្តាយឈ្មោះ ពិន ឃឹម។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៧នាក់។ កាលពីក្មេង ខ្ញុំរៀននៅសាលាវត្តស្វាយតាមឹងត្រឹមថ្នាក់ទី១១ចាស់។ បន្ទាប់មក ខ្ញុំឈប់រៀនដោយសារតែជីវភាពលំបាក និងបានមកជួយធ្វើការងារឪពុកម្តាយនៅផ្ទះ និងមើលគោ។

នៅឆ្នាំ១៩៧០ ខ្ញុំដឹងថាមានរដ្ឋប្រហារ លន់ នល់កើតឡើង។ បន្ទាប់ពីរដ្ឋប្រហារកើតឡើងមិនយូរប៉ុន្មានផងបាតុកម្មបានផ្ទុះឡើង និងដង្ហែតាមដងផ្លូវ។ ខ្ញុំក៏បានចូលរួមការដង្ហែរបាតុកម្ម ប៉ុន្តែមិនបានទៅណាឆ្ងាយទេ គឺទៅដល់ពាមជាំង និងបានដើរត្រឡប់មកផ្ទះវិញ។ នៅពេលនោះ ខ្ញុំឃើញអ្នកចូលរួមបាតុកម្មបានចាប់ប្អូនប្រុសរបស់ លន់ នល់ គឺឈ្មោះ លន់ និល។ បាតុករបានវ៉ាយដំ និងបណ្តើរ លន់ និល ទាំងហូរឈាមពេញខ្លួនចេញពីបន្ទាយវាំងសែងយកទៅសម្លាប់ចោលនៅម្តុំផ្សារអូររាំងឪ។ នៅចុងឆ្នាំ១៩៧០ មានវត្តមានកងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិ។ ប្អូនប្រុសរបស់ខ្ញុំបានស្ម័គ្រចិត្តចូលព្រៃម៉ាគីដើម្បីតស៊ូប្រឆាំងរបប លន់ នល់។ ខ្ញុំត្រៀមរត់ចូលព្រៃម៉ាគីដែរ ប៉ុន្តែគ្មានអ្នកនាំទៅ។

នៅឆ្នាំ១៩៧១ ខ្ញុំរៀបការប្តី។ នៅឆ្នាំ១៩៧២ ខ្ញុំបង្កើតបានកូនប្រុសម្នាក់។ នៅភូមិសាស្ត្រអូររាំងឪ តែងតែមានយន្តហោះមកទម្លាក់គ្រាប់បែក។ នៅថ្ងៃមួយ យន្តហោះអាដើងបក្តុងបានហោះហើរក្រឡឹងចុះឡើង



ទិន ញ៉ អាយុ៧០ឆ្នាំរស់នៅភូមិដំណាក់ព្រីង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។
( ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា )



ស៊ីង គីមស្រ៊ុន អាយុ៧២ឆ្នាំ រស់នៅក្នុងភូមិទី៨ ស្រុកកោះសូទិន ខេត្តកំពង់ចាម។
( ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា )

ប្រហែល២០នាទី និងបាញ់ផ្សែងជាសញ្ញា។ បន្ទាប់មកយន្តហោះអាស្គាបកាត់បានហោះមកទម្លាក់គ្រាប់បែកចាប់ពីម៉ោង១២ថ្ងៃត្រង់ដល់ម៉ោង៥ល្ងាច។ ខ្ញុំនាំកូនរត់ចូលក្នុងរណ្ដៅត្រង់សេ។ នៅឆ្នាំ១៩៧២ ខ្ញុំនិងគ្រួសាររត់ភៀសខ្លួនទៅភូមិ មាសស្នេហ៍ ឃុំអំពិលពក។ រយៈពេល៣ខែក្រោយមក គ្រួសារខ្ញុំបានវិលត្រឡប់មកផ្ទះវិញ។ នៅឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ខ្ញុំបន្តរស់នៅផ្ទះ។

រហូតដល់បែកទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានដាក់ចូលធ្វើការនៅកងចល័តវ័យកណ្ដាល ដើម្បីទៅធ្វើការងាររួមមាន លើកដី ធ្វើស្រែ និងដាំដំណាំនៅក្នុងភូមិ។ កងចល័តវ័យកណ្ដាលមានគ្នាប្រហែល៤០នាក់ និងមានប្រធានឈ្មោះ មិត្ត យឿន។ ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវទៅធ្វើការដកស្ទូងស្រូវនៅតាមសហករណ៍។ នៅឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកចាប់ប្រធានកង មេភូមិ និងកម្មាភិបាលមូលដ្ឋាន ដើម្បីយកទៅសួរចម្លើយ និងសម្លាប់ចោល។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅជ្រែជីសួរបានមួយរយៈ។ ក្រោយមកទៀត ខ្ញុំត្រូវបានអង្គការឲ្យទៅធ្វើការនៅខាងពារាំង។ នៅពេលនោះខ្ញុំបានប្រកែកមិនទៅ ពីព្រោះប្ដីខ្ញុំកំពុងតែឈឺនៅពេទ្យ។ ប៉ុន្មានថ្ងៃក្រោយមក ប្ដីរបស់ខ្ញុំបានស្លាប់ដោយសារតែគ្មានថ្នាំព្យាបាល។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំឮសំឡេងគ្រាប់បាញ់គ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ ខ្ញុំរួចផុតពីសេចក្ដីស្លាប់ក្នុងរបបខ្មែរក្រហម និងបន្តជីវិតរស់នៅជាកសិករ។

## ៨) ស៊ីង គីមស្រ៊ុន ៖ អតីតកងចល័តវ័យកណ្ដាល

ខ្ញុំឈ្មោះ ស៊ីង គីមស្រ៊ុន អាយុ៧២ឆ្នាំ រស់នៅក្នុងភូមិទី៨ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានមុខរបរជាកសិករធ្វើស្រែចម្ការ។ ខ្ញុំមានភូមិកំណើតនៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ កៅ ឡេង និងម្ដាយឈ្មោះ ពិន ស្រ៊ី។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧ នាក់។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាគ្រួអ៊ុក។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ចាស់។ ខ្ញុំឈប់រៀននៅអាយុ១៣ឆ្នាំ ដើម្បីមកជួយការងារឪពុកម្ដាយនៅផ្ទះ និងមើលប្អូនៗ។ នៅអាយុ១៥ឆ្នាំ ខ្ញុំរៀបការប្ដី ដែលធ្វើជាប៉ូលីស នៅជីហែ។ ខ្ញុំបានទៅរស់នៅជាមួយប្ដីនៅជីហែ។ មួយរយៈក្រោយមក ប្ដីខ្ញុំត្រូវបានផ្លាស់ទៅត្រពាំងថ្កូង។ នៅពេលនោះ ខ្ញុំបង្កើតកូនបាន១នាក់ និងវិលមករស់នៅជីហែវិញ។

បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅដើមឆ្នាំ១៩៧០ បាតុកម្មបានផ្ទុះឡើង និងដង្ហែទៅទីរួមខេត្តកំពង់ចាម។ អ្នកភូមិជាច្រើនបានចូលរួមបាតុកម្មនោះ។ ខ្ញុំបានមករស់នៅផ្ទះជាមួយម្ដាយខ្ញុំនៅកោះសូទិន។ នៅឆ្នាំ១៩៧១ ខ្ញុំឃើញកងទ័ពរំដោះខ្មែរក្រហមចូល

មកដល់ភូមិ។ ប្តីខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការងារនៅភស្តុភារនៅខេត្តព្រៃវែង។ នៅពេលនោះ ប្តីខ្ញុំមិនដែលមកលេងផ្ទះនៅកោះសូទិនទេ។ នៅឆ្នាំ១៩៧៣ ភូមិទី៨ គឺជាសមរភូមិក្តៅរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ទាហានលន់នល់បានទម្លាក់គ្រាប់បែកជាច្រើនទៅលើទីតាំងដែលមានកងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៤ ខ្ញុំរត់គេចខ្លួនជាមួយកូនទៅរស់នៅជាមួយប្តីដែលទើបតែត្រូវបានផ្លាស់មកនៅអូររាំងឪ។ នៅឆ្នាំ១៩៧៥ ខ្ញុំដឹងដំណឹងថាម្តាយរបស់ខ្ញុំដែលរស់នៅកោះសូទិន បានស្លាប់។ ខ្ញុំបាននាំកូន និងប្អូនតូចមកភូមិវិញ ដោយបានដើរពីអូររាំងឪរហូតមកដល់កោះចិន និងឆ្លងទៅខាងកោះសូទិននៅព្រឹកបន្ទាប់។ នៅឆ្នាំ១៩៧៦ អង្គការចាត់តាំងខ្ញុំឲ្យធ្វើការងារនៅកងចល័តវ័យកណ្តាល ដោយបានដើរទៅរែកដី ជីកប្រឡាយ ស្ទូងស្រូវ កាត់ថ្នាំ និងកាច់ពោត។ ខ្ញុំត្រូវក្រោកនៅម៉ោង៤ព្រឹក ដើម្បីតម្រង់ជួរ និងចាប់ផ្តើមធ្វើការនៅម៉ោង៦ព្រឹកដល់ម៉ោង១១ព្រឹក និងម៉ោង១រសៀលដល់ម៉ោង៥ល្ងាច។ ខ្ញុំទទួលបានរបបអាហារត្រឹមតែបបររាវ។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រង និងចាប់ផ្តើមចាប់ខ្លួនប្រធានកង មេភូមិ និងអ្នក១៧មេសាដើម្បីយកទៅសម្លាប់ចោល។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានដាក់ជាប្រជាជនត្រៀម គឺជាក្រុមប្រជាជនដែលខ្មែរក្រហមយកទៅសម្លាប់នាពេលឆាប់ៗខាងមុខ។ មានប្រជាជនចាស់ និងប្រជាជន១៧មេសាជាច្រើនត្រូវបានចាប់ខ្លួនយកទៅសម្លាប់នាពេលនោះ។ ខ្ញុំធ្វើការនៅក្នុងកងចល័តវ័យកណ្តាល រហូតដល់ពេលដែលកងទ័ពវៀតណាមចូលមកដល់។ ខ្ញុំរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម និងប្រកបរបររស់នៅជាកសិកររហូតដល់ពេលសព្វថ្ងៃនេះ។

## ៩) អៀប គុយ ៖ អតីតកងចល័តខ្មែរក្រហម

ខ្ញុំឈ្មោះ អៀប គុយ អាយុ៦៤ឆ្នាំ រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ឪពុកខ្ញុំឈ្មោះ ហ៊ុយ អៀប និងម្តាយឈ្មោះ ពិន ស្រ៊ី។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៧នាក់។ នៅវ័យកុមារ ខ្ញុំរៀនសូត្រនៅសាលាបឋមសិក្សាវត្តចុងកោះ ត្រឹមថ្នាក់ទី១០ចាស់។ បន្ទាប់ពីមានរដ្ឋប្រហារលន់ នល់ នៅដើមឆ្នាំ១៩៧០ បាតុកម្មក៏កើតឡើង។ អ្នកភូមិជាច្រើនបានចូលរួមដង្ហែបាតុកម្មទៅទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមចូលមកដល់ភូមិជាបណ្តើរៗ និងសុំផ្ទះរបស់អ្នកភូមិដើម្បីស្នាក់អាស្រ័យ។ នៅឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ យន្តហោះអាដើងបង្គងបានហោះមកក្រឡឹងចុះឡើង និងបាញ់ផ្សេងៗ។ បន្ទាប់មកយន្តហោះអាទ្រុងជ្រូកបានមកទម្លាក់គ្រាប់បែកនៅភូមិច្រើនណាស់។ នៅឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារតែជំងឺ។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅតាមកងចល័ត។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានឆ័ត្រ និងតំរិល រួមមាន ស្ទូងស្រូវ លើកទំនប់ រែកដី និងជីកប្រឡាយ។ ខ្ញុំធ្វើការពីម៉ោង៦ព្រឹកដល់១១ថ្ងៃត្រង់ទើបឈប់ហូបបបរ និងបន្តធ្វើការងារចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ ចាប់ពីម៉ោង៧ដល់ម៉ោង៩យប់ ខ្ញុំធ្វើការងារបន្ថែមទៀត។ នៅឆ្នាំ១៩៧៧ ខ្ញុំទៅធ្វើកងចល័តឆ្ន័ត្ររហូតដល់ឆ្នាំ១៩៧៩។ ខ្ញុំរស់រានមានជីវិតពីការស្លាប់ក្នុងរបបខ្មែរក្រហម នៅពេលដែលកងទ័ពវៀតណាមចូលមកដល់។ ក្រោយមក ខ្ញុំរៀបការជាមួយ ជួង វី និងមានកូនម្នាក់។



អៀប គុយ អាយុ៦៤ឆ្នាំរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា / មជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមទឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១០ ផ្លូវលេខ ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!















# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំវេទិកាប្រវត្តិសាស្ត្រគ្រួសារ

## ពីថ្ងៃទី១៣ ដល់ទី១៥ ខែមិថុនា ឆ្នាំ២០២២

**ថុន ស្រីពេជ្រ**



*ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបនៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ពីថ្ងៃទី១៣ដល់១៥ ខែមិថុនា ឆ្នាំ២០២២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្រោមជំនួយទ្រទ្រង់ពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ បានចុះធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារនៅក្នុងភូមិចំនួន២គឺ ភូមិស្រះតាអឹម និងភូមិអង្រ្កង នៃឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ កិច្ចការនេះ ទទួលបានការឯកភាព និងសម្របសម្រួលពីអាជ្ញាធរមូលដ្ឋានឃុំអង្គរស ដើម្បីចុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១២នាក់ ក្នុងនោះមានស្រីចំនួន៥នាក់។

មុននឹងចុះទៅកាន់មូលដ្ឋានដើម្បីជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមភូមិនីមួយៗនេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើការទំនាក់ទំនងទៅកាន់លោកមេឃុំអង្គរសជាមុន ដើម្បីជម្រាបអំពីផែនការការងារ គោលបំណង និងស្នើសុំការសហការពីអាជ្ញាធរមូលដ្ឋាន ក្នុងការបញ្ជូនបញ្ជីឈ្មោះអ្នករស់រានមានជីវិតទាំង១២នាក់ ដែលត្រូវបានខេ្ទសនាមដោយលោកមេឃុំអង្គរស ហើយ

ផ្តល់ព័ត៌មានទៅកាន់អ្នកទាំងនោះវិញដើម្បីចូលរួមសហការផ្តល់បទសម្ភាសន៍ពីជីវប្រវត្តិឆ្លងកាត់របបខ្មែរក្រហម។

ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានចាកចេញពីទីរួមខេត្តព្រៃវែងនៅរៀងរាល់ព្រឹក ឆ្ពោះទៅកាន់គោលដៅការងារក្នុងឃុំអង្គរសដើម្បីអនុវត្តការងារ ហើយបានវិលត្រឡប់មកកាន់ទីរួមខេត្តវិញ នៅពេលរសៀល។ ក្នុងមួយថ្ងៃក្រុមការងារបានចុះទៅជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៤នាក់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានសហការយ៉ាងល្អជាមួយក្រុមការងារក្នុងការផ្តល់បទសម្ភាសន៍។ ក្រុមការងារសង្កេតឃើញមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់រីករាយក្នុងការផ្តល់បទសម្ភាសន៍ទោះបីគាត់ឈឺ និងមិនអាចអង្គុយយូរដោយសារតែគាត់មានជំងឺពុកឆ្អឹងខ្នង។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានស្នើសុំឲ្យគាត់ដេកនៅលើគ្រែដើម្បីជួយសម្រួលដល់គាត់ក្នុងការផ្តល់បទសម្ភាសន៍។ គាត់ចង់ចែករំលែកអំពីបទពិសោធន៍ និងទុក្ខវេទនា ព្រមទាំងការឈឺចាប់ចំពោះការបាត់បង់សាច់ញាតិបងប្អូនបង្កើត និងជីដូនមួយរបស់គាត់អស់ចំនួន២៥នាក់ ដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដើម្បីឲ្យក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងយកទៅចងក្រងជាឯកសារប្រវត្តិសាស្ត្រសម្រាប់ក្មេងជំនាន់ក្រោយ។

ភាគច្រើននៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលក្រុមការងារបានសម្ភាសន៍ គឺជាអតីតកម្មាភិបាលខ្មែរក្រហមថ្នាក់មូលដ្ឋាន និងអតីតពេទ្យខ្មែរក្រហម។ អ្នកទាំងនោះនៅចងចាំអំពីបទពិសោធន៍ជីវិតរបស់ខ្លួនបានយ៉ាងល្អ និងគិតថារបបខ្មែរក្រហម ហាក់ដូចជាទើបនឹងកើតឡើងថ្មីៗសម្រាប់គាត់។ អ្នកទាំងនោះបានទទួលស្វាគមន៍ក្រុមការងារយ៉ាងកក់ក្តៅ និងរីករាយក្នុងការផ្តល់បទសម្ភាសន៍ ព្រមទាំងសហការជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។

ទោះបីយ៉ាងណា ក្រុមការងារបានជួបបញ្ហាប្រឈមខ្លះដោយសារស្ថានភាពផ្លូវចូលទៅកាន់ភូមិនានាក្នុងឃុំអង្គរស ហើយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួនមានពេលវេលាតិចក្នុងការផ្តល់បទសម្ភាសន៍ព្រោះគាត់ជាប់រវល់ក្នុងការប្រកបរបររកស៊ី។ តាមរយៈបញ្ហាប្រឈមខាងលើនេះ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងនឹងជ្រើសរើសទីតាំងអំណោយផលក្នុងការចុះជួបសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះនៅពេលក្រោយ។ ក្រុមការងារនឹងខិតខំបន្តពង្រឹងបន្ថែមនូវវិធីសាស្ត្រសម្ភាសន៍ ដើម្បីធានាថាការសន្ទនាពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមនឹងប្រព្រឹត្តទៅដោយរលូន និងទទួលបានព័ត៌មានគ្រប់គ្រាន់។

គម្រោងផែនការសម្រាប់ខែកក្កដា ឆ្នាំ២០២២ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តព្រៃវែងនឹងបន្តកិច្ចការរបស់ខ្លួននៅក្នុងឃុំអង្គរស ដើម្បីជួបសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនទៀតដើម្បីស្វែងយល់បន្ថែមពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រក្រោយថ្ងៃជ័យជម្នះ៧ ខែមករា ឆ្នាំ១៩៧៩។



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបនៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នករស់រានមានជីវិតពីរបបនៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនចុងសប្តាហ៍ជាមួយសិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន អង្គរស

## ស្តីពី សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ

ថុន ស្រីពៅ



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៃវិទ្យាល័យអង្គរស ថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានរៀបចំវេទិកាថ្នាក់រៀនលើកទី៨៤ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២។ កម្មវិធីនេះ បានប្រព្រឹត្តទៅនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលមានទីតាំងស្ថិតក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង។ សិស្សានុសិស្សថ្នាក់ទី១២ ចំនួន៤៨នាក់ (ស្រី៣៧ នាក់) បានចូលរួមនៅក្នុងវេទិកាថ្នាក់រៀននេះ ក្រោមការដឹកនាំពីគ្រូប្រវត្តិវិទ្យានៃវិទ្យាល័យហ៊ុនសែនអង្គរស។ ដំណើរទស្សនកិច្ចសិក្សានេះត្រូវបានធ្វើឡើងក្នុងគោលបំណង ផ្តល់នូវចំណេះដឹងបន្ថែមដល់សិស្សានុសិស្ស ឲ្យបានយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងផ្តល់ឱកាសដល់សិស្សានុសិស្សដែលបានចូលរួមធ្វើការចែករំលែកនូវចំណេះដឹងផ្ទាល់ខ្លួន ក៏ដូចជាបទពិសោធន៍ដែលខ្លួនបានដឹងពីជីដូនជីតា ប្រាប់ដល់សិស្សានុសិស្សឯទៀត ដែលមានវត្តមាននៅក្នុង



លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់សិស្សានុសិស្សនៅក្នុងកម្មវិធីវេទិកាថ្នាក់រៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

វេទិកាថ្នាក់រៀន។ ក្រៅពីនេះ គឺដើម្បីលើកទឹកចិត្តឲ្យមានការ វិភាគ ការគិតពិចារណា ទៅលើសង្គមកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៅទៀតគឺដើម្បីជំរុញឲ្យមានការពិភាក្សា វែកញែករកខុសត្រូវ និងយុទ្ធសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ក្នុងដំណើរទស្សនកិច្ចសិក្សារបស់សិស្សានុសិស្សនេះ លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានយល់ព្រមនឹងសំណើរបស់គណគ្រប់គ្រងវិទ្យាល័យ ហ៊ុន សែន អង្គរស ក្នុងការបញ្ជូនសិស្សានុសិស្សឲ្យមកចូលរួមក្នុងវេទិកាថ្នាក់រៀន ដោយមូលហេតុថា នៅក្នុងឆ្នាំ២០២២នេះ សាលាវិទ្យាល័យ ហ៊ុនសែន អង្គសរ ពុំទាន់បានអញ្ជើញសិស្សានុសិស្សថ្នាក់ទី១២ជំនាន់ថ្មី មកទទួលនូវចំណេះដឹងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងវេទិកាថ្នាក់រៀន ដែលបានប្រព្រឹត្តនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងនៅឡើយទេ។

វិទ្យាល័យ ហ៊ុនសែនអង្គរស មានចម្ងាយប្រមាណ ៥០គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង។ កាលដើមឡើយ វិទ្យាល័យនេះ ពុំទាន់មានកម្រិតថ្នាក់វិទ្យាល័យនៅឡើយទេ។ ស្ថិតនៅក្នុងសម័យសង្គមរាស្ត្រនិយម សាលានេះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៥១ ជាសាលាបឋមសិក្សាអង្គរស ដឹកនាំដោយព្រះតេជគុណ ប៉ែន ពៅ។ លុះមកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលជាថ្ងៃធ្វើរដ្ឋប្រហាររបស់សេនាប្រមុខ លន់ នល់ ទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ប្រទេសជាតិចាប់ផ្តើមកើតមានសង្គ្រាម ហើយសាលាបឋមសិក្សាអង្គរសត្រូវបានបិទទ្វារ។ នៅក្នុងរបបខ្មែរក្រហម សាលាបឋមសិក្សាអង្គរស ត្រូវអង្គការយកទៅធ្វើជាមន្ទីរពេទ្យប្រចាំភូមិអង្គរស។ ក្រោយមក នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៧ សាលាបឋមសិក្សាអង្គរសត្រូវបានផ្លាស់ប្តូរទៅជាអនុវិទ្យាល័យអង្គរសវិញ។ រហូតមកដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨ សាលាអនុវិទ្យាល័យអង្គរសក៏បានប្រែក្លាយទៅជា វិទ្យាល័យ ហ៊ុន សែន អង្គរស រហូតមកដល់បច្ចុប្បន្ននេះ ដែលមានអគារមួយជាន់ចំនួន ៣ខ្នង និងអគារពីរជាន់ចំនួន ១ខ្នង ស្មើនឹង៣២បន្ទប់។



សិស្សានុសិស្សបំពេញតារាងវាស់ស្ទង់ចំណេះដឹងមុន និងក្រោយពេលសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាធ្វើបទបង្ហាញអំពីមេដឹកនាំខ្មែរក្រហមទៅកាន់សិស្សានុសិស្សនៅក្នុងកម្មវិធីវេទិកាថ្នាក់រៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កាលវិភាគវេទិកាថ្នាក់រៀន ១) ការណែនាំអំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ២) ការទស្សនាពិព័រណ៍រូបថត ៣) បំពេញតារាងស្ទាបស្ទង់មតិ (មុនពេលការធ្វើបទបង្ហាញ) ៤) បទបង្ហាញសង្ខេបពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងផលប៉ះពាល់ក្រោយរបបនេះ ៥) សំណួរចម្លើយពី ប្រវត្តិសាស្ត្រខ្មែរក្រហម ៦) ទស្សនាខ្សែភាពយន្តខ្លី «កុមារកម្ពុជា» សម្រាកអាហារថ្ងៃត្រង់ ៧) បទបង្ហាញពីនិយមន័យ និងកត្តាគ្រោះថ្នាក់ដែលនាំឲ្យកើតមានអំពើឃោរឃៅ ៨) បំពេញតារាងស្ទាបស្ទង់មតិ (ក្រោយពេលស្តាប់ការធ្វើបទបង្ហាញ ៩) ចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១០) ថតរូបជុំគ្នាទុកជាអនុស្សាវរីយ៍។

សកម្មភាពវេទិកាថ្នាក់រៀន សិស្សានុសិស្សទាំងអស់បានធ្វើដំណើរមកដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងនៅវេលាម៉ោងប្រមាណ៩ព្រឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២។ នៅពេលសិស្សានុសិស្សមកដល់ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានអនុវត្តវិធានការសុខាភិបាលជាដំបូងគេដូចជា ការពាក់ម៉ាស និងការលាងដៃជាមួយនឹងអាល់កុលជាដើម មុននឹងសិស្សចូលរួមក្នុងវេទិកាថ្នាក់រៀន។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានត្រៀមរួចជាស្រេច នូវអាល់កុល និងម៉ាស់ដើម្បីធានាសុវត្ថិភាពដល់សិស្សានុសិស្សពីការរីករាលដាលនៃជំងឺកូវីដ-១៩ បើទោះជាដឹងថាបច្ចុប្បន្ននេះ ជំងឺកូវីដ-១៩ នៅក្នុងប្រទេសត្រូវបានអន់ថយ ក៏យើងនៅតែបន្តប្រុងប្រយ័ត្នដែរ។

ដំណើរការនៃការចាប់ផ្តើមនៃវេទិកាថ្នាក់រៀននេះ ជាដំបូងលោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានចាប់ផ្តើមណែនាំដល់សិស្សានុសិស្សទាំងអស់អំពីការបង្កើតមជ្ឈមណ្ឌលឯកសារនេះឡើងក្នុងគោលបំណង ផ្សព្វផ្សាយ ប្រមូលចងក្រងឯកសារ ទាំងឡាយណាដែលទាក់ទងនឹងប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈការសម្ភាសជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម យកមកតម្កល់ទុកធ្វើជាឯកសារសម្រាប់ក្មេងជំនាន់ក្រោយបានសិក្សារៀនសូត្រ ដើម្បីការចងចាំ និងប្រើប្រាស់ជាមេរៀនបន្ថែម ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ។ ចំពោះការទស្សនាពិព័រណ៍រូបថតគ្រូខ្មេស បានធ្វើការណែនាំនូវរូបភាពអចិន្ត្រៃយ៍តាមរយៈការបញ្ចាំងស្លាយ ដើម្បីពន្យល់ប្រាប់ដល់សិស្សនូវរូបភាពនីមួយៗ ដូចជា រូបភាពប្រជាជនធ្វើការងារ ជីកប្រឡាយ លើកទំនប់ នៅស្ទឹងជីនិត រូបភាពប្រជាជនធ្វើការភៀសខ្លួនទៅវៀតណាម

ព្រមទាំងរូបភាពជនរងគ្រោះទាំងអស់ដែលត្រូវបានជាប់នៅមន្ទីរស-២១ ជាច្រើនទៀត។ ក្រៅពីនេះ គ្រូខ្មែរក៏បានបញ្ចាំងស្លាយ និងឲ្យសិស្សស្គាល់អំពីប្រវត្តិសង្ខេប របស់មេដឹកនាំធំៗ ដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន និង ឌុច ជាដើម ហើយគ្រូខ្មែរក៏បានបន្ថែមចុងក្រោយទៀតថា អ្នកទាំងនោះត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ខ្លួនយកទៅកាត់ទោសអស់មួយជីវិត។ មួយវិញទៀតរហូតមកដល់បច្ចុប្បន្ននេះ ទោះបីជាអ្នកទាំងនោះស្លាប់ហើយក៏ដោយ ក៏អ្នកទាំងនោះនៅតែជាប់ឈ្មោះជាជនមានទោស។

មុនពេលចាប់ផ្តើមវេទិកាថ្នាក់រៀនសិស្សានុសិស្សតម្រូវឲ្យបំពេញតារាងស្ទាបស្ទង់មតិរយៈពេល១០នាទីដើម្បីវាស់ស្ទង់នូវចំណេះដឹងរបស់សិស្សមុនពេលសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ សម្រាប់តារាងស្ទាបស្ទង់នេះគឺមាន ១២សំណួរ ដែលត្រូវបានបែងចែកជាបីផ្នែកធំៗគឺ ទី១) ផ្នែកចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកចំណេះដឹងអំពីនិយមន័យអំពើប្រល័យពូជសាសន៍ ទី២) កត្តាគ្រោះថ្នាក់ជាក់លាក់ដែលនាំឲ្យកើតមានអំពើឃោរឃៅក្នុងពិភពលោក និង ទី៣) ផ្នែកចំណេះដឹងអំពីវិធីសាស្ត្រក្នុងការចូលរួមទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ៤) បទបង្ហាញដោយសង្ខេបពី "ប្រវត្តិសាស្ត្រខ្មែរក្រហម" ។

បន្ទាប់ពីការបំពេញតារាងស្ទាបស្ទង់មតិរួច គ្រូខ្មែរចាប់ផ្តើមធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្សដែលបានចូលរួម។ ការធ្វើបទបង្ហាញនេះ គ្រូខ្មែរបានចំណាយពេលប្រហែល២ម៉ោង ដើម្បីធ្វើបទបង្ហាញសង្ខេបអំពីផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើប្រជាជនកម្ពុជា និងប្រទេសជាតិ ដែលបន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រារាប់ពាន់នាក់ ជំងឺបាក់ស្បាត ដែលនៅតែបន្តកើតមានចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នាពេលបច្ចុប្បន្ន និងជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ព្រមទាំងសេដ្ឋកិច្ចធ្លាក់ដល់កម្រិតសូន្យក្រោយរបបខ្មែរក្រហមដួលរលំ។

ក្នុងការទាញអារម្មណ៍សិស្សឲ្យផ្តោតសំខាន់និងយកចិត្តទុកដាក់ទៅលើមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហម ព្រមទាំងបើកឱកាសដល់សិស្សសួរសំណួរ ដែលខ្លួនឆ្ងល់ជាយូរណាស់មកហើយនោះ តែមិនដឹងសួរទៅកាន់នរណាដើម្បីបានចម្លើយត្រឹមត្រូវ គ្រូខ្មែរបានផ្តល់ពេលវេលា ដល់ក្រុមសិស្សទាំងអស់ក្នុងការសួរសំណួរអំពីប្រវត្តិសាស្ត្រខ្មែរក្រហម មុនការធ្វើបទបង្ហាញខ្លីអំពីប្រវត្តិសាស្ត្រនេះបានចាប់ផ្តើម។ សិស្សបានចោទសួរជាសំណួរដូចជា ហេតុអ្វីនៅក្នុងរបបខ្មែរក្រហមមានការសម្លាប់ប្រជាជន? ហេតុអ្វីបានជានៅក្នុងរបបខ្មែរក្រហមសម្លាប់បញ្ញវន្ត និងអ្នកមានចំណេះដឹង? ហេតុអ្វីបានជា ប៉ុល ពត ឃុំឃាំងសម្តេចព្រះនរោត្តម សីហនុ នៅក្នុងព្រះបរមរាជវាំង? តើកត្តាអ្វីខ្លះដែលនាំឲ្យរបបខ្មែរក្រហមក្លាយទៅជារបបប្រល័យពូជសាសន៍? នៅក្នុងរបបខ្មែរក្រហម ហេតុអ្វីបានប្តីប្រពន្ធមិនអាចនៅជាមួយគ្នាបាន?

បន្ទាប់ពីការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបានឆ្លើយសំណួររបស់សិស្សរួច គ្រូខ្មែរបានចាក់បញ្ចាំងនូវខ្សែវីដេអូឯកសារខ្លីមួយដែលមានចំណងជើងថា «កុមារកម្ពុជា» ខ្សែវីដេអូនេះ បង្ហាញពីដំណើរគ្មានគោលដៅរបស់ក្មេងកំព្រាទាំងឡាយដែលឪពុកម្តាយ និងបងប្អូនបានស្លាប់ចោលអស់។ ក្នុងដំណើរដ៏ឯកោនេះ សិស្សានុសិស្សបានសង្កេតឃើញពីភាពគ្មានអនាម័យក្នុងការហូបចុក និងពុំមានផ្ទះសម្បែងសម្រាប់ជាទីលំនៅ ព្រមទាំងបានឃើញពីជីវិតដែលគោលគ្មានគោលដៅ ដែលដំណើរទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសគ្នារវាងក្មេងៗជំនាន់មុន និងក្មេងៗជំនាន់ក្រោយ ហើយក្មេងៗជំនាន់ក្រោយមិនអាចទទួលយកបានឡើយ។ ខ្សែវីដេអូនេះក៏ជាភ័ស្តុតាងបញ្ជាក់ និងជាមេរៀនជីវិតរបស់ក្មេងៗជំនាន់មុន ដែលក្មេងៗជំនាន់នេះ បានបង្ហាញពីភាពភ្ញាក់ផ្អើល និងអាណិតអាសូរឥតព្រំដែនចំពោះសោកនាដកម្មនានាដែលបានកើតមានចំពោះក្មេងៗក្នុងសម័យខ្មែរក្រហម។ វីដេអូនេះក៏ជាផ្នែកមួយដែលបំផុសស្មារតីឲ្យក្មេងៗជំនាន់ក្រោយ រិះរកវិធីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកជាលើកទីពីរទៀត។

គ្រូឧទ្ទេសបានចាប់ផ្តើមធ្វើបទបង្ហាញផ្នែកសំខាន់ៗផ្សេងទៀតគឺ ១) និយមន័យនៃអំពើឧក្រិដ្ឋឃោរឃៅ (រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) និងឧទាហរណ៍ជាក់លាក់មួយចំនួនដែលនាំឲ្យកើតមានឧក្រិដ្ឋកម្មឃោរឃៅទាំងឡាយ និង ២) វិធីសាស្ត្រជាក់លាក់ចំនួនពីរក្នុងការចូលរួមទប់ស្កាត់អំពើឃោរឃៅឬអំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារឬសហគមន៍ និងកម្រិតប្រទេសជាតិ។ សិស្សានុសិស្ស ត្រូវបានលើកទឹកចិត្តឲ្យអនុវត្តវិធីសាស្ត្រទាំងនេះ ដោយចាប់ផ្តើមពីខ្លួនឯង។

ក្រោយវេទិកាបញ្ចប់ក្នុងរយៈពេលមួយថ្ងៃ ដែលសិស្សានុសិស្សបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះ តម្រូវឲ្យមានការបំពេញនូវតារាងស្ទាបស្ទង់មតិ (ក្រោយវេទិកា) ម្តងទៀត ដើម្បីវាស់ស្ទង់ពីចំណេះដឹងកើនឡើង ថាតើខ្លួនអាចទទួលបាននូវចំណេះដឹងកើនឡើងបានប៉ុន្មានភាគរយ ក្រោយពីបានសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួចមកនេះ។ ការបំពេញតារាងស្ទាបស្ទង់មតិលើកនេះ សិស្សានុសិស្សបានចំណាយពេលវេលាធ្វើយូរជាងមុន ព្រោះថាត្រូវមានសំណួរជាច្រើនដែលសិស្សត្រូវឆ្លើយ ហើយ សំណួរខ្លះត្រូវការគិត និងទាមទារឲ្យសិស្សានុសិស្សសរសេររៀបរាប់ពីចំណេះដឹងដែលខ្លួនបានសិក្សាថ្មីៗ ព្រមទាំងគំនិតយល់ឃើញផ្ទាល់ខ្លួនក៏ដូចជាវិធីសាស្ត្រនានា ក្នុងការទប់ស្កាត់អំពើហិង្សានិងឧក្រិដ្ឋកម្មឃោរឃៅ នាពេលអនាគត។ ចុងបញ្ចប់នៃកម្មវិធីវេទិកាថ្នាក់រៀន មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានចែកជូននូវសៀវភៅប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២ម្នាក់មួយក្បាល ដើម្បីទុកជាឯកសារស្រាវជ្រាវ និងរៀនសូត្របន្ថែម។

ជាចុងក្រោយ មុននឹងត្រឡប់ទៅកាន់គេហដ្ឋានរៀងៗខ្លួនវិញ សិស្សានុសិស្សទាំងអស់បានឈរថតរូបជុំគ្នាជាមួយនឹងគ្រូឧទ្ទេស គ្រូដឹកនាំ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅពីមុនផ្ទាំងពិព័រណ៍ធំមួយ ស្ថិតនៅខាងក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ តាមការសង្កេត មានសិស្សានុសិស្សចំនួនច្រើន ដែលមានចំណាប់អារម្មណ៍ខ្ពស់លើការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នេះ ប៉ុន្តែក៏មានសិស្សានុសិស្សចំនួនតូចមិនបានយកចិត្តទុកដាក់ស្តាប់គ្រូឧទ្ទេសពន្យល់នោះដែរ។ យ៉ាងណាមិញ សិស្សានុសិស្សភាគច្រើនក៏បានបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ក្នុងការត្រងត្រាប់ស្តាប់ការធ្វើបទបង្ហាញរបស់គ្រូឧទ្ទេសដែរ តាមរយៈការឆ្លើយឆ្លង និងសួរនូវសំណួររបស់ខ្លួនទៅកាន់គ្រូឧទ្ទេស។ សំណួររបស់សិស្សទាំងអស់គ្នានេះ យើងអាចសន្និដ្ឋានបានថា សិស្សមានចំណេះដឹងពីមុនមកស្រាប់ពីរបបខ្មែរក្រហម ប៉ុន្តែចំណេះដឹងទាំងនោះនៅមានកម្រិតនៅឡើយ។ ការសង្កេតមួយទៀត សិស្សានុសិស្សមួយចំនួន បានកត់ត្រានូវចំណុចសំខាន់ៗដែលគ្រូឧទ្ទេសបានបង្ហាញ ដែលជាមូលហេតុធ្វើឲ្យយើងដឹងថា សិស្សានុសិស្សទាំងនោះ ព្យាយាមនិងយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ និងបានកត់ត្រាចំណុចសំខាន់ដែលត្រូវយកមកសិក្សារៀនសូត្រ។

សិស្សានុសិស្សចូលរួមក្នុងវេទិកាថ្នាក់រៀនបានបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

*ខ្ញុំបាទឈ្មោះ* **ស៊ុំ សុគន្ធា** *មានអាយុ១៩ឆ្នាំ រៀននៅថ្នាក់ទី១២ C នៃវិទ្យាល័យ ហ៊ុនសែន អង្គរស។ ខ្ញុំបាទពិតជាមានរីករាយជាខ្លាំងក្នុងការចូលរួមក្នុងដំណើរការទស្សនកិច្ចនេះ ព្រមទាំងទទួលបានអារម្មណ៍យ៉ាងកក់ក្តៅពីលោកគ្រូទាំងអស់ ដែលបានជួយបណ្តុះបណ្តាលខាងផ្នែកចំណេះដឹងអំពីប្រវត្តិសាស្ត្រដ៏ជូរចត់នៃប្រទេសកម្ពុជា។ ជាចុងក្រោយ ជំនួសមុខដល់សិស្សានុសិស្សនៃវិទ្យាល័យ ហ៊ុនសែន អង្គរស ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូទាំងអស់គ្នាឲ្យមានសុខភាពល្អ និងមានសុវត្ថិភាពទាំងទីជិតទីឆ្ងាយ ព្រមទាំងមានសុភមង្គលនៅក្នុងគ្រួសារ។*

ខ្ញុំបាទ ឈ្មោះ **សាត រតនា** មានអាយុ១៧ឆ្នាំ រៀននៅថ្នាក់ទី១២C នៃវិទ្យាល័យ ហ៊ុនសែនអង្គរស យល់ឃើញថា ការចូលរួមក្នុងទស្សនកិច្ចសិក្សានៅក្នុងថ្ងៃនេះ បានធ្វើឲ្យខ្ញុំយល់ច្បាស់ពីប្រវត្តិ-សាស្ត្រកាន់តែច្រើន យល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំពិតជាចង់សិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រនេះណាស់ ព្រោះធ្វើឲ្យខ្ញុំយល់ដឹងកាន់តែច្បាស់។

---

នាងខ្ញុំឈ្មោះ **សាក សំភ័ស** មានអាយុ២០ឆ្នាំ រៀននៅថ្នាក់ទី១២ C នៃវិទ្យាល័យ ហ៊ុនសែនអង្គរស។ ខ្ញុំមានអារម្មណ៍ថាសប្បាយរីករាយណាស់ក្នុងការចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សានេះ ព្រោះវាបានផ្ដល់នូវចំណេះដឹងច្រើនមកដល់រូបខ្ញុំ និងបានអប់រំដល់មនុស្សជាតិទូទៅ ឲ្យខំស្វែងយល់អំពីបញ្ហា មិនតែប៉ុណ្ណោះ កាលណាមានអ្នកចេះដឹងច្រើនអាចជួយលើកស្ទួយសិទ្ធិមនុស្ស និងជួយទប់ស្កាត់អំពើអមនុស្សធម៌។

បញ្ហាប្រឈម នៅក្នុងដំណើរទស្សនកិច្ចនេះមានសិស្សស្រីម្នាក់បានខ្យល់គរ ដោយសារតែពុលឡាន ទើបធ្វើឲ្យគាត់មិនអាចចូលរួមក្នុងវេទិកាថ្នាក់រៀនបាននៅពេលព្រឹក។ ចំណែកឯបញ្ហាប្រឈមមួយទៀតគឺ សិស្សានុសិស្សមួយចំនួនតូច បានបង្ហាញឲ្យឃើញពីភាពអស់កម្លាំង និងងងុយដេក និងក្រាបនៅលើតុ ខណៈពេលដែលគ្រូខទ្វេសកំពុងធ្វើបទបង្ហាញ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ សិស្សានុសិស្សភាគច្រើនបានបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការត្រងត្រាប់ស្ដាប់ការពន្យល់របស់គ្រូខទ្វេស។

សេចក្តីសន្និដ្ឋាន ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ មិនត្រឹមតែឲ្យក្មេងជំនាន់ក្រោយបានយល់ដឹងពីប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្ដុះគំនិតដល់សិស្សឲ្យនឹកគិតពីបទពិសោធន៍លំបាកនានារបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម ហើយធ្វើការប្រៀបធៀបក្នុងសង្គមខ្មែរក្រហមមកសង្គមបច្ចុប្បន្នថាខុសគ្នាកម្រិតណា។ ដំណើរទស្សនកិច្ចសិក្សានេះក៏បានបណ្ដុះក្មេងជំនាន់ក្រោយរិះរកវិធីសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់កុំឲ្យរបបនេះវិលត្រឡប់មកវិញសារជាថ្មីម្ដងទៀត ដោយចាប់ផ្ដើមពីខ្លួនឯង។



បរិវេណសាលាគរុកោសល្យភូមិភាគ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិយាដ» (ត)

## និស្ស័យប្រែពណ៌

### កម្មាភិបាលធុយ៉ិស

ខ្ញុំឈរធ្មឹងស្រមើស្រមៃទៅដល់រឿងអតីតកាលដ៏ឈឺចាប់ ទាំងអារម្មណ៍ក្រៀមក្រំខ្សោះរីងរៃ។ ពេលនោះប្អូនវ៉ាមើលមកខ្ញុំ រួចកេះឲ្យខ្ញុំភ្ញាក់ស្មារតីឡើង ខណៈកំពុងភ្លឹកអារម្មណ៍។ ខ្ញុំភ្ញាក់មើលមុខប្អូនរួចងាកមកនិយាយតិចៗ៖ “តស់! ប្អូនទៅមើលបងស្រីយើងរៀបការ។”

ខ្ញុំក៏ចងមីគ្នោតនឹងខ្សែអង្កត់ទៅនឹងជញ្ជាំង ខ្ទមស្លាយខ្សែជាប់ស្មឹងនិងកឡោប៉ីបាចទឹកគោ រួចដឹកដៃប្អូនប្រុសរត់កាត់វាលស្រែជញ្ជាំងតម្រង់ទៅរោងបាយ ខាងកើតភូមិ មានតែខោខ្លីមួយចង្កេះផ្ទុះមុខក្រោយចងនឹងខ្សែសម្បារបេក ក្នុងចិត្តរំភើបផងភ័យផង។

មកដល់រោងបាយ ពីរនាក់បងប្អូនឈរក្រោមដើមដូងមួយដើម ក្រោមភ្លៀងរលឹមផ្សែងក្រុចខែកត្តិកបក់មករអឹក នឹកឃើញឡើងខ្លោចផ្សារ។ ខ្ញុំផ្ទាឱបដៃខំសម្លឹងរកមើលបងស្រី។ ខ្ញុំមើលទៅប្រហែល កម្មាភិបាលបដិវត្តន៍ថ្នាក់លើរៀបផ្សំផ្គុំការឲ្យម្ភៃគូ ឃើញសម្លៀកបំពាក់ខ្មៅក្រឹប ពាក់ស្បែកជើងកង់ឡាន និងក្រមាថ្មីៗ។ ខាងយុវជនគេបង់កនឹងក្រមា ចំណែកយុវនារីៗ ជួតក្បាលក្រមា ប្រហែលអង្គការបដិវត្តន៍ថ្នាក់លើទើបនឹងបើកឲ្យ។

មិនមានអ្នកណាមួយឈរមើលទេ មានតែខ្ញុំពីរនាក់បងប្អូន ភ្នែកខំសម្លឹងរេរកមើលបងស្រី ឃើញកម្មាភិបាលម្នាក់ប្រាប់ឲ្យមួយគូម្តងៗ ឡើងប្តេជ្ញាចិត្តនៅចំពោះមុខ។ គេបង្គាប់ឲ្យគូស្រករថ្មី ដែលចាប់ផ្តិមបញ្ចូលនឹមដោយអង្គការ និងគ្មានការស្ម័គ្រចិត្តងើបឈរដោយកាន់ដៃគ្នាលើកឡើងលើ ហើយនិយាយតាមក្រោយកម្មាភិបាលថា “យើងខ្ញុំទាំងពីរនាក់ប្តេជ្ញាចិត្តថានឹងយកគ្នាជាប្តីប្រពន្ធអស់មួយជីវិត និងប្តេជ្ញាចិត្តខំធ្វើស្រែឲ្យបានផលពីបីទៅប្រាំតោនក្នុងមួយ ហិកតាជូនអង្គការបដិវត្តន៍។”

បន្ទាប់ពីរៀបការរួច យប់នោះមានកងឈ្លបមកយកការណ៍ទៀត។ ប្រសិនបើ គូណាមិនចុះសម្រុងលួចរស់នៅបែកគ្នា ស្អែកឡើងអង្គការនឹងបញ្ជូនយកទៅកសាងរៀនសូត្រ គឺបានន័យថា យកទៅសម្លាប់ ពីបទចោទថាបានបោកប្រាសអង្គការក្នុងការរៀបការនេះ ដោយគ្មានការស្ម័គ្រចិត្ត។

អង្គការបែងចែកឲ្យប្រជាជនចាស់រៀបការស្ម័គ្រចិត្តបានតែជាមួយប្រជាជនចាស់ទេ ដែលគេចាត់ទុកថាប្រជាជនបដិវត្តន៍ស្អាតស្អំ និងប្រជាជនថ្មីរៀបការតែជាមួយ ប្រជាជនថ្មីដូចគ្នា។ គេបែងចែកវណ្ណៈឲ្យដាច់រវាងប្រជាជនចាស់និងប្រជាជនថ្មី។



ទិដ្ឋភាព៖ ខ្ញុំ និងប្អូន រត់មកមើលបងស្រីរៀបការនៅរោងបាយ ខាងកើតភូមិ
(ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិយាដ)

ខណៈពេលនោះ មិនយូរប៉ុន្មានខ្ញុំឃើញបងស្រីគាត់សម្លឹងមកមើលប្អូនទាំងពីរ រួចដល់វេន គាត់ឡើងប្តេជ្ញាចិត្ត គាត់ខំងាកមកមើលខ្ញុំៗ ខ្ញុំមើលទៅគាត់វិញញញឹមលាយទឹកភ្នែកៗ

មួយស្របក់ក្រោយមក ការប្តេជ្ញាចិត្តត្រូវបានបញ្ចប់ ហើយផ្នែកចុងភៅគេរៀបចំចានបាយ និងស្លាបព្រាកញ្ចាស់ឲ្យម្នាក់មួយៗបន្ទាប់មកចុងភៅដួសបបរដាក់ចានម្នាក់មួយវែក និងទឹកប្រហុករាវកក្លូកមួយចានពីរនាក់ៗ វាជាពិធីជប់លៀងយ៉ាងមហាឱឡារិកដែលរៀបចំដោយអង្គការបដិវត្តន៍ក្នុងរបបនោះៗ

បងស្រី ហូបបបរទំពាមួយៗក្នុងអារម្មណ៍ក្តុកក្តួលសម្លឹងមើលប្អូនបណ្តើរ តែមិនហ៊ានចេញមកក្រៅជួបប្អូនទេខ្លាចខុសវិន័យៗ គ្មានអ្វីនឹងវាចាបានត្រឹមតែមើលមុខគ្នាឡេងឡង់ៗ មិនអាចនិយាយរកគ្នាបានមិនតែប៉ុណ្ណោះកម្មាភិបាលបានចេញមកក្រៅ ហើយដេញពួកខ្ញុំចេញ ស្រែកគំហកដាក់នែអាកុមារថ្មីពីរនាក់បងប្អូនចេញពីទីនេះទៅៗ ខ្ញុំងាកមើលបងស្រីលើកចុងក្រោយ ហើយក៏ដឹកដៃប្អូនធ្វើដំណើរមួយៗចេញពីទីនោះទាំងនឹកអាល័យអស់សង្ឃឹមនឹងរនាំងនិស្ស័យប្រែពណ៌ដោយផ្តាច់មនោសញ្ចេតនារវាងបងប្អូន ជីដូនជីតា កូនឪពុកម្តាយៗ

ខ្ញុំដើរផងងាកមើលក្រោយផងៗ បងស្រីនៅតែតាមមើលប្អូនទាំងពីរ ទឹកស្រណោះរហូតដាច់កន្ទុយភ្នែកៗ **ខ្ញុំឈប់បន្តិច ហើយងាកមើលបងស្រីជាលើកចុងក្រោយនូវសម្តីក្រសែភ្នែកពីចម្ងាយដែលជិតដាមដោយទឹកភ្នែកហូរជាចំណងដៃ និងសំឡេងយំរងំក្នុងពោះជាបទភ្លេងបាយខុនចងដៃក្នុងថ្ងៃបងស្រីរៀបការ ហើយខ្ញុំតម្រង់ទៅកន្លែងចាំគោវិញ ទាំងអស់សង្ឃឹមក្នុងជីវិតកំព្រាកុមារភាពៗ**

**ខ្ញុំដើរដឹកដៃប្អូនចេញមកវិញស្ទើរឈានជំហានមិនរួច និងឆ្លងកាត់វង្វេង នឹកតូចចិត្តនឹងជីវិតវាសនាអភ័ព្វ ក្រោមទម្ងន់មាក់ងាយមើលថោក រើសអើងហាក់ដូចជាខ្មៅមរអើមថាគ្រួសារខ្ញុំអាក្រក់ក្រៃដូចប្រេតតិរច្ឆានពីសំណាក់មេកងកុមារ មេចុងភៅរោងបាយ កម្មាភិបាល និងកុមារមូលដ្ឋាន នូវពាក្យសម្តីអសុរោះដូចជា អាកុមារថ្មី អាពួកចក្រព័ត្តិ១៧មេសា អាអ្នកភ្នំពេញជុះអាចម៍មិនចេញយកពន្លាកដាប់ ឬអាអ្នកថ្មីល្ងីល្ងើជាដើម គឺកម្មាភិបាលអាមីង មានចរិតលក្ខណៈនិយាយចំអកមើលងាយ ដែលជាអនុស្សាវរីយ៍ពិតនាំមកជាមួយៗ**

ពិតជាសម្រែកដួងចិត្ត ដែលយើងហ៊ានលួចតបតទៅវិញ តាមតែវាចា ទឹកភ្នែកក្នុងគំនាបជីវិតគ្មានសិទ្ធិសេរីភាពប៉ុណ្ណោះៗ



ទិដ្ឋភាព៖ ខ្ញុំ និងប្អូនរត់មកមើលបងស្រីរៀបការនៅរោងបាយខាងកើតភូមិ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)





រូបភាពបច្ចុប្បន្នឆ្នាំ២០១៩៖ ដើមដូងដែលខ្ញុំ និងប្អូនវ៉ា ធ្លាប់ជ្រកមើលបងស្រីរៀបការត្រូវបានគេកាប់នៅសល់គល់ៗ (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

# បាយក្តាំង អំបិលគ្រួស

## បាយក្តាំង អំបិលគ្រួស

ពេលល្ងាចបន្ទាប់ពីយកគោបញ្ចូលក្រោលនិងហូបបបររួច ខ្ញុំត្រឡប់មកដល់ផ្ទះបានឃើញបងថ្លៃកំពុងរែកទឹកពីអណ្តូងមកដាក់ក្នុងពាង។ បងស្រីមកនិយាយប្រាប់ខ្ញុំពីរនាក់ប្អូនថា ប្អូនហៅគាត់បង១ទៅ ព្រោះអ្នកភូមិគេទម្លាប់ហៅបងថ្លៃថាអ្នក១។ បន្ទាប់មកបងប្រុស គាត់ប្រាប់ខ្ញុំថា ប្អូនទាំងពីរងូតទឹកពាងនេះចុះ បងរែកមកទុកប្រើសម្រាប់តាយាយនិងយើងទាំងអស់គ្នា។

ចាប់ពីពេលនោះមកខ្ញុំហាក់មានអារម្មណ៍ធូរស្រាលកក់ក្តៅ ដោយមានបងថ្លៃមកនៅជាមួយជួយមើលថែរក្សាក្រុមគ្រួសារ ដូចជាមេគ្រួសារមួយដែរ។ គាត់តែងតែអប់រំនិងរបៀបរត់គេចចេញពីការតាមដានរបស់កងឈ្លប និងពួកកម្មាភិបាល ព្រោះយើងជាអ្នកថ្មី ម៉្យាងទៀតគាត់ដឹងរឿងរ៉ាវច្រើន។

តែទោះជាយ៉ាងណា គ្រួសារខ្ញុំនៅតែកម្សត់អភ័ព្វព្រាត់ប្រាសនិរាស ដោយជួបរឿងរ៉ាវច្រើនឥតគណនា គ្មានពេលស្រាកស្រាន្តដោយខំធ្វើការដែលកម្មាភិបាលដាក់ឲ្យ ហើយគេចចេញពីការតាមដាន និងធ្វើទុក្ខបុកម្នេញរបស់កងឈ្លបបដិវត្តន៍គ្រប់ពេល រួចមួយថ្ងៃ គឺយើងរស់បានមួយថ្ងៃ។ បងប្រុសគាត់មិនដែលគិតថាខ្ញុំនិងប្អូនប្រុសជាសាច់ថ្លៃទេ ចំណែកខ្ញុំក៏អ៊ីចឹងដែរគឺប្រៀបដូចបងប្អូនបង្កើតដែលបានសាងឡើងនូវអនុស្សាវរីយ៍មនោសញ្ចេតនាល្អៗនិងភាពញញឹម។

គាត់ត្រូវបានកម្មាភិបាលចាត់តាំងឲ្យមកជួយដាំស្លក្នុងរោងបាយ ស្ថិតនៅកណ្តាលភូមិ។ មិនតែប៉ុណ្ណោះពេលចប់ការងារព្រលប់ៗ បាំងភ្នែកអង្គការភ្នែកម្នាស់ គាត់តែងតែខំលួចកោសយកបាយក្តាំង ឬបបរក្តាំងពីខ្ទះដាក់ក្នុងថង់ក្រមា និងអំបិលគ្រួសបួនប្រាំគ្រាប់ប្រឡាក់សុទ្ធតែដី ព្រោះគាត់ដឹងថាប្អូនយាយតា ហូបមិនដែលគ្រប់គ្រាន់មកព្យួរនឹងកន្ទៀតសសរផ្ទះ។ គាត់លួចខ្សឹបប្រាប់ខ្ញុំប្អូន និងតាយាយថា នៅក្នុងថង់ក្រមាមានបាយក្តាំងនិងអំបិល ប្អូនយកហូបចុះ ប្រយ័ត្នផងខ្លាចកងឈ្លបគេធ្វើមកលេងផ្ទះយើងហើយឃើញលួចបាយក្តាំងមកផ្ទះ គេនឹងរាយការណ៍ជូនថ្នាក់លើភ្លាម យើងច្បាស់ជាគេចោទថាជាខ្មាំងយកទៅកសាងនិងសម្លាប់ចោលមិនខាន។

ចាប់ពីពេលនោះមកខ្ញុំមិនសូវមានភាពទុរ្ភិក្សប៉ុន្មានទេ ព្រោះបានបាយក្តាំងបបរក្តាំងហូបស៊ីងរាល់ពេលល្ងាច។



រូបភាពបច្ចុប្បន្នឆ្នាំ២០១៩៖ សសរផ្ទះនេះហើយ ដែលបងណាតយកបាយក្តាំងនិងអំបិលគ្រួសមកលាក់ទុកឲ្យខ្ញុំ បងប្អូន និងតាយាយ ហូប
(ឡុង វង្សសម្ផស្ស/សៀវភៅ ទួលពិយាជ់)

# ៧. សំណាងមួយក្នុងមួយលានគ្រោះថ្នាក់

## យ៉េត ចរិយា (បងណាត)

### សំណល់ជីវិតកងចល័តធ្ងួល ស្វាយខ្ទួច ឃុំកញ្ជុំ

សូមរម្លឹកថា បងណាត គាត់ក៏ជាកងចល័តជាមួយបងវុឌ្ឍខ្ញុំដែរ ហើយទៅធ្វើការនៅសមរភូមិមុខទួលស្វាយខ្ទួច ឃុំកញ្ចុំ ប៉ុន្តែដោយគាត់មានជំងឺឈឺក្អែក គាត់សុំកម្មាភិបាលសម្រាកនៅការដ្ឋាន។

មានថ្ងៃមួយប្រហែលជាកងឈ្លបមិនបានដឹងថាគាត់នៅក្នុងរោងស្នាក់នៅនោះទេ។ ពួកវាបានមកនិយាយគ្នានៅខាងក្រោយរោងថា "នែសមមិត្ត! អាកងចល័តអ្នកថ្មីមួយដែលឈឺក្អែកនោះ យើងត្រូវរាយការណ៍ទៅអង្គការថ្នាក់លើទៅ។ ទុកវាក៏មិនចំណេញដកចេញក៏មិនខាតដែរ ហើយយកវាទៅនៅភ្នំពេញហ្នឹងទៅ"។

ពេលឮដូច្នេះ គាត់មានការភ័យរន្ធត់ញាប់ញ័រស្ទើរទប់ខ្លួនមិនជាប់។ គាត់ដឹងថាយកទៅភ្នំពេញបានសេចក្តីថាយកទៅសម្លាប់ចោល។ ស្អែកឡើងគាត់រូតរះសុំមេកងចល័តថា សុំសមមិត្តទៅព្យាបាលក្អែកនៅមន្ទីរពេទ្យបដិវត្តន៍ ស្រុកពារាំងស្វាយពល តំបន់ ២២ ។

ពេលព្រលឹមស្រាងៗឡើង គាត់ក៏ស្ពាយសាក់កាដូកញ្ចាស់មួយ ឆ្ពោះទៅកាន់មន្ទីរពេទ្យពារាំង ស្វាយពល តំបន់ ២២ ។



ទិដ្ឋភាពគំណាល៖ បងណាតឈឺក្អែកសម្រាកនៅរោង ហើយឮសំឡេងកងឈ្លបពីរនាក់មកនិយាយគ្នាថា "អាអ្នកថ្មីម្នាក់ដែលឈឺក្អែកនោះបញ្ជូនវាទៅនៅភ្នំពេញទៅ។" (ឡុង វង្សសមិទ្ធ/សៀវភៅទួលពិឃាដ)

---

## ទិដ្ឋភាពយង់ឃ្នង អាសូរស្ត្រីជនជាតិឥស្លាម និងទារក

### សម្លាប់ក្រោមចំពុះទុង, គល់ស្វាយ

ពេលមកដល់ដោយធ្វើដំណើរតាមផ្លូវក្តៅ ហើយក្អែកឈឺរកាំផង គាត់ក៏ដោះខោរួចស្លៀកក្រមា ហើយទម្លាក់ខ្សែដងថ្នឹង និងធុងចូលក្នុងទឹកអណ្តូងដើម្បីទាញយកទឹកមកផឹក។

កំពុងលើកធុងទឹកស្រោចខ្លួនស្រាប់តែឮសូរសំឡេងមនុស្សស្រីស្រែកថា "ជួយផងៗកុំសម្លាប់ខ្ញុំអីៗ។ "រត់លើផ្លូវមុខមន្ទីរពេទ្យ ពកូនងែតអាយុប្រហែលប្រាំខែ ស្គមកំព្រឹងធំតែក្បាល ស្ត្រីនោះស្រែកយំហូរទឹកភ្នែករហាមផង ដោយមានការដេញចាប់ពី

ក្រោយពីពួកកម្មាភិបាលខ្មែរក្រហមពីរនាក់ជិះម៉ូតូ CL90 ទាំងស្រែកថាឈប់ៗ។ កម្មាភិបាលនោះស្ពាយកាំភ្លើងអាកានិងមានដំពុះទុង។

ពេលកម្មាភិបាលនោះមកទាន់បាន យកដំពុះទុងចាក់ទៅលើស្ត្រីនោះឲ្យដួលនៅលើផ្លូវ ហើយកម្មាភិបាលម្នាក់ទៀតចុះពីលើម៉ូតូស្ទុះទៅទាញទារកពីដៃស្ត្រីដែលកំពុងតែឱបជាប់នឹងដើមទ្រូង។ ស្ត្រីនោះបានដេកសំពះងើបមិនរួច ព្រោះត្រូវមួយដំពុះទុងហូរឈាមស្រោចចេញពីពោះពេញផ្លូវ។ ស្ត្រីនោះនៅតែវារលើដីដោយបញ្ចេញសំឡេងខ្សាវៗមានសំនៀងដូចជាជនជាតិចាមថា "កុំសម្លាប់កូនខ្ញុំអីៗ" មិនបង្អង់យូរកម្មាភិបាលនោះក៏ទាញទារកនោះចាប់ជើងបោកផ្ទប់នឹងដើមស្វាយក្បែរនោះឮសូរភូស ហើយស្លាប់មួយរំពេច មានតែសំឡេងយំឮសូរង៉ាវមួយម៉ាត់ប៉ុណ្ណោះ។ ចំណែកស្ត្រីនោះសម្លឹងតាមមើលកូនដែលគេបោះគ្រវែងចោលក្នុងគុម្ពោតព្រៃក្បែរនោះយ៉ាងសង្វេគ ដោយខំវារលើកដៃឡើងលើបញ្ចេញសំឡេងខ្សាវៗថា "ឱ! កូនមាសម្ដាយជាទីស្រឡាញ់អើយ!" ហើយដាច់ខ្យល់ស្លាប់ភ្លាមទៅ។

បងណាត ឃើញទិដ្ឋភាពជីវន្តនេះស្ទើរសន្លប់ ហើយគាត់ក៏ប្រញាប់ប្រញាល់រៀបចំខោអាវដាក់សាក់ការដូដោយដៃញ័រទទ្រើត រួចគាត់គិតថាស្នាក់នៅក្នុងមន្ទីរពេទ្យស្រុកនេះមិនបានទេ។ បើស្នាក់នៅគេប្រាកដជាសម្លាប់នៅយប់នេះ ព្រោះមេកងចល័តច្បាស់ជាបញ្ជូនសារជាតម្រុយឲ្យកម្មាភិបាលបដិវត្តន៍តាមសម្លាប់គាត់នៅមន្ទីរពេទ្យស្រុកតំបន់ ២២ នេះជាមិនខានឡើយ។

គាត់សម្រេចចិត្តចាកចេញពីទីនោះដោយទន់ជង្គង់ ហើយខំប្រឹងតាំងស្មារតីរួចសញ្ជឹងគិតថា តើត្រូវធ្វើដូចម្ដេច? គិតរួចគាត់នឹកឃើញអ្នកស្រុកភូមិជាមួយគ្នាជាកូនកម្មាភិបាលដែលគេបញ្ជូនមកធ្វើការនៅមន្ទីរស្រុកតំបន់២២។ គាត់បានទៅរកគេនោះហើយបានជួប។ គាត់បាននិយាយភូតទៅកាន់គេថា "ខ្ញុំខ្ចីកង់សមមិត្តឯងជិះទៅសមរភូមិម្ដិច" គេយល់ព្រម ហើយគាត់ក៏បង្ហួសមកកាន់ភូមិក្រាំង។

ជិះកង់តែម្នាក់ឯង ជើងមេឃចាប់ផ្ដើមងងឹត ក្នុងចិត្តដក់ជាប់អារម្មណ៍ភ័យខ្លាចនឹងរឿងតក់ស្លុតអម្បាញ់មិញ។ ចេញដំណើរបានបន្តិចពោះវៀនកង់បែក គាត់មិនដឹងគិតយ៉ាងម៉េចៗ កង់ក៏បែកមេឃងងឹតចាប់ផ្ដើមភ្លៀងបង្អុរផ្គរបន្ទោរនិងរន្ទះមិនបង្អង់ដូចជាចង់ប្រាប់ថាគ្រោះជីវិតមកដល់ហើយ។ គាត់គិតថាមិនអាចអត់កង់បានទេទោះជាវាបែកឆ្ងាយយ៉ាងណាក៏ដោយ។ គាត់ចុះបណ្ដើរវាទៅជាមួយ មេឃងងឹត ភ្លៀងដូចរហែកមេឃមើលអ្វីពុំយល់។ តំណក់ទឹកភ្លៀងបានស្រោចស្រពទទឹកជោកពេញខ្លួន តែគាត់ហាក់ដូចជាក្ដៅភាយៗនូវអំណាចការភ័យខ្លាច។

មិនយូរប៉ុន្មានគាត់ក៏បណ្ដើរកង់មកជិតនឹងឃុំស្វាយ។ ភ្នែកឡើងបាយក្រហមរកាំមើលមិនបានវែងឆ្ងាយ ខំប្រឹងសម្លឹងទៅឃើញព្រិលៗកងឈ្លបពីរនាក់ក្នុងរោងយាម មានដើមឫស្សីមួយដើមដាក់យាំងតាមផ្លូវ។ គាត់ឈរសញ្ជឹងគិតមួយសន្ទុះ គិតថាបកក្រោយឬទៅមុខ។ បន្ទាប់មកក៏សម្រេចចិត្តថាទៅណាក៏គង់តែស្លាប់ដូចគ្នា ដូច្នេះត្រូវតែប្រថុយនឹងគ្រោះថ្នាក់នេះគឺត្រូវទៅភូមិក្រាំង។ មិនបង្អង់យូរគាត់ទាញយកក្រមាពីសាក់ការដូមកបង់កនិងពាក់ស្បែកជើងកង់ឡានរួចឡើងជិះកង់ទាំងបែកលើផ្លូវឆ្លងកាត់រោងយាមខំទប់អារម្មណ៍ធ្វើធម្មតា តែព្រលឹងបានហោះចេញពីរាងកាយអស់ហើយ ថានឹងអស់ជីវិតនៅទីនេះ។



ទិដ្ឋភាពតំណាងៈ បងណាត ឃើញកម្មាភិបាលខ្មែរក្រហមយកចំពុះទុងចាក់ទៅលើស្ត្រីនិងចាប់ជើងទារកអាយុប្រហែល៥ខែ បោកផ្ទប់នឹងគល់ស្វាយនៅមុខមន្ទីរពេទ្យបដិវត្តន៍ពារាំងតំបន់២២។ (ឡុង វង្សសមិទ្ធ/សៀវភៅ ទួលពិឃាដ)

**ឡុង ទវ្យសមិទ្ធ**

**(តនៅលេខក្រោយ)**

*រូបក្របមុខ៖*

*ទេព សារឿន អាយុ៦១ឆ្នាំ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង*
*ទទួលសៀវភៅ ទស្សនាវដ្តីស្វែងរកការពិតពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ៖*

*លោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ថតរូបជុំគ្នាជាមួយអ្នករស់រានមានជីវិត*
*ពីរបបខ្មែរក្រហមនៅចេតីយ៍សំណាងនិម្មិតរូប «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។*
*(ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 270, June 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.